សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economigues

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ទោសព្រហ្មទណ្ឌ
# ចំពោះពលកម្មលើកុមារ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សេង ចាន់សុភាព**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economigues**

**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# ទោសព្រហ្មទណ្ឌ
# ចំពោះពលកម្មលើកុមារ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សេង ចាន់សុភាព**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ាង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទ **សេខ ចាន់សុភាព** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ២០ នៃ សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦ - ២០២០។

ជាបឋម ខ្ញុំបាទសូមសំដែងនូវគារវកិច្ច គោរពដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះអ្នកមានគុណទាំងទ្វេគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានប្រឹងប្រែងប្រកបដោយព្រហ្មវិហារធម៌ ចិញ្ចឹមបីបាច់ ថែរក្សា ខិតខំអស់កម្លាំងកាយចិត្ត ប្រឹងប្រែងអប់រំ ប្រៀនប្រដៅ ជួយជ្រោមជ្រែង ក៏ដូចជាជួយជម្រុញឲ្យយើងខ្ញុំបាទ ទទួលនូវចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។

សូមគោរពថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យគ្រប់ៗរូប** ដែលបានខិតខំប្រឹងប្រែង និងប្រឹងអស់ពីសមត្ថភាពគ្រប់បែបយ៉ាងក្នុងការដឹកនាំ ក្នុងគោលបំណងបណ្តុះបណ្តាល មូលធនផ្នែកបញ្ញា ធនធានមនុស្សកម្ពុជាឲ្យមានចំណេះដឹង បទពិសោធន៍ និងមានសមត្ថភាពខ្ពស់ ដើម្បីក្លាយជាសសរទ្រូង ស្របតាមកាលានុវត្តភាពនៃការអភិវឌ្ឍន៍របស់ប្រទេសជាតិ។

សូមគោរពថ្លែងអំណរគុណចំពោះ **លោកគ្រូសាស្ត្រាចារ្យ ហ៊ាន ឡេង** ដែលបានខិតខំប្រឹងប្រែង អប់រំ ណែនាំ ចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត ចែករំលែកចំណេះដឹងទាំងឡាយ ជាមួយការដឹកនាំ កែលម្អ ចង្អុលបង្ហាញ និងតម្រង់ទិស ព្រមទាំងពន្យល់វិធីសាស្ត្រល្អៗ និងផ្តល់យោបល់ល្អៗដែលទាក់ទងនឹងប្រធានបទសារណារបស់ខ្ញុំបាទ រួមទាំងចំណាយពេលវេលាដ៏មានតម្លៃតាំងពីចាប់ផ្តើម រហូតដល់បញ្ចប់ការស្រាវជ្រាវមួយនេះ ។

សូមគោរពថ្លែងអំណរគុណដល់លោកពូ អ្នកមីង បងប្អូនគ្រប់ៗគ្នា ដែលបានជួយទំនុកបម្រុងជាប្រាក់ក្តី ជាកន្លែងស្នាក់នៅក្តីដល់ខ្ញុំបាទ ព្រមទាំងជួយទាំងកម្លាំងកាយ និងកម្លាំងស្មារតី ដើម្បីអោយយើងខ្ញុំបានរៀនសូត្រយកចំណេះដឹងទាំងអម្បាលមាណ រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

ជាចុងបញ្ចប់ ខ្ញុំបាទសូមបួងសួងដល់បារមីនៃវត្ថុសាកសិទ្ធិទាំងឡាយទាំងពួង ដែលមានបារមីនៅលើលោកយើងនេះ សូមមេត្តាតាមបីបាច់ ថែរក្សាអ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ លោកពូ អ្នកមីង បងប្អូន និងមិត្តភក្តិទាំងអស់ ជាពិសេសលោកគ្រូសាស្ត្រាចារ្យណែនាំ **ហ៊ាន ឡេង** សូមជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីខ្ញុំបាទបានសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេលជិត ៤ ឆ្នាំកន្លងទៅនេះ អ្វីៗហាក់ដូចជាលឿនមែនទែន ដែលទើបតែមួយប៉ប្រិចភ្នែកសោះ ខ្ញុំបានបញ្ចប់ថ្នាក់បរិញ្ញាបត្រទៅហើយ។ រយៈពេលកន្លងមកនេះ ខ្ញុំបាទបានទទួលនូវចំណេះដឹងជាច្រើន ទាំងផ្នែកទ្រឹស្តី និងការអនុវត្តនៅក្នុងវិស័យនេះ។ ស្ថិតនៅក្នុងដំណាក់កាលនេះ ដោយផ្អែកតាមចំណេះដឹងនៃការសិក្សាទាំងអប្បាលមាណ ធ្វើឲ្យខ្ញុំបាទមានឱកាស និងលទ្ធភាពក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយ សម្រាប់ទុកជាឯកសារដល់និស្សិតជំនាន់ក្រោយ។ ហើយនេះក៏ជាឱកាសដ៏មានតម្លៃមួយ ដែលអាចស្ទង់អំពីចំណេះដឹងរបស់ខ្ញុំបាទដែលមានពីមុន និងការសិក្សាស្រាវជ្រាវបន្ថែម។ ហេតុនេះហើយ ទើបខ្ញុំបាទបានជ្រើសរើសប្រធានបទទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ ស្តីអំពី «**ទោសព្រហ្មទណ្ឌ ចំពោះពលកម្មលើកុមារ**» មកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សានេះ។

កម្មវត្ថុសំខាន់មួយទៀតនោះ គឺចង់អោយនិស្សិតជំនាន់ក្រោយ និងសាធារណៈជន បានយល់ដឹង និងយកចិត្តទុកដាក់ចំពោះបញ្ហាពលកម្មកុមារ ដែលកំពុងតែកើតមានឡើងគ្រប់ទីកន្លែង ទាមទារឲ្យមានការចូលរួមលុបបំបាត់ទាំងអស់គ្នា។ ពលកម្មកុមារ បានជះឥទ្ធិពលដោយផ្ទាល់ចំពោះកុមារ និងដោយប្រយោលចំពោះការរីកចម្រើនរបស់ប្រទេសជាតិនាពេលអនាគត។ កាលណាពលកម្មកុមារនៅតែបន្ត នោះធនធានកុមារ ដែលជាទំពាំងស្នងឬស្សីរបស់យើង នឹងមិនអាចក្លាយជាឬស្សីដែលល្អ ឬរឹងមាំ សម្រាប់ស្នងកិច្ចការងារអភិវឌ្ឍន៍បន្តពីអ្នកជំនាន់មុនបានឡើយ។ ដែលនេះជាហេតុនាំអោយការអភិវឌ្ឍប្រទេសជាតិមិនមានការរីកចម្រើន ឬមានការរីកចម្រើនយឺត ជាងប្រទេសដទៃ។

មុននឹងបញ្ចប់ បើទោះបីជាខ្ញុំបាទបានខិតខំផ្ចិតផ្ចង់ក្នុងការសរសេរ និងជៀសវាងនូវកំហុសឆ្គងទាំងផ្នែកអក្ខរាវិរុទ្ធ ពាក្យសម្តី និងផ្នែកវេយ្យាករណ៍យ៉ាងណាក៏ដោយ ក៏កំហុសនឹងនៅតែកើតមានដោយប្រការណាមួយដោយអចេតនាជាក់ជាពុំខាន។ ហេតុដូចនេះ យើងខ្ញុំសូមការខន្តីអភ័យទោស ក៏ដូចជាការអធ្យាស្រ័យដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត ហើយខ្ញុំបាទរីករាយនឹងទទួលរាល់មតិកែលម្អ ដើម្បីស្ថាបនានូវរាល់ចំនុចខ្វះខាតទាំងឡាយ ដើម្បីយកមកបំពេញបន្ថែម ព្រមទាំងអភិវឌ្ឍន៍នូវសំណេរអត្ថបទក្រោយៗទៀតអោយកាន់តែប្រសើរឡើង។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរដល់មិត្តនិស្សិត មិត្តអ្នកអានទាំងអស់ សូមទទួលបានជោគជ័យគ្រប់ភារកិច្ច និងកម្លាំងពលំខ្លាំងក្លា ប្រាជ្ញាវាងវៃ អាយុយឺនយូរ រកទទួលទានមានបាន គ្រប់ៗគ្នា ព្រមទាំងជួបតែពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

សេចក្តីផ្តើម....................................................................................................០១

## ជំពូកទី១

## សញ្ញាណទូទៅអំពីការងារ និងពលកម្មកុមារ

ផ្នែកទី១៖ អំពីកុមារ.........................................................................................០៤

១.១.១.និយមន័យ.......................................................................................០៤

១.១.១.១.កុមារ.........................................................................................០៤

១.១.១.២.អនីតិជន....................................................................................០៥

១.១.២.សិទ្ធិកុមារ........................................................................................០៥

១.១.២.១.សិទ្ធិរស់រានមានជីវិត....................................................................០៦

១.១.២.២.សិទ្ធិទទួលបានការអភិវឌ្ឍ.............................................................០៦

១.១.២.៣.សិទ្ធិក្នុងការចូលរួម......................................................................០៦

១.១.២.៤.សិទ្ធិទទួលបានការការពារ...............................................................០៦

ផ្នែកទី២៖ សញ្ញាណទូទៅនៃការងារ និងពលកម្មកុមារ.........................................០៧

១.២.១.អត្ថន័យនៃការងារកុមារ និងពលកម្មកុមារ...............................................០៧

១.២.១.១.អ្វីជាការងារកុមារ?.......................................................................០៧

១.២.១.២.អ្វីជាពលកម្មកុមារ?......................................................................០៧

១.២.២.ភាពខុសគ្នារវាងការងារកុមារ និងពលកម្មកុមារ......................................០៨

១.២.២.១.ការងារកុមារ................................................................................០៨

១.២.២.២.ពលកម្មកុមារ...............................................................................០៩

១.២.២.៣.ភាពខុសគ្នារវាង ការងារ និងពលកម្មកុមារ?............................................០៩

## ជំពូកទី២

## ទម្រង់នៃការងារកុមារ ពលកម្មកុមារ មូលហេតុ និងប្រភពនៃពលកម្មកុមារ

ផ្នែកទី១៖ ទម្រង់នៃការងារ និងពលកម្មកុមារ.........................................................១១

**២.១.១.ទម្រង់ការងារកុមារ**..........................................................................១២
២.១.១.១.ទម្រង់កិច្ចការងារកំប៉ិចកំប៉ុក..........................................................១២
២.១.១.២.ទម្រង់កិច្ចការងារស្រាល.....................................................................១២
**២.១.២.ទម្រង់ពលកម្មកុមារ**.......................................................................១៣
២.១.២.១.ទម្រង់ពលកម្មស្រាល.........................................................................១៣
២.១.២.២.ទម្រង់ពលកម្មធ្ងន់ធ្ងរ.......................................................................១៤
២.១.២.៣.ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ.....................................................១៥
**ផ្នែកទី២៖ មូលហេតុ និងប្រភពពលកម្មកុមារ**...................................................១៨
**២.២.១.មូលហេតុដែលនាំឲ្យមានពលកម្មកុមារ**..............................................១៨
២.២.១.១.មូលហេតុចម្បង...................................................................................១៩
២.២.១.២.មូលហេតុបន្ទាប់បន្សំ...........................................................................២០
**២.២.២.ប្រភពនៃពលកម្មកុមារ**.....................................................................២០
២.២.២.១.ការបញ្ចាំខ្លួនដោះបំណុល.....................................................................២០
២.២.២.២.ទំនាក់ទំនងរវាងម្ចាស់សិប្បកម្ម និងកម្មករជាកុមារ..................................២២
២.២.២.៣.ការជួញដូរកុមារ..................................................................................២៣

## ជំពូកទី៣

## ច្បាប់ពាក់ព័ន្ធ និងទោសព្រហ្មទណ្ឌ ចំពោះពលកម្មលើកុមារ

**ផ្នែកទី១៖ ច្បាប់ជាតិ និងបទដ្ឋានគតិយុត្តអន្តរជាតិ**.........................................២៥
**៣.១.១.ច្បាប់ជាតិ**.......................................................................................២៥
៣.១.១.១.រដ្ឋធម្មនុញ្ញ.......................................................................................២៥
៣.១.១.២.ក្រមព្រហ្មទណ្ឌ...................................................................................២៦
៣.១.១.៣.ច្បាប់ស្តីពីការជួញដូរ...........................................................................២៧
៣.១.១.៤.ច្បាប់ស្តីពីការងារ................................................................................២៩
**៣.១.២.បទដ្ឋានគតិយុត្តអន្តរជាតិ**......................................................................២៩
៣.១.២.១.សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស.............................................២៩

៣.១.២.២.អនុសញ្ញាស្តីពីសិទ្ធិកុមារ.....................................................................៣០
៣.១.២.៣.អនុសញ្ញាស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់ សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ..........................................................................៣០
**ផ្នែកទី២៖ ទោសព្រហ្មទណ្ឌ និទណ្ឌភាព និងដំណោះស្រាយ ចំពោះពលកម្មកុមារ**.....៣១
**៣.២.១.ទោសព្រហ្មទណ្ឌ ចំពោះពលកម្មកុមារ**..................................................៣១
៣.២.១.១.ទោសអនុវត្តន៍ ចំពោះរូបវន្តបុគ្គល........................................................៣២
៣.២.១.២.ទោសអនុវត្តន៍ ចំពោះនីតិបុគ្គល.........................................................៣៧
**៣.២.២.និទណ្ឌភាព និងដំណោះស្រាយ**............................................................៤០
៣.២.២.១.និទណ្ឌភាព......................................................................................៤០
៣.២.២.២.ដំណោះស្រាយ..................................................................................៤១
**សេចក្តីសន្និដ្ឋាន**...........................................................................................៤៥
**អនុសាសន៍**.................................................................................................៤៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ព្រះរាជាណាក្រកម្ពុជា គឺជាប្រទេសមួយដែលបានឆ្លងកាត់នូវរបត់នយោបាយ និងសង្គ្រាមជាច្រើនជំនាន់ ដោយមានទាំងសង្គ្រាមស៊ីវិល និងការជ្រៀតជ្រែកពីបរទេស ជាហេតុធ្វើឲ្យប្រទេសកម្ពុជារងការខូចខាតយ៉ាងខ្លាំងនូវហេដ្ឋារចនាសម្ព័ន្ធ បាត់បង់ធនធានមនុស្សយ៉ាងសន្ធឹកសន្ធាប់ និងធ្វើអោយប្រជាជនជាច្រើនជួបការលំបាកវេទនា ការព្រាត់ប្រាស់ក្រុមគ្រួសារ និងមានជីវភាពក្រីក្រជាដើម។ ជាក់ស្តែងនៅកំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ កម្ពុជាបានធ្លាក់ចូលយ៉ាងជ្រៅក្នុងរបបខ្មៅងងឹត នៃរបបកម្ពុជាប្រជាធិបតេយ្យ។ នាសម័យនោះធនធានមនុស្សស្ទើរតែទាំងអស់ត្រូវបានបាត់បង់ជីវិត និងប្រជាជនទាំងអស់ត្រូវរងទុក្ខវេទនា ធ្វើការងារហួសកម្លាំង ជាពិសេសកុមារក៏ត្រូវបានគេកេងប្រវ័ញ្ចកម្លាំងពលកម្មធ្ងន់ធ្ងរជាទីបំផុតផងដែរ។ ក្រោយមកទៀត កម្ពុជាក៏បានចាកផុតពីភ្លើងសង្គ្រាម និងទទួលបាននូវសុខសន្តិភាពពេញលេញ បន្ទាប់ពីផ្តួលរំលំរបបយង់ឃ្នងមួយនេះ និងបានអភិវឌ្ឍន៍ស្តារប្រទេសជាតិឡើងវិញ។ បើទោះបីជាប្រទេសជាតិមានសុខសន្តិភាពឡើងវិញក៏ដោយប៉ុន្តែធនធានមនុស្សនៅមានចំនួនតិចនៅឡើយ ជាហេតុនាំអោយនាំអោយកម្រិតជីវភាពប្រជាជននៅតែក្រីក្រលំបាក ដែលតម្រូវឲ្យប្រជាជនត្រូវស្វែងរកការងារធ្វើ ដើម្បីចិញ្ចឹមជីវិត និងមានឱកាសរួចផុតពីភាពក្រីក្រ។ កត្តាទាំងនេះហើយ ដែលនាំឲ្យប្រជាជនកម្ពុជា ជាពិសេសកុមារជាច្រើនបានបោះបង់ចោលការសិក្សា ដើម្បីស្វែងរកការងារធ្វើ ក្នុងគោលបំណងទទួលបានប្រាក់ដើម្បីចាយវាយ ក៏ដូចជាជួយផ្គត់ផ្គង់ជីវភាពផ្ទាល់ខ្លួន និងជីវភាពគ្រួសារ ហើយជារឿយៗដោយសារកង្វះចំណេះដឹង និងចាញ់ល្បិចបោកបញ្ឆោតរបស់ជនខិលខូច ឬបុគ្គលដែលមានបំណងចង់កេងប្រវ័ញ្ចលើខ្លួន ពួកគេក៏ផុងខ្លួនជាមួយជនដែលកេងប្រវ័ញ្ច តាមរយៈមធ្យោបាយបោកប្រាស់សន្យាផ្តល់លក្ខខណ្ឌជីវភាពរស់នៅល្អប្រសើរ ។ ល ។ ប៉ុន្តែទាំងអស់នេះ គ្រាន់តែជាការភូតកុហក ទៅកាន់ពួកគេតែប៉ុណ្ណោះ ជាពិសេសកុមារដែលជាមនុស្សវ័យក្មេង មានចំណេះដឹងតិចតួច និងកង្វះខាតនូវបទពិសោធន៍ជីវិត ដើម្បីកេងប្រវ័ញ្ចពលកម្មលើពួកគេជាកុមារ។ ហើយបច្ចុប្បន្ននេះ បញ្ហាពលកម្មកុមារ គឺជាបញ្ហាដ៏ធំមួយដែលកំពុងចោទឡើងនៅពាសពេញពិភពលោក និងរួមទាំងកម្ពុជាផងដែរ។

## ២. ចំណោទបញ្ហា

ពលកម្មកុមារ ជាបញ្ហាប្រឈមធ្ងន់ធ្ងរមួយនៅកម្ពុជា ដែលគេបានមើលរំលង។ កុមាររាប់លាននាក់កំពុងក្លាយជាឧបករណ៍សម្រាប់ការរកចំណូលផ្គត់ផ្គង់គ្រួសារ ការធ្វើការងារដោយគ្មានការសម្រាក ជាពិសេសកុមារទាំងនោះគ្មានឱកាសបន្តការសិក្សា។ បញ្ហានេះ នឹងប៉ះពាល់បន្តដល់ការអភិវឌ្ឍប្រទេសកម្ពុជា និងជាបន្ទុករបស់រដ្ឋាភិបាល ប្រសិនបើគ្មានដំណោះស្រាយសមរម្យនោះទេ។ របាយការណ៍របស់ក្រសួងផែនការបានបង្ហាញថា កុមារដែលមានអាយុចន្លោះពី ៥ ឆ្នាំ ដល់ ១៧ ឆ្នាំ មានចំនួនជិត ៤លាននាក់ ភាគច្រើនបំផុតរស់នៅជនបទ

ដែលកុមារចំនួន ៨០% ជាប់ទាក់ទងនឹងការងារផ្ទះ និងការរកចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ។ ការងាររបស់កុមារទាំងនោះ ភាគច្រើនធ្វើការច្រើនម៉ោង ដើម្បីជួយក្រុមគ្រួសាររបស់គេ ឬជាប្រភេទការងារដែលមិនទទួលកម្រៃអ្វីទាំងអស់។ ឯកសារដែលចងក្រងដោយស្ថាប័នស្រាវជ្រាវអន្តរជាតិជាច្រើនបានរកឃើញថា កុមារចំនួន ៧៥ ម៉ឺននាក់ ជាក្រុមកុមារដែលទទួលខុសត្រូវលើសេដ្ឋកិច្ចគ្រួសារ។ មូលហេតុចម្បងមួយសំខាន់បំផុតដែលបណ្តាលឲ្យមានពលកម្មកុមារគឺ ភាពក្រីក្រ និងមូលហេតុបន្ទាប់បន្សំផ្សេងៗទៀត។ កត្តាទាំងនេះបានបង្ខំឲ្យកុមារត្រូវធ្វើកិច្ចការជាច្រើន និងបំភ្លេចចោលនូវការសិក្សារបស់ខ្លួន។ ការស្រាវជ្រាវដោយអង្គការអន្តរជាតិខាងការងារក៏បានរកឃើញថា កុមារចំនួន ៤៣ ម៉ឺននាក់ បានបោះបង់ចោលការសិក្សា និងចំនួនជិត ៤០ ម៉ឺននាក់ផ្សេងទៀត ពុំដែលចូលសាលាទាល់តែសោះ។ ភាគច្រើន ក្រុមកុមារដែលបោះបង់ចោល និងបាត់បង់ឱកាសសិក្សាមកពីគ្រួសារដែលធ្វើចំណាកស្រុកពីខេត្តមួយទៅខេត្តមួយ ឬពីប្រទេសមួយ ទៅប្រទេសមួយទៀត។ បន្ថែមលើនេះ កត្តាជីវភាពក្រីក្ររបស់គ្រួសារនៅជនបទបានបង្ខំឲ្យកូនរបស់គេមកធ្វើការនៅទីក្រុង ឬធ្វើចំណាកស្រុក។ ករណីខ្លះឈានដល់ការកែប្រែអាយុ ឲ្យគ្រប់នីតិភាព ដើម្បីរកការងារមួយសមរម្យ។ ទោះជាយ៉ាងណាក៏ដោយ ការរកឃើញដោយអង្គការពលកម្មអន្តរជាតិ (ILO) បានបញ្ជាក់ថា ដើម្បីលើកកម្ពស់អត្រាចូលសិក្សា និងកាត់បន្ថយនូវពលកម្មកុមារ រដ្ឋាភិបាលកម្ពុជាបានផ្តល់អាហារសម្រាប់កុមារអាយុ ៥ ឆ្នាំដល់ ១៧ ឆ្នាំ បានចំនួនជាង ៣ លាននាក់ ដែលស្មើនឹង ៨០% នៃកុមារកម្ពុជាសរុប ប៉ុន្តែពលកម្មកុមារ នៅតែកើនឡើង។

## ៣. សារៈសំខាន់ និងគោលបំណងនៃការស្រាវជ្រាវ

ដោយសារតែ ពលកម្មកុមារ ជាបញ្ហាចោទ និងប៉ះពាល់ដល់ផលប្រយោជន៍របស់កុមារ ជាពិសេសនោះគឺវាបានជះឥទ្ធិពលដល់ការអភិវឌ្ឍប្រទេសជាតិ ទើបយើងគ្រប់រូបគប្បីពិចារណា និងគិតគូរអោយបានដិតដល់លើបញ្ហានេះ។ សារណាស្តីអំពី **ទោសព្រហ្មទណ្ឌ ចំពោះពលកម្មលើកុមារ** មានគោលបំណង ២(ពីរ)សំខាន់ៗ។ គោលបំណងទី១នោះ គឺដើម្បីឲ្យសាធារណជន ជាពិសេសមន្ត្រីអនុវត្តច្បាប់ យល់ដឹងអំពីអ្វីទៅជាការងារកុមារ ហើយអ្វីទៅជាពលកម្មកុមារ? ពិសេសជាងនេះទៅទៀត គឺដើម្បីជាមូលដ្ឋានគ្រឹះមួយ សម្រាប់ផ្តន្ទាទោសចំពោះបុគ្គលដែលប្រព្រឹត្តបទល្មើស កេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ។ ចំណែកឯគោលបំណងទី២ នៃសារណានេះ គឺដើម្បីជាផ្នែកមួយក្នុងការចូលរួមទប់ស្កាត់ បង្ការ និងជម្រុញឲ្យមានការកាត់បន្ថយ ឈានទៅរកការលុបបំបាត់ទាំងស្រុងនៃពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

## ៤. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវ និងការចងក្រងសារណានេះឡើង ត្រូវបានធ្វើឡើងដោយយកចិត្តទុកដាក់ ជាមួយនឹងការប្រមូលនូវឯកសារពាក់ព័ន្ធ ដែលមានប្រភពច្បាស់លាស់ គួរឲ្យទុកចិត្តបានពីបណ្ណាបណ្ណាល័យ អង្គការសង្គមស៊ីវិល និងច្បាប់បញ្ញត្តិដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា។

## ៥. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះ នឹងធ្វើបង្ហាញលម្អិតអំពីការងារកុមារ ពលកម្មកុមារ និងទោសព្រហ្មទណ្ឌចំពោះពលកម្មកុមារ ដែលបែងចែកជា ៣ ជំពូកគឺ៖

- ជំពូកទី ១ "**សញ្ញាណទូទៅអំពីការងារ និងពលកម្មកុមារ**"
- ជំពូកទី ២ "**ទម្រង់នៃការងារកុមារ ពលកម្មកុមារ មូលហេតុ និងប្រភពនៃពលកម្មកុមារ**" និង
- ជំពូកទី ៣ "**ច្បាប់ពាក់ព័ន្ធ និងទោសព្រហ្មទណ្ឌ ចំពោះពលកម្មលើកុមារ**" ។

# ជំពូកទី១
# សញ្ញាណទូទៅអំពីការងារ
# និងពលកម្មកុមារ

# ជំពូកទី១

# សញ្ញាណទូទៅអំពីការងារ និងពលកម្មកុមារ

## ផ្នែកទី១៖ អំពីកុមារ

មុននឹងធ្វើការសិក្សា ស្វែងយល់លម្អិតអំពីការងារកុមារ ក៏ដូចជាពលកម្មកុមារ យើងគប្បីស្វែងអំពីពាក្យថា «កុមារ» និង «អនីតិជន» ជាមុនសិន។ មានមតិខ្លះបានលើកឡើងថា កុមារ ដូចគ្នាទៅនឹង អនីតិជន។ ប៉ុន្តែក៏មានមតិខ្លះទៀត បានលើកឡើងផ្ទុយពីនេះ ដោយបញ្ជាក់ថា ពាក្យទាំងពីរនេះខុសគ្នា ហើយការប្រើប្រាស់ក៏ខុសគ្នាដែរ។ តើពាក្យថា «កុមារ» និង «អនីតិជន» មានន័យដូចគ្នា ឬខុសគ្នា យ៉ាងដូចម្តេចខ្លះ?

### ១.១.១.និយមន័យ

#### ១.១.១.១.កុមារ

នៅក្នុងបរិបទនៃប្រទេសកំពុងអភិវឌ្ឍន៍ មានមតិជាច្រើន និងការយល់ឃើញមួយចំនួនពាក់ព័ន្ធទៅនឹងពាក្យថា «កុមារ» នេះផ្សេងៗគ្នា។ ជាក់ស្តែងណាស់ គេបានលើកឡើងថា មនុស្សដែលមានអាយុក្រោម ១ ឆ្នាំ ឬ ១ ខួប គិតចាប់ពីថ្ងៃកំណើត ត្រូវបានគេហៅថាជា «ទារក ឬ ទារិកា»។ ឯមនុស្សដែលមានអាយុច្រើនជាង ១ ឆ្នាំ រហូតដល់អាយុក្រោម ៦ ឆ្នាំ ត្រូវបានគេហៅថាជា «កូនក្មេង ឬ ក្មេងៗ»។ រីឯមនុស្ស ដែលមានអាយុចាប់ពី ៦ ឆ្នាំរហូតដល់ ១៤ ឆ្នាំ ត្រូវបានគេហៅថាជា «កុមារ»។ ចំណែកឯមនុស្សដែលមានអាយុចាប់ពី ១៤ ឆ្នាំ រហូតដល់អាយុក្រោម ១៨ ឆ្នាំ ត្រូវបានគេហៅថា «អនីតិជន» វិញ។

បើទោះបីជាយ៉ាងនេះក្តី ក៏មាននិយមន័យផ្លូវការមួយចំនួនបានលើកឡើងថា «កុមារ» សំដៅលើមនុស្សទាំងឡាយណាដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។[1] និយមន័យផ្សេងទៀត បានលើកឡើងថា ចំពោះបុគ្គលទាំងឡាយណាដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គឺជា «កុមារ»។[2]

ចំណែកឯកសារខ្លះទៀត បានអោយនិយមន័យរបស់កុមារថា «កុមារ» ត្រូវបានគេទទួលស្គាល់ថាជាមនុស្សមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ លើកលែងតែច្បាប់របស់ប្រទេស ចែងពីអាយុពេញវ័យដែលគេសន្មតរហ័សជាង។[3] ការអោយនិយមន័យបែបនេះ មានគោលបំណងសម្រាប់កំណត់អំពីអាយុរបស់កុមារ ទៅតាមប្រទេសនីមួយៗលើពិភពលោក ដោយផ្អែកលើមូលដ្ឋាននៃការរីកលូតលាស់ទាំងផ្នែករូបរាងកាយ ចំណេះដឹង និងផ្អែកលើបរិបទសង្គមរបស់ប្រទេសទាំងនោះ។ ជាការពិតណាស់ កុមារនៅក្នុងតំបន់អាស៊ីភាគច្រើនកំណត់យកអាយុ ១៨ ឆ្នាំ ទើបក្លាយអាយុពេញវ័យ ឬអាចនិយាយម្យ៉ាងទៀតថា មាននីតិភាពដែលទទួល

[1] អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៣៨ និងលេខ ១៨២

[2] ច្បាប់ស្តីពីការងារ

[3] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ

ស្គាល់ដោយច្បាប់ ដែលខុសពីកុមារដែលនៅតំបន់អឺរ៉ុប។ នៅតំបន់អឺរ៉ុប គេកំណត់អាយុពេញវ័យត្រឹមអាយុ ១៥ ឆ្នាំប៉ុណ្ណោះ។ មានន័យថានៅតំបន់អឺរ៉ុប កុមារ គឺជាមនុស្សដែលមានអាយុក្រោម ១៥ ឆ្នាំ បើប្រៀបធៀបជាមួយប្រទេសកម្ពុជាវិញ អាយុ ១៥ ឆ្នាំគឺនៅជាកុមារនៅឡើយ។[4]

ក្រៅពីពាក្យថា «កុមារ» ក៏មានពាក្យមួយទៀតដែរ ដែលពាក្យនោះគឺ «អនីតិជន»។

### ១.២.១.២.អនីតិជន

នៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រៅពីពាក្យ «កុមារ» ក៏មានពាក្យមួយទៀតដែលមានអត្ថន័យដូចគ្នាផងដែរ នោះគឺពាក្យ «អនីតិជន»។ ពាក្យថា «អនីតិជន» គឺជាជនដែលមានអាយុក្រោម ១៨(ឆ្នាំ)។[5] ឯន័យម្យ៉ាងទៀត សំដៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស។[6]

យើងឃើញថា ពាក្យថា «កុមារ» មានន័យដូចគ្នាទៅនឹង «អនីតិជន»។ ប៉ុន្តែក្នុងន័យច្បាប់ គេច្រើនប្រើពាក្យ «អនីតិជន» ជាពិសេសនៅក្នុងបទល្មើសព្រហ្មទណ្ឌ។ ជាមួយគ្នានេះ ពាក្យថាអនីតិជននេះ គេប្រើសម្រាប់ការកំណត់ទោស និងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអនីតិជន។ ជាគោលការណ៍ អនីតិជនដែលមានអាយុក្រោម ១៨ ឆ្នាំ គឺជាវ័យមួយដែលទទួលបាននូវការពារសិទ្ធិ និងផលប្រយោជន៍ពិសេស។ ដូចនេះ បញ្ញត្តិច្បាប់នានា ក៏ធ្វើឡើងដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ទាំងនោះចំពោះអនីតិជន ឬកុមារផងដែរ។

ជារួមមក ពាក្យថា «កុមារ» និង «អនីតិជន» គឺសំដៅលើមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំដូចគ្នា។

នៅក្នុងសារណានេះ យើងនឹងប្រើពាក្យ កុមារ ជំនួសឲ្យពាក្យ អនីតិជន ក៏ដោយសារតែយើងសន្មតថាពាក្យទាំងពីរនេះ មានអត្ថន័យដូចគ្នា។ តើកុមារ ឬអនីតិជន មានសិទ្ធិអ្វីខ្លះ?

### ១.១.២.សិទ្ធិកុមារ

សិទ្ធិកុមារ គឺជាអ្វីៗដែលកុមារគួរមាន ឬមានលទ្ធភាពអាចបាន។ កុមារទាំងអស់មានសិទ្ធិដូចៗគ្នា។ ហើយសិទ្ធិគ្រប់យ៉ាងរបស់កុមារ ត្រូវបានចុះក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ។ គ្រប់ភាគី(ប្រទេស)ទាំងអស់សុទ្ធតែបានយល់ស្របទៅនឹងសិទ្ធិទាំងនេះ។ សិទ្ធិទាំងអស់របស់កុមារ គឺជាប់ពាក់ព័ន្ធគ្នាទៅវិញទៅមក ហើយសិទ្ធិទាំងអស់ក៏សុទ្ធតែមានសារៈសំខាន់ដូចៗគ្នា។ សិទ្ធិកុមារត្រូវបានកំនត់យ៉ាងច្រើនប្រភេទ រួមបញ្ចូលទាំងភាពធំទូលាយនៃសង្គម វប្បធម៌ សេដ្ឋកិច្ច និងសង្គម។

អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ បានបែងចែកជា ៤ ប្រភេទធំៗនៃសិទ្ធិកុមារគឺៈ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍន៍ សិទ្ធិក្នុងការចូលរួម និងសិទ្ធិទទួលបានការការពារ។

[4] https://ec.europa.eu/eurostat/web/products-eurostat-news/-/EDN-20170531-1
[5] មាត្រា ៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
[6] មាត្រា ៤ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

### ១.១.២.១.សិទ្ធិរស់រានមានជីវិត

សិទ្ធិរស់រានមានជីវិត គឺជាសិទ្ធិមូលដ្ឋាន និងជាសិទ្ធិចាំបាច់បំផុតសម្រាប់មនុស្សទូទៅ មិនមែនតែសម្រាប់កុមារនោះទេ។ ដើម្បីធានាដល់ការរស់រានមានជីវិតបាន រដ្ឋត្រូវធានាថា កុមារគ្រប់រូបមានអាហាររូបត្ថម្ភគ្រប់គ្រាន់ ត្រឹមត្រូវសម្រាប់ទទួលទាន ប្រកបដោយសុខុមាលភាព មានទីលំនៅ ឬផ្ទះសមរម្យរស់នៅ មានទឹកស្អាតប្រើប្រាស់ និងមានមន្ទីរពេទ្យសម្រាប់មើលថែ ព្យាបាលកុមារពេលមានជម្ងឺឈឺថ្កាត់ និងចុងក្រោយនោះត្រូវធានានូវបរិស្ថានបរិសុទ្ធ មិនប៉ះពាល់ដល់សុខភាពកុមារ។

### ១.១.២.២.សិទ្ធិទទួលបានការអភិវឌ្ឍន៍

សិទ្ធិទទួលបានការអភិវឌ្ឍន៍ គឺជាសិទ្ធិមួយដែលកុមារគ្រប់រូបត្រូវទទួលបាន ក្នុងការអភិវឌ្ឍរូបរាងកាយ សតិបញ្ញា ស្មារតី ចំណេះដឹង និងជំនាញ។ មានន័យថារដ្ឋត្រូវមានសាលារៀន តាំងពីមតេយ្យសិក្សាដើម្បីអោយកុមារបានចូលសិក្សារៀនសូត្រ អភិវឌ្ឍន៍បញ្ញា ស្មារតី និងចំណេះដឹងរបស់ខ្លួន និងធានាថាពួកគេមានជំនាញច្បាស់លាស់នាពេលអនាគត។

### ១.១.២.៣.សិទ្ធិក្នុងការចូលរួម

សិទ្ធិក្នុងការចូលរួម គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិផ្សេងៗទៀត ដែលផ្តល់ឱកាសអោយកុមារបានចូលរួមក្នុងសកម្មភាពសង្គម ចូលរួមក្នុងកម្មវិធីសិល្បៈ វប្បធម៌ ចូលរួមក្នុងការលេងល្បែងប្រជាប្រិយ និងចូលរួមគ្រប់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងប្រយោជន៍កុមារ ដោយគ្មានការរើសអើង និងដោយការគោរពទៅវិញទៅមក។

### ១.១.២.៤.សិទ្ធិទទួលបានការការពារ

សិទ្ធិទទួលបានការការពារ គឺជាសិទ្ធិពិសេសមួយ ដែលរដ្ឋត្រូវធានា ក្នុងការការពារកុមារពីការប្រើអំពើហិង្សា ការពារពីការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងផ្លូវភេទ ការពារពីការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការពារពីការរើសអើង ការពារពីការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន និងការពារពីអំពើឧក្រិដ្ឋផ្សេងៗ។

ក្នុងចំណោមសិទ្ធិធំៗទាំង ៤ ប្រភេទខាងលើ មានសិទ្ធិមួយដែលជាសិទ្ធិពិសេស ហើយត្រូវបានចាត់ទុកថា កុមារគឺជាជនងាយរងគ្រោះ ត្រូវមានវិធានការពិសេសដើម្បីបង្ការ និងទប់ស្កាត់ នោះគឺសិទ្ធិទទួលបានការការពារ។

យើងនឹងលើកយកសិទ្ធិមួយរបស់កុមារ នោះគឺសិទ្ធិទទួលបានការការពារ ពីការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ និងទោសព្រហ្មទណ្ឌ ចំពោះពលកម្មកុមារ ដែលជនដែលប្រព្រឹត្តបទល្មើសត្រូវប្រឈម។ ប៉ុន្តែមុននឹងឈានដល់ការបកស្រាយទាំងនោះ យើងគប្បីស្វែងយល់អំពីការងារកុមារ និងពលកម្មកុមារជាមុនសិន។

## ផ្នែកទី២៖ សញ្ញាណទូទៅនៃការងារ និងពលកម្មកុមារ

### ១.២.១.អត្ថន័យនៃការងារកុមារ និងពលកម្មកុមារ

#### ១.២.១.១.អ្វីជាការងារកុមារ?

«ការងារ» សំដៅទៅលើ កិច្ចការដែលត្រូវធ្វើតាមមុខងាររបស់ខ្លួន។[7]

«កុមារ» សំដៅលើមនុស្សដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។

ពាក្យថា ការងារកុមារ បានមកពីពាក្យ «ការងារ + កុមារ» ។ ដូច្នេះ យើងអាចអោយនិយមន័យថា ការងារកុមារ គឺជាកិច្ចការងារទាំងឡាយណាដែលមនុស្សមានអាយុក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ត្រូវធ្វើតាមមុខងាររបស់ខ្លួន។ ប៉ុន្តែសួរថាតើមនុស្សដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំមានមុខងារអ្វីខ្លះ? នៅពេលដែលកុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំនៅឡើយ ថាតើពួកគាត់តម្រូវអោយធ្វើអ្វីខ្លះ?

ការងារកុមារ គឺជាការងារដែលច្បាប់អនុញ្ញាតឲ្យកុមារអាយុចាប់ពី ១២ ឆ្នាំឡើងទៅអាចធ្វើបាន ឲ្យតែការងារនោះមិនប៉ះពាល់ដល់សុខភាព សុវត្ថិភាព សីលធម៌ ការរីកលូតលាស់ផ្នែកស្មារតី ការរីកលូតលាស់ផ្នែករូបរាងកាយ និងសតិបញ្ញាស្មារតីរបស់កុមារ។ ជាពិសេស ការងារទាំងនោះ មិនប៉ះពាល់ដល់ការសិក្សាជាទៀងទាត់របស់កុមារ ពោលគឺត្រូវធានាបានថាកុមារបានទទួលការសិក្សារៀនសូត្រពេញលេញ។

ផ្ទុយមកវិញ ចំពោះការងារទាំងឡាយដែលផ្ទុយពីការរៀបរាប់ខាងលើ គឺត្រូវបានចាត់ទុកថា បានហួសដែនកំណត់នៃពាក្យថា ការងារកុមារ ហើយត្រូវបានគេហៅថាជា «ពលកម្មកុមារ» វិញ។

#### ១.២.១.២.អ្វីជាពលកម្មកុមារ?

ដើម្បីបកស្រាយអំពី អ្វីទៅជាពលកម្មកុមារ? យើងគប្បីស្វែងយល់ពីពាក្យ «ពលកម្ម» ជាមុនសិន។

«ពលកម្ម» សំដៅលើ អំពើ ឬសកម្មភាពទាំងឡាយណាដែលប្រើប្រាស់នូវកម្លាំង មិនថាកម្លាំងកាយ ឬកម្លាំងបញ្ញាស្មារតី។

ដូចនេះ ពាក្យថា «ពលកម្មកុមារ» គឺជាសកម្មភាពទាំងឡាយណាដែលប្រើប្រាស់នូវកម្លាំងរបស់កុមារ មិនថាទាំងកម្លាំងកាយ ឬកម្លាំងស្មារតី។ ប៉ុន្តែ បើយោងទៅតាមអនុសញ្ញាអង្គការពលកម្មពិភពលោកស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ បានឲ្យនិយមន័យ «ពលកម្មកុមារ» ថា គឺជាការងារដែលធ្វើអោយប៉ះពាល់ដល់សុខុមាលភាពរបស់កុមារ ការអប់រំ ការអភិវឌ្ឍ និងការរស់រានតនៅថ្ងៃអនាគតរបស់ពួកគេ។ ពលកម្មកុមារ គឺជាការងារទាំងឡាយណា ដែលប្រភេទ ឬដំណើរការនៃប្រតិបត្តិការការងាររបស់វាបង្កអោយមានគ្រោះថ្នាក់ រំលោភបំពាន និងកេងប្រវ័ញ្ចញើសឈាមរបស់កុមារ ហើយបានធ្វើអោយកុមារឃ្លាតឆ្ងាយពីការអប់រំ។[8]

[7] វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត

[8] មាត្រា ២ នៃអនុសញ្ញាអង្គការពលកម្មអន្តរជាតិស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

ក្រៅពីពាក្យថា «ពលកម្មកុមារ» អង្គការពលកម្មអន្តរជាតិ(ILO) បានប្រើប្រាស់ពាក្យ «កុមារបម្រើការងារ» និង «កុមារបម្រើសកម្មភាពសេដ្ឋកិច្ច»។ ពាក្យទាំងនេះបង្កើតឡើងក្នុងគោលបំណងសម្រាប់ប្រើប្រាស់ និងមានភាពងាយយល់នាពេលធ្វើស្ថិតិ ឬស្ទង់មតិ ជាដើម។ ពាក្យទាំងពីរខាងលើ សំដៅលើការងារដែលធ្វើដោយកុមារលើសពីមួយម៉ោងក្នុងមួយសប្តាហ៍។ ការងារនេះអាចជាការងារដែលទទួលបានប្រាក់កម្រៃ ឬគ្មានប្រាក់កម្រៃសម្រាប់ការងារនៅក្នុងទីផ្សារ ឬគ្មានទីផ្សារ មានលក្ខណៈទៀងទាត់ ឬយូរៗម្តង ស្របច្បាប់ ឬមិនស្របច្បាប់។ នៅក្នុងករណីភាគច្រើន ការងារទាំងនោះស្ថិតនៅក្រោមច្បាប់ ហេតុដូច្នេះ វាមិនត្រូវបានចាត់ទុកថាជាពលកម្មកុមារនោះទេ។ ហេតុដូចនេះហើយ វាមានសារៈសំខាន់ណាស់ ដើម្បីបែងចែកអោយច្បាស់រវាងពាក្យថា «ពលកម្មកុមារ» ដែលមានលក្ខណៈខុសច្បាប់ និងសកម្មភាពផ្សេងៗដែលត្រូវបានធ្វើដោយកុមារ តែជាការងារស្របច្បាប់។ អង្គការពលកម្មអន្តរជាតិ(ILO) ប្រើប្រាស់នូវពាក្យបច្ចេកទេសទាំងនេះ ដោយសារតែវាមានភាពងាយស្រួលក្នុងប្រមូលទិន្នន័យ ដោយផ្អែកលើពាក្យខុសគ្នាទាំងនេះ ជាជាងផ្អែកលើតែពាក្យពលកម្មកុមារតែមួយមុខ។ និយមន័យនឹងកាន់ទូលំទូលាយជាងនេះ ប្រសិនបើប្រៀបធៀបពីប្រទេសមួយទៅប្រទេសមួយទៀតដែលត្រូវបានផ្តល់ដោយអង្គការពលកម្មអន្តរជាតិ(ILO)។

សម្រាប់កម្ពុជាវិញក៏មាននិយមន័យមួយផ្សេងទៀត ដែលលើកឡើងប្រហាក់ប្រហែលគ្នានឹងនិយមន័យខាងលើផងដែរ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(MLVT) បានឲ្យនិយមន័យនៃ «ពលកម្មកុមារ» ថាជាការងារដែលធ្វើដោយកុមារក្រោមអាយុ ១៨ (ដប់ប្រាំបី)ឆ្នាំ រួមបញ្ចូលការងារបានប្រាក់កម្រៃ ឬគ្មានប្រាក់កម្រៃ ដែលប៉ះពាល់ដល់ការលូតលាស់ផ្នែកបញ្ញាស្មារតី ផ្នែករូបរាងកាយ ផ្នែកសង្គម ឬសីលធម៌របស់កុមារ និងរារាំងកុមារក្នុងការទទួលបានការអប់រំពេញលេញ។[9] ការងារណាដែលជួយដល់ការអប់រំ ឬបណ្តុះបណ្តាលកុមារសម្រាប់ការងារនៅពេលអនាគត និងជាផ្នែកមួយនៃដំណើរការសង្គម និងគ្រួសារ វាត្រូវបានកំណត់ថាជាការងារកុមារ និងមិត្រូវចាត់ទុកថាជាពលកម្មកុមារ ឬពលកម្មកុមារ នៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតឡើយ។

### ១.២.២.ភាពខុសគ្នារវាងការងារកុមារ និងពលកម្មកុមារ

#### ១.២.២.១.ការងារកុមារ

ដូចបានរៀបរាប់ខាងលើរួចមកហើយអំពីអត្ថន័យនៃ «ការងារកុមារ»។ ប៉ុន្តែនៅក្នុងចំនុចនេះ យើងនឹងបង្ហាញអំពីលក្ខណៈសម្គាល់របស់ការងារកុមារ។ តើវាមានលក្ខណៈដូចម្តេចខ្លះ និងបែងចែកជាប៉ុន្មានប្រភេទ?

ការងារកុមារ ត្រូវបានគេបែងចែកជា ២(ពីរ)គឺ៖

១- ទម្រង់កិច្ចការងារកំប៉ិចកំប៉ុក

២- ទម្រង់កិច្ចការងារស្រាល

---

[9] និយមន័យនៃពលកម្មកុមារ ផ្តល់ដោយ MLVT នៃឯកសារផែនការអភិវឌ្ឍន៍ជាតិ ២០០៩-២០១៤

ការងារកុមារ មិនត្រូវបានកំណត់ពីអាយុរបស់កុមារឡើយ ប៉ុន្តែលក្ខណៈនៃការងារកុមារ គឺត្រូវប្រាកដថា ការងារទាំងនោះនឹងមិនប៉ះពាល់ដល់សុខភាព សុវត្ថិភាព សីលធម៌ ការរីកលូតលាស់ផ្នែកស្មារតី រូបរាងកាយ និងសតិបញ្ញាស្មារតីរបស់កុមារ ព្រមទាំងមិនប៉ះពាល់ដល់ការសិក្សាពេញលេញរបស់កុមារ។

### ១.២.២.២.ពលកម្មកុមារ

ពលកម្មកុមារ មានលក្ខណៈធ្ងន់ធ្ងរជាង និងមានផលប៉ះពាល់អាក្រក់ ឬអាក្រក់បំផុត អាស្រ័យលើសកម្មភាពការងារដែលកុមារនោះកំពុងធ្វើ។ ដូចនេះហើយ ពលកម្មកុមារ គឺសំដៅលើការងារទាំងឡាយដែលកុមារមានអាយុតិចជាងអាយុអប្បបរមា ១៥ (ដប់ប្រាំ)ឆ្នាំ សម្រាប់ប្រភេទការងារដែលច្បាប់កំណត់។ លើសពីនេះទៅទៀតនោះ ការងារនោះ គឺជាការងារដែលនាំឲ្យប៉ះពាល់ដល់សុខុមាលភាព សុវត្ថិភាព សីលធម៌ ការរីកលូតលាស់ផ្នែកស្មារតី រូបរាងកាយ និងសតិបញ្ញាស្មារតី ការអភិវឌ្ឍជំនាញ ឬការសិក្សាពេញលេញរបស់កុមារ។

ពលកម្មកុមារ ត្រូវបានបែងចែកជា ៣(បី)គឺៈ

១- ពលកម្មស្រាល

២- ពលកម្មធ្ងន់ធ្ងរ

៣- ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ

លក្ខណៈពិសេសនៃពលកម្មកុមារគឺ ប៉ះពាល់ដល់សុខភាព សុវត្ថិភាព សីលធម៌ ការរីកលូតលាស់ផ្នែកស្មារតី រូបរាងកាយ និងសតិបញ្ញាស្មារតី ការអភិវឌ្ឍជំនាញ ឬការសិក្សាពេញលេញរបស់កុមារ។

### ១.២.២.៣.ភាពខុសគ្នារវាង ការងារ និងពលកម្មកុមារ

ការងារទាំងអស់ដែលធ្វើដោយកុមារ មិនមែនសុទ្ធតែជាពលកម្មកុមារនោះទេ។ ដូចនេះ តើអ្វីជាភាពខុសគ្នារវាងការងារកុមារ និងពលកម្មកុមារ? តើនៅពេលណាដែលការងារកុមារ ក្លាយជាពលកម្មកុមារ?

នៅក្នុងឯកសារបោះពុម្ពផ្សាយជាសកលរបស់អង្គការពលកម្មពិភពលោក (ILO) និងកម្មវិធីស្តីពីការលុបបំបាត់ពលកម្មកុមារ ពាក្យថា «ការងារកុមារ» និង «ពលកម្មកុមារ» ត្រូវបានកំណត់ និងបែងចែកគ្នាយ៉ាងដាច់ស្រឡះតែម្តងអំពីភាពខុសគ្នារវាង «ការងារកុមារ» និង «ពលកម្មកុមារ»។[10]

| | ការងារកុមារ | ពលកម្មកុមារ |
|---|---|---|
| **អាយុ** | ក្រោម ឬតិចជាង ១៨ ឆ្នាំ | ក្រោម ឬតិចជាង ១៨ ឆ្នាំ |
| **ប្រភេទការងារ** | ការងារកំប៉ិចកំប៉ុក មិនអចិន្ត្រៃយ៍ | ការងារអចិន្ត្រៃយ៍ និង ប្រើប្រាស់កម្លាំង |
| **រយៈពេល** | រយៈពេលខ្លី ឬមិនលើសពី ២ ម៉ោង | រយៈពេលច្រើនម៉ោង ឬស្ទើរតែពេញមួយថ្ងៃ |

[10] ទំព័រទី ២១ - សៀវភៅការងារកុមារនៅប្រទេសកម្ពុជា រៀបរៀងដោយ UCW

| | | |
|---|---|---|
| **ទីកន្លែង** | នៅបរិវេណក្នុងផ្ទះ ជុំវិញផ្ទះ ឬក្នុងភូមិតែមួយ | នៅក្បែរ ឬឆ្ងាយពីផ្ទះ ឬចំណាកស្រុកឆ្ងាយ |
| **ការសិក្សា** | មិនប៉ះពាល់ដល់ការសិក្សា | សិក្សាមិនពេញលេញ ឬមិនបានទៅសិក្សា |
| **សុខភាព** | មិនប៉ះពាល់ដល់សុភាព | ប៉ះពាល់ដល់សុខភាព |
| **សតិបញ្ញា** | មិនប៉ះពាល់ដល់សតិបញ្ញា និងផ្លូវចិត្ត | ប៉ះពាល់ដល់សតិបញ្ញា និងផ្លូវចិត្ត |
| **បង្ខិតបង្ខំ** | គ្មានការបង្ខិតបង្ខំ | រងការគម្រាមកំហែង ឬបង្ខិតបង្ខំ |
| **សុវត្ថិភាព** | មិនបង្កគ្រោះថ្នាក់ | បង្កគ្រោះថ្នាក់ដល់រូបរាងកាយ ឬអាចពិការ |

*(តារាងបង្ហាញពីភាពខុសគ្នារវាង ការងារកុមារ និងពលកម្មកុមារ)*

ក្រៅពីនេះនៅមានលក្ខណៈពិសេស ដែលអាចបែងចែកភាពខុសគ្នារវាងការងារកុមារ និងពលកម្មកុមារបានជាច្រើនទៀត តាមរយៈរូបភាពផ្សេងៗជាការងារកុមារ ប៉ុន្តែការងារទាំងនោះ បានធ្វើអោយបាត់បង់នូវផលប្រយោជន៍របស់កុមារផ្ទាល់។

នៅជំពូកបន្ទាប់ និងធ្វើការបកស្រាយលម្អិតអំពីទម្រង់ការងារកុមារ និងពលកម្មកុមារនីមួយៗ។ បន្ថែមពីលើនេះ ក៏នឹងមានការបង្ហាញអំពីមូលហេតុ និងប្រភពដែលនាំអោយមានពលកម្មកុមារ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការត្រិះរិះពិចារណា ដើម្បីស្វែងរកដំណោះស្រាយ និងឈានទៅរកការលុបបំបាត់ពលកម្មកុមារ។

# ជំពូកទី២
# ទម្រង់នៃការងារកុមារ
# ពលកម្មកុមារ
# មូលហេតុ
# និងប្រភពនៃពលកម្មកុមារ

# ជំពូកទី២

# ទម្រង់នៃការងារកុមារ ពលកម្មកុមារ មូលហេតុ និងប្រភពនៃពលកម្មកុមារ

## ផ្នែកទី១៖ ទម្រង់នៃការងារ និងពលកម្មកុមារ

វាមិនពិបាកទេ ចំពោះការបែងចែក ឬចាត់ចំណាត់ថ្នាក់នៃប្រភេទការងារកុមារ និងពលកម្មកុមារ ដោយហេតុតែប្រភេទនៃការងារ ទម្រង់ និងលក្ខខណ្ឌការងារ អាចបង្ហាញឲ្យយើងបានឃើញយ៉ាងច្បាស់ថាតើមួយណាជាការងារកុមារ ហើយមួយណាជាពលកម្មកុមារ។

ការងារកុមារ គឺជាកិច្ចការងារទាំងឡាយណាដែលមនុស្សមានអាយុក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ត្រូវធ្វើតាមមុខងាររបស់ខ្លួន។ ចំណែកឯ ពលកម្មកុមារ គឺសំដៅលើការងារទាំងឡាយដែលកុមារមានអាយុតិចជាងអាយុអប្បបរមា ១៥ (ដប់ប្រាំ)ឆ្នាំ សម្រាប់ប្រភេទការងារដែលច្បាប់កំណត់។ លើសពីនេះទៅទៀតនោះ ការងារនោះ គឺជាការងារដែលនាំឲ្យប៉ះពាល់ដល់សុខុមាលភាព សុវត្ថិភាព សីលធម៌ ការរីកលូតលាស់ផ្នែកស្មារតី រូបរាងកាយ និងសតិបញ្ញាស្មារតី ការអភិវឌ្ឍជំនាញ ឬការសិក្សាពេញលេញរបស់កុមារ។

ការងារ និងពលកម្មកុមារត្រូវបានបែងចែកជា ៥ ទម្រង់ ដែលរួមមាន៖

- ទម្រង់កិច្ចការងារកំប៉ិចកំប៉ុក
- ការងារស្រាល
- ពលកម្មស្រាល
- ពលកម្មធ្ងន់ធ្ងរ
- ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (ត្រូវបានបែងចេកជា ២ ទៀតគឺ៖ ទម្រង់ធ្ងន់ធ្ងរដោយគ្មានលក្ខខណ្ឌនៃពលកម្មកុមារ និងទម្រង់ប្រកបដោយគ្រោះថ្នាក់នៃពលកម្មកុមារ )។[11]

ចំពោះទម្រង់កិច្ចការងារកំប៉ិចកំប៉ុក និងការងារស្រាល ត្រូវបានថាជាការងារស្របច្បាប់ និងចាត់ចូលជាការងាររបស់កុមារ។ ប៉ុន្តែ ចំពោះទម្រង់ពលកម្មស្រាល ពលកម្មធ្ងន់ធ្ងរ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានចាត់ទុកជាពលកម្មកុមារ ដែលច្បាប់បានកំណត់លក្ខខណ្ឌច្បាស់លាស់ចំពោះទម្រង់នីមួយៗ។

យើងនឹងធ្វើការរៀបរាប់លម្អិតអំពីទម្រង់នីមួយៗនៃការងារកុមារ និងពលកម្មកុមារនៅចំនុចបន្តបន្ទាប់ដែលមានដូចតទៅ៖

### ២.១.១.ទម្រង់ការងារកុមារ

កត្តាសង្គម និងវប្បធម៌នៅក្នុងប្រទេសជាច្រើនក្នុងពិភពលោក ការងារជាច្រើនត្រូវបានគេទទួលយក និងចាត់ទុកជាការងារមានលក្ខណៈជាសង្គម និងលក្ខណៈវប្បធម៌។ គេក៏ចាត់ទុកថាក្នុងលក្ខណៈវិជ្ជមាន និង

[11] ការបែងចែកចំណាត់ថ្នាក់ការងារ និងពលកម្មកុមារដោយអង្គការពលកម្មអន្តរជាតិ (ILO)

ជាប្រភេទការងារដែលមានសុវត្ថិភាព និងសមរម្យ ចំពោះកុមារ ជាពិសេសកុមារីដែលមានតួនាទីក្នុងការធ្វើកិច្ចការងារផ្ទះ តាមលំនាំប្រពៃណី។

ទម្រង់ការងារកុមារ គឺជាការងារដែលមានលក្ខណៈសមស្រប សមាមាត្រទៅនឹងកម្លាំងកុមារ ហើយធានាដល់សុខុមាលភាព និងសុវត្ថិភាពរបស់កុមារផ្ទាល់ ដែលកុមារអាចធ្វើការងារទាំងនោះបាន។ ហើយទម្រង់ការងារកុមារ ត្រូវបានបែងចែកជា ២ គឺ៖ ទម្រង់កិច្ចការងារកំប៉ិកកំប៉ុក និងទម្រង់កិច្ចការងារស្រាល។ ខាងក្រោមនេះនឹងធ្វើការរៀបរាប់លម្អិតអំពីទម្រង់នីមួយៗ។

### ២.១.១.១.ទម្រង់កិច្ចការងារកំប៉ិចកំប៉ុក

ទម្រង់ការងារកំប៉ិចកំប៉ុក ត្រូវបានចាត់ទុកថាជាទម្រង់ការងារមួយដែលកុមារគ្រប់រូបអាចធ្វើបាន ហើយត្រូវបានច្បាប់ប្រពៃណីអនុញ្ញាត។ ការងារកំប៉ិកកំប៉ុក ជាការងារដែលកុមារអាចធ្វើបានដោយខ្លួនឯង ដោយគ្មានការបង្ខិតបង្ខំ មិនទៀងទាត់ ប្រើរយៈពេលខ្លី មានសុវត្ថិភាព មិនប៉ះពាល់ដល់សុខភាព និងការសិក្សាពេញលេញរបស់កុមារ។ ការងារបែបកំប៉ិកកំប៉ុកនេះ ត្រូវបានចាត់ទុកថាជាការងារមូលដ្ឋានដែលកុមារអាចធ្វើបាននៅក្នុងផ្ទះរបស់ខ្លួនបាន ដោយមានការបង្រៀន ប្រៀនប្រដៅ ឬធ្វើការណែនាំដោយអាណាព្យាបាល ឬសមាជិកណាម្នាក់នៅក្នុងគ្រួសារ។ ទម្រង់ការងារកំប៉ិចកំប៉ុកនេះ ជាទូទៅជាការងារដែលចង្អុលបង្ហាញ ឬជាការណែនាំដោយនរណាម្នាក់នៅក្នុងគ្រួសារ ដើម្បីអោយកុមារជាកូនចៅធ្វើ និងជាការរួមចំណែកក្នុងការជួយសមាជិកគ្រួសាររបស់ខ្លួនផង។ ជាឧទាហរណ៍ដូចជា៖ ការប្រើទៅទិញគ្រឿងទេសដើម្បីយកមកធ្វើម្ហូប ការរៀបចំប្រដាប់ប្រដាដែលខ្លួនលេងអោយមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ការរៀបចំកន្លែងគេង ឬបន្ទប់គេង ការជួយរៀបចំអាហារទទួលទាន ។ល។

### ២.១.១.២.ទម្រង់កិច្ចការងារស្រាល

ទម្រង់កិច្ចការងារស្រាល ជាទម្រង់ការងារមួយដែលមានលក្ខណៈប្រហាក់ប្រហែលនឹងទម្រង់ការងារកំប៉ិចកំប៉ុកដែរ ប៉ុន្តែខុសគ្នាត្រង់ថា ទម្រង់ការងារស្រាល ត្រូវធ្វើជាទៀងទាត់ ឬមិនទៀងទាត់ ប្រើពេលវេលាច្រើនជាង មានសុវត្ថិភាព មិនប៉ះពាល់ដល់សុខភាព និងការសិក្សាពេញលេញរបស់កុមារ។ ជាទូទៅ ទម្រង់ការងារស្រាលជាការងារដែលជួយដល់ការអប់រំ ឬបណ្តុះបណ្តាលកុមារសម្រាប់ពេលអនាគត និងជាផ្នែកមួយនៃការរីកចម្រើនក្នុងគ្រួសារផងដែរ។ ទម្រង់ការងារស្រាល ពេលខ្លះជាការងារដែលស្ម័គ្រចិត្តធ្វើដោយកុមារ ពេលខ្លះទៀតជាកាតព្វកិច្ចដែលកុមារត្រូវតែបំពេញ។ ទម្រង់ការងារស្រាលទាំងនោះមានដូចជា៖ ការដាំបាយ ចម្អិនអាហារ ការងារសម្អាតផ្ទះ ការលាងចាន ឬសម្ភារៈផ្ទះបាយ ការបោកគក់សំលៀកបំពាក់របស់ខ្លួន ឬសមាជិកគ្រួសារ និងកិច្ចការងារស្រាលផ្សេងៗទៀតជាដើម ដែលការងារទាំងអស់នេះសុទ្ធតែរួមចំណែកដល់ការអភិវឌ្ឍដល់បំនិននៃការរស់នៅប្រចាំថ្ងៃនៅក្នុងជីវិត ចំណេះដឹង និងជំនាញ ដែលជាផ្នែកមួយ សម្រាប់ភាពរីកចម្រើនដល់កុមារ

នាពេលអនាគត។ ប៉ុន្តែត្រូវប្រាកដថា ការងារទាំងនោះត្រូវធ្វើនៅក្នុងលំនៅដ្ឋានរបស់កុមារនោះផ្ទាល់ ពុំមែនធ្វើនៅលំនៅដ្ឋានរបស់អ្នកដទៃ ដោយតបស្នងជាប្រាក់កម្រៃវិញនោះឡើយ។ ពុំនោះទេវានឹងលែងជាការងារស្រាលតទៅទៀតហើយ វាអាចនឹងត្រូវបានចាត់ចូលជាពលកម្មស្រាលលើកុមារវិញម្តង ។

ជាគោលការណ៍ ទម្រង់ការងារស្រាលដែលស្ថានភាពច្បាប់អនុញ្ញាត គឺជាការងារដែលៈ

- គោរពតាមអាយុអប្បបរមាតាមច្បាប់ សម្រាប់ប្រភេទ និងលក្ខខណ្ឌការងារដែលកុមារត្រូវធ្វើ
- មិនរំខានដល់ការអប់រំរបស់កុមារ
- មិនបង្កគ្រោះថ្នាក់ដល់សុខុមាលភាពរាងកាយ ផ្លូវចិត្ត ឬសីលធម៌របស់កុមារ ដោយសារតែលក្ខខណ្ឌអនុវត្តការងារនោះ។

### ២.១.២.ទម្រង់ពលកម្មកុមារ

ទម្រង់ពលកម្មកុមារ គឺជាទម្រង់មួយ សំដៅលើការប្រើកុមារអោយបម្រើកិច្ចការងារដែលមិនសាកសមឬហួសសមត្ថភាព និងលទ្ធភាពរបស់កុមារ។ ទម្រង់ពលកម្មកុមារ ត្រូវបានអង្គការពលកម្មអន្តរជាតិ(ILO) ធ្វើការចាត់ចំណាត់ថ្នាក់ជា ៣ ពោលគឺៈ ទម្រង់ពលកម្មស្រាល ទម្រង់ពលកម្មធ្ងន់ធ្ងរ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

#### ២.១.២.១.ទម្រង់ពលកម្មស្រាល

ទម្រង់ពលកម្មស្រាល ត្រូវបានគេសម្គាល់ថា ភាគច្រើនជាការងារតាមផ្ទះ ដែលធ្វើនៅក្នុង ឬសម្រាប់គ្រួសារមួយ ឬគ្រួសារច្រើន។ ទម្រង់ពលកម្មស្រាលគ្របដណ្តប់ទៅលើកិច្ចការ ឬសេវាកម្មជាច្រើន ដែលអាចខុសពីប្រទេសមួយ ទៅប្រទេសមួយទៀត អាស្រ័យលើអាយុ ភេទ សញ្ជាតិ បរិបទវប្បធម៌ និងសេដ្ឋកិច្ចនៅកន្លែងដែលកុមារធ្វើការ។ ជាទូទៅទម្រង់ពលកម្មស្រាល កុមារជាអ្នកបម្រើការងារ ឬសេវាកម្មត្រូវបានគេជួលដោយទទួលបានប្រាក់កម្រៃ។ ចំពោះម៉ោងការងារគឺទៀងទាត់ និងប្រចាំ។ ដោយឡែកចំពោះការសិក្សាវិញ អាចរងនូវការប៉ះពាល់បន្តិចបន្តួច ក៏ដោយសារតែរវល់នឹងកិច្ចការងារទាំងនោះ ជាហេតុនាំឲ្យកង្វះពេលមើល ឬរំលឹកមេរៀន ការខកខានទៅសាលាម្តងម្កាល។ ប៉ុន្តែកុមារក៏នៅតែទទួលបានការអប់រំដូចជាកុមារដទៃទៀតផងដែរ។

ទម្រង់ពលកម្មស្រាល ត្រូវបានគេសង្កេតឃើញថា ភាគច្រើនកុមារដែលកំពុងធ្វើការងារទាំងនោះមានអាយុពី ១២ ឆ្នាំឡើង ហើយភាគច្រើនជាកុមារី។ ពួកគេធ្វើការជាធម្មតា ចាត់ទុកថាជាចំណែកនៃការងារប្រចាំថ្ងៃរបស់មនុស្សស្រី ជាអាទិ៍រួមមានៈ ការសម្អាត ការដាំស្លរ ការបោកគក់សំលៀកបំពាក់ និងអ៊ុតសំលៀកបំពាក់ការមើលថែទាំក្មេងតូចៗ ឬមនុស្សចាស់ ឬមនុស្សពិការ ទិញទំនិញ និងការយាមផ្ទះ ជាដើម។ ចំណែកឯកុមារាភាគច្រើនគឺធ្វើការក្រៅផ្ទះច្រើនជាង មានដូចជាៈ ការថែទាំ និងសម្អាតសួនច្បារ បោសសម្អាតទីធ្លា លាងសម្អាតយានយន្ត។ ល ។

ជារឿយៗកុមារដែលកំពុងធ្វើកិច្ចការងារក្នុងទម្រង់ពលកម្មស្រាលនេះ ស្ទើរតែទាំងអស់គឺមិនបានទទួលការអប់រំឡើយ។ ឱកាសទទួលការអប់រំ និងការបន្តការសិក្សា គឺជារឿងលំបាកបំផុតសម្រាប់កុមារ ពីព្រោះតែការងារទាំងអស់នោះ បានរំខានជាប្រចាំលើសមត្ថភាពក្នុងការធ្វើកិច្ចការសាលា ក៏ដូចជាក្លាយជាសិស្សដែលរៀនមិនទាន់គេនៅក្នុងថ្នាក់។ លើសពីនេះទៅទៀតនោះ ភាគច្រើននៃកុមារទាំងនោះ ត្រូវទៅធ្វើការនៅឆ្ងាយពីលំនៅដ្ឋានរបស់ខ្លួន ដោយទៅរស់នៅ ឬស្នាក់អាស្រ័យជាមួយម្ចាស់ផ្ទះផ្ទាល់តែម្តង ដែលជាហេតុនាំអោយបោះបង់ចោលការសិក្សារៀនសូត្ររបស់ខ្លួន។

បន្ថែមពីនេះទៅទៀត ចំពោះសុខភាពរបស់កុមារ ក៏មានការប៉ះពាល់ដល់សុខភាពកុមារផងដែរ ប៉ុន្តែអាចព្យាបាលបាន តាមរយៈការលេបថ្នាំ ព្យាបាលដោយខ្លួនឯង ឬមានគ្រូពេទ្យ ឬការសម្រាកពីការងារអោយបានគ្រប់គ្រាន់។

ជារួម ទម្រង់ពលកម្មស្រាល មានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់ការងារស្រាល ប៉ុន្តែខុសគ្នាត្រង់ថាទម្រង់ពលកម្មស្រាលនេះ កុមារត្រូវធ្វើការទៀងទាត់ ពុំបានទទួលការអប់រំពេញលេញ ប៉ះពាល់ដល់សុខភាពបន្តិចបន្តួចរបស់កុមារ និងផលប៉ះពាល់ផ្សេងៗទៀតផងដែរ។

### ២.១.២.២.ទម្រង់ពលកម្មធ្ងន់ធ្ងរ

ទម្រង់ពលកម្មធ្ងន់ធ្ងរ គឺសំដៅលើស្ថានភាពការងារទាំងឡាយណា ដែលច្បាប់មិនអនុញ្ញាត ចំពោះការងារដែលកុមារធ្វើ ហើយកុមារនោះមានអាយុក្រោមអប្បបរមា ស្ថិតនៅក្នុងលក្ខខណ្ឌគ្រោះថ្នាក់ ឬស្ថិតនៅក្នុងស្ថានភាពដូចទាសករ។ កុមារដែលស្ថិតនៅក្នុងស្ថានភាពនៃទម្រង់ពលកម្មធ្ងន់ធ្ងរ ត្រូវបានគេដកហូតនូវកុមារភាព សក្តានុពល និងសេចក្តីថ្លៃថ្នូរ។[12]

កុមារដែលបម្រើការងារក្នុងទម្រង់ពលកម្មធ្ងន់ធ្ងរ ត្រូវបានច្បាប់ហាមឃាត់ជាដាច់ខាត ដោយសារតែអាយុរបស់កុមារផ្ទាល់ និងផលប៉ះពាល់ជាច្រើនទៀតដោយផ្ទាល់ និងដោយប្រយោល ចំពោះសិទ្ធិរបស់កុមារ និងការអភិវឌ្ឍប្រទេសជាតិ។ សុខុមាលភាព ទាំងរូបរាងកាយ ទាំងផ្លូវចិត្ត ទាំងសីលធម៌របស់កុមារស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ ដោយសារការងារដែលពួកគេធ្វើ និងលក្ខខណ្ឌផ្សេងៗទៀតដែលកុមារធ្វើនោះ។ លើសពីនេះទៅទៀត កុមារដែលធ្វើការទាំងនោះគឺពុំមានឱកាសទទួលការអប់រំរៀនសូត្រដូចកុមារដ៏ទៃទៀតឡើយ។ ពួកគេត្រូវបានគេដកហូតសិទ្ធិក្នុងការទទួលបានការអប់រំ ដែលតម្រូវឲ្យកុមារឈប់រៀនមុនអាយុ និងតម្រូវអោយកុមារធ្វើការងារធ្ងន់ធ្ងរហួសកម្លាំងរបស់កុមារក៏មាន។ កុមារដែលបម្រើការងារក្នុងទម្រង់ពលកម្មធ្ងន់ធ្ងរ ភាគច្រើនត្រូវបានរងផលប៉ះពាល់ដល់ការរីកលូតលាស់រូបរាងកាយ និងបញ្ញាស្មារតី គ្រោះថ្នាក់ដល់សរីរាង្គ ឬផ្នែកណាមួយនៃរាងកាយ ដោយហេតុតែការធ្វើការងារជាមួយគ្រឿងម៉ាស៊ីន នៅតាមសិប្បកម្ម សហគ្រាស ឬឧស្សាហកម្ម ការ

[12] អនុសញ្ញាលេខ ១៨២ របស់អង្គការពលកម្មអន្តរជាតិ (ILO)

ធ្វើការហួសកម្លាំង និងមិនបានទទួលទានអាហារូបត្ថម្ភគ្រប់គ្រាន់ ដែលទ្រទ្រង់ដល់រូបរាងកាយ និងកម្លាំងកំហែងរបស់កុមារ ជាដើម។

ជាធម្មតា កុមារដែលបម្រើការងារក្នុងទម្រង់ពលកម្មធ្ងន់ធ្ងរ ច្រើនតែកើតឡើងនៅក្នុងវិស័យសេដ្ឋកិច្ចមិនរៀបរយ នៅតាមតំបន់ជាយក្រុង/ទីប្រជុំជន នៅតាមតំបន់ជនបទ និងនៅតាមបណ្តាកន្លែងឧស្សាហកម្មនានា ដែលលាក់បាំងភ្នែកសាធារណៈជន។ កុមារទាំងនោះធ្វើការងារប្រកបដោយគ្រោះថ្នាក់ មានហានិភ័យខ្ពស់ មិនស្របច្បាប់ ឬលក្ខខណ្ឌការងារមិនសមស្រប។

ការសិក្សាត្រូវបានធ្វើឡើងនៅកន្លែងជាច្រើននៅក្នុងពិភពលោក រួមទាំងតំបន់អាស៊ីប៉ាស៊ីហ្វិចផងដែរ ដែលបានបញ្ជាក់យ៉ាងច្បាស់ថា ទម្រង់ពលកម្មធ្ងន់ធ្ងរ ដោយមានភាពរីករាលដាលយ៉ាងខ្លាំង ដោយភាគច្រើនខ្លាំងគឺជាការងារដែលធ្វើនៅតាមផ្ទះ ដែលកុមារត្រូវធ្វើការចាប់ពី ១០ ទៅ ១២ ម៉ោងក្នុងមួយថ្ងៃ និងត្រូវធ្វើការពី ៦ ទៅ ៧ ថ្ងៃក្នុងមួយអាទិត្យ។ កុមារពុំមានពេលសម្រាកគ្រប់គ្រាន់ឡើយ ភាគច្រើនសម្រាកបានរយៈពេលខ្លីតែប៉ុណ្ណោះ ពោលគឺនៅក្នុងពេលហូបបាយ ហើយមួយភាគធំគឺមិនមានពេលសម្រាកនោះទេ។ អ្វីដែលគួរអោយអាណិតអាសូរទៀតនោះ កុមារទាំងនោះត្រូវបានគេវាយដំ ឬជេរស្តីនៅពេលបំពេញការងារមិនបានល្អ។ ចំពោះប្រាក់ឈ្នួលរបស់កុមារវិញ កុមារទាំងនោះទទួលបានតិចតួចស្តួចស្តើងតែប៉ុណ្ណោះ។

ចំពោះទម្រង់ពលកម្មធ្ងន់ធ្ងរ មានទំនាក់ទំនងយ៉ាងច្បាស់មួយ អាចឈានទៅដល់ទម្រង់ធ្ងន់ធ្ងរពលកម្មបំផុតនៃពលកម្មកុមារ ករណីដែលកុមាររូបនោះត្រូវបានគេលួងលោម ឬត្រូវបានភ្នាក់ងារទុច្ចរិតចាប់ខ្លួន បន្ទាប់មកទើបធ្វើការជួញដូរ តាមរយៈការលក់ទៅឲ្យអ្នកទិញ ដើម្បីកេងប្រវ័ញ្ចពលកម្មទូទៅ ឬពលកម្មផ្លូវភេទ។

### ២.១.២.៣.ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានគេឲ្យនិយមន័យថា ជាក្រុមពលករកុមារ ឬកុមារ ដែលត្រូវបានគេបំបិទសិទ្ធិសេរីភាព និងទទួលរងនូវការគម្រាមកំហែងដល់សុវត្ថិភាព និងសុខុមាលភាព។ ជាមួយគ្នានេះក៏មានការកំណត់អំពីនិយមន័យជាក់លាក់ផ្សេងទៀតដែរថា ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ជា៖

ក) រាល់ទម្រង់ទាសភាព ឬការអនុវត្តស្រដៀងទាសភាព ដូចជា ការលក់ដូរ ឬជួញដូរកុមារ កញ្ចះដោះបំណុល និងពលកម្មដោយបង្ខំ ឬពលកម្មចាំបាច់ខានពុំបាន ដោយរាប់បញ្ចូលទាំងការជ្រើសរើសដោយបង្ខំ ឬដោយចាំបាច់ខានមិនបានទៅលើកុមារ សម្រាប់ប្រើនៅក្នុងជម្លោះប្រដាប់អាវុធដែរ

ខ) ការប្រើប្រាស់ សញ្ជារកម្ម ឬការផ្តល់កុមារសម្រាប់ពេស្យាចារ្យ សម្រាប់ផលិតភាពយន្តអាសអាភាស ឬសម្រាប់សម្តែងបែបអាសអាភាស

គ) ការប្រើប្រាស់ សញ្ជូរកម្ម ឬការផ្តល់កុមារសម្រាប់សកម្មភាពខុសច្បាប់ ជាពិសេសសម្រាប់ការផលិត ចែកចាយ ប្រើប្រាស់ និងជួញដូរគ្រឿងញៀន ដូចមានកំណត់នៅក្នុងសន្ធិសញ្ញាអន្តរជាតិដែលជាប់ទាក់ទង

ឃ) ការងារដែលមានលក្ខណៈ ឬមានស្ថានភាពទំនងជាធ្វើឲ្យមានការខូចខាតដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់កុមារ នៅពេលដែលកុមារធ្វើការងារដែលមានគ្រោះថ្នាក់នោះ។[13]

ជាមួយគ្នានេះ ក៏មានការបកស្រាយបន្ថែមអំពីអត្ថន័យនៃពលកម្មកុមារផងដែរ ដែលក្នុងនោះមានដូចខាងក្រោម៖

- ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ប្រឆាំងនឹងសិទ្ធិមូលដ្ឋានរបស់មនុស្ស ដូចជាទាសភាពលើកុមារ ឬការអនុវត្តប្រហាក់ប្រហែលទៅនឹងទាសភាព ដូចជាការលក់ និងការជួញដូរកុមារ ការងារដោះបំណុល និងការងារជាខ្ញុំកញ្ជះ ការងារដោយបង្ខំ ឬការងារជាកាតព្វកិច្ច រួមទាំងការជ្រើសរើសកុមារ ដោយបង្ខំ ឬដោយកាតព្វកិច្ច ដើម្បីឲ្យបម្រើក្នុងជម្លោះប្រដាប់អាវុធ ការប្រើប្រាស់កុមារក្នុងការងារប្រើកម្លាំងអូសទាញ ឬពេស្យាកម្ម ការផលិតរូបភាពអាសគ្រាម ឬការសំដែងអាសគ្រាម និងការប្រើប្រាស់កុមារឲ្យបម្រើក្នុងសកម្មភាពខុសច្បាប់ ឬឧក្រិដ្ឋកម្ម ។ សកម្មភាពទាំងអស់នេះ គឺជាអំពើខុសច្បាប់។

- ពលកម្មកុមារនៅក្នុងប្រភេទការងារប្រកបដោយគ្រោះថ្នាក់ ឬនៅក្នុងបរិយាកាសការងារគ្រោះថ្នាក់ អាចប៉ះពាល់ដល់សុខភាព សុវត្ថិភាព និងសីលធម៌របស់កុមារបម្រើការងារ។ ការងារទាំងនេះគឺមិនអនុញ្ញាតឲ្យធ្វើសម្រាប់អ្នកដែលមានអាយុតិចជាង ១៨ ឆ្នាំឡើយ។[14]

កុមារត្រូវបានគេបំបិទសិទ្ធិសេរីភាពស្ទើតែទាំងស្រុង នៅពេលដែលពួកគេបានជ្រុល ធ្លាក់ខ្លួនចូលក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ កុមារទាំងនោះទទួលបានត្រឹមតែអាហារដើម្បីបរិភោគដើម្បីតែរស់ពីមួយថ្ងៃទៅមួយថ្ងៃប៉ុណ្ណោះ ហើយអាហារទាំងនោះទៀតសោត គឺជាអាហារដែលមានអាហារូបត្ថម្ភមិនគ្រប់គ្រាន់ គ្មានប្រាក់ឈ្នួល ឬទទួលបានកម្រៃអ្វីឡើយ។ កុមារដែលស្ថិតនៅក្នុងស្ថានភាពនៃទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ជាទូទៅត្រូវបានគេកេងប្រវ័ញ្ចកម្លាំងពលកម្មហួសហេតុ។ កុមារដែលស្ថិតនៅក្នុងស្ថានភាពបែបនេះ ត្រូវធ្វើការរយៈពេលយូរ (ស្ទើតែពេញមួយថ្ងៃ ក្នុងមួយសប្តាហ៍) ដេកមិនគ្រប់គ្រាន់ និងការនឿយហត់ខ្លាំង។ ហើយដើម្បីប៉ះប៉ូវកម្លាំងឡើងវិញ កុមារត្រូវបានគេបង្ខំអោយប្រើប្រាស់គ្រឿងញៀន ដើម្បីធ្វើការងារទាំងនោះបន្តទៀត។ ក្រៅពីនេះ កុមារទាំងនោះតែងតែទទួលរងនូវផលប៉ះពាល់ដល់សុខភាពខ្លាំងផងដែរ ដោយសារទីតាំងដែលធ្វើ

[13] មាត្រា ៣ នៃអនុសញ្ញាអង្គការពលកម្មអន្តរជាតិ (ILO) លេខ ១៨២

[14] អនុសញ្ញាលេខ ១៨២ អង្គការពលកម្មអន្តរជាតិ (ILO)

ការនោះអាចជារោងចក្រ សហគ្រាសដែលប្រើប្រាស់នូវសារធាតុគីមី ឬសារធាតុពុលផ្សេងទៀត។ លើសពីនេះទៅទៀត កុមារទាំងនោះភាគច្រើនប្រឈមនឹងគ្រោះថ្នាក់ដល់សរីរាង្គកាយ រហូតដល់បាត់បង់អវៈយវៈណាមួយ ឬក្លាយជាជនពិការ ឬធ្ងន់ធ្ងរជាងនេះទៅទៀតរហូតបណ្តាលឲ្យបាត់បង់ជីវិតក៏មាន ព្រោះការងារទាំងនោះត្រូវធ្វើការជាមួយគ្រឿងម៉ាស៊ីនដែលមានគ្រោះហានិភ័យខ្ពស់។ ការងារទាំងនោះ អាចជាកម្មករនេសាទទូកលើសមុទ្រ កម្មករឡឥដ្ឋ កម្មករក្នុងរោងចក្រសិប្បកម្ម-ឧស្សាហកម្ម។ បន្ថែមពីនេះទៀត លក្ខខណ្ឌដែលអាក្រក់ និងធ្ងន់ធ្ងរជាងនេះទៅទៀតនោះ គឺកុមារត្រូវបានគេវាយដំ ប្រើអំពើហិង្សាលើរូបរាងកាយ ឬពាក្យជេរស្តីប្រមាថ និងការរំលោភបំពានផ្លូវភេទថែមទៀតផង ដែលជាហេតុបណ្តាលឲ្យប៉ះពាល់ដល់ផ្លូវអារម្មណ៍របស់កុមារយ៉ាងធ្ងន់ធ្ងរ និងអាចបណ្តាលអោយកុមារក្លាយជាមនុស្សវិកលចរិក ជាដើម។

ខាងក្រោមនេះ ជាទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែលបានកំណត់នៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានច្បាប់ហាមឃាត់ រួមមាន៖

- ទម្រង់ធ្ងន់ធ្ងរបំផុតដោយគ្មានលក្ខខណ្ឌនៃពលកម្មកុមារ មាន ៣ ទម្រង់៖
  - ១- ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
  - ២- ការជួញដូរកុមារ
  - ៣- ការប្រើប្រាស់កុមារក្នុងការផលិត ការធ្វើអាជីវកម្ម និងការជួញដូរគ្រឿងញៀន
- ទម្រង់ប្រកបដោយគ្រោះថ្នាក់នៃពលកម្មកុមារ មាន ១៦ ទម្រង់៖
  - ១- ការងារលីសែង
  - ២- ការងារបម្រើតាមផ្ទះ
  - ៣- ការងាររើសអេតចាយ និងកាកសំណល់ផ្សេងៗ
  - ៤- ការងារនៅក្នុងចម្ការកៅស៊ូ
  - ៥- ការងារនៅក្នុងចម្ការថ្នាំជក់
  - ៦- ការងារនេសាទ
  - ៧- ការងារនៅក្នុងចម្ការកសិ-ឧស្សាហកម្ម
  - ៨- ការងារសំណង់
  - ៩- ការងារក្នុងផលិតកម្មអំបិល និងក្នុងសហគ្រាសផលិតអំបិល
  - ១០- ការងារសិប្បកម្ម និងក្នុងសហគ្រាសធ្វើសិប្បកម្ម
  - ១១- ការងារក្នុងផលិតកម្មគ្រឿងសមុទ្រ
  - ១២- ការងារវាយថ្ម ឥដ្ឋ

១៣- ការងារកាយ និងប្រមូលខ្សាច់ និងថ្ម

១៤- ការងារក្នុងរ៉ែត្បូងថ្ម និងត្បូង

១៥- ការងារក្នុងភោជនីយដ្ឋាន និង

១៦- ការងារជាអ្នកសុំទាន។

ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែលបានកំណត់ខាងលើ ត្រូវបានច្បាប់ហាមឃាត់ និងលុបបំបាត់អោយខានតែបានៅពេលអនាគត។ ចំពោះជនណាដែលបានល្មើស ដោយទទួលកុមារ ឬប្រើអោយកុមារធ្វើការងារទាំងអស់ដែលច្បាប់ហាមប្រាម ជននោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ គឺជាបញ្ហាប្រឈម នឹងចាំបាច់លុបបំបាត់ឲ្យខានតែបានពីព្រោះ៖

- វាប៉ះពាល់ដល់សីលធម៌ ជាពិសេសការងារពាក់ព័ន្ធការជួញដូរគ្រឿងញៀន ការថតរូបអាសអាភាសន៍ ពេស្យាកម្មលើកុមារ ជាដើម
- វារំខានដល់ការអប់រំរបស់កុមារ និងឬសគល់នាំអោយកុមារក្លាយជាអនក្ខរជន
- វាប៉ះពាល់ដល់ការអភិវឌ្ឍន៍ជំនាញ ដែលនាំឲ្យកុមារមិនអាចរកការងារសមរម្យធ្វើបាននៅពេលពេញវ័យ
- វានាំឲ្យមានភាពក្រីក្រ បន្តពីជំនាន់មួយទៅជំនាន់មួយទៀត
- វានាំអោយមានគន្លាតកាន់តែខ្លាំង រវាងអ្នកមាន និងអ្នកក្រ
- វាអាចនាំឲ្យនូវភាពតានតឹង វិបត្តិ និងជម្លោះក្នុងសង្គម។

## ផ្នែកទី២៖ មូលហេតុ និងប្រភពពលកម្មកុមារ

### ២.២.១.មូលហេតុដែលនាំឲ្យមានពលកម្មកុមារ

ពលកម្មកុមារ បានក្លាយជាបញ្ហាសំខាន់មួយក្នុងចំណោមបញ្ហានានានៅក្នុងប្រទេសកម្ពុជា ក្រោយពីរាជរដ្ឋាភិបាលបានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៨២ របស់អង្គការពលកម្មអន្តរជាតិ នៅក្នុងខែតុលា ឆ្នាំ២០០៥។ កង្វល់ដ៏សំខាន់នោះ គឺថាការងារដែលធ្វើដោយកុមារនៅតាមកន្លែងការងារជាប្រភេទការងារធ្ងន់ធ្ងរ និងមានគ្រោះថ្នាក់ បន្ថែមពីលើម៉ោងធ្វើការយូរ ការប៉ះពាល់ដល់ការសិក្សានៅសាលារៀន ជាមួយនឹងការទទួលបាននូវប្រាក់ថ្លៃឈ្នួលទាប ជាដើម។ អាស្រ័យហេតុនេះហើយ ទើបវាមានតម្រូវអោយយើងត្រូវសិក្សាស្វែងយល់ឲ្យបានច្បាស់លាស់ ដើម្បីមានមូលដ្ឋានក្នុងការកំណត់អំពីមូលហេតុ និងប្រភព ដើម្បីរួមចំណែកកាត់បន្ថយនិងឈានទៅរកការបញ្ឈប់បញ្ហាពលកម្មលើកុមារ។

ចំនុចខាងក្រោមនេះ នឹងរៀបរាប់អំពីមូលហេតុចម្បង និងមូលហេតុបន្ទាប់បន្សំផ្សេងទៀត ព្រមទាំងប្រភពនានា ដែលនាំឲ្យមានពលកម្មកុមារ។

**២.២.១.១.មូលហេតុចម្បង**

មានមូលហេតុជាច្រើន ត្រូវបានរកឃើញថាជាឫសគល់ ជាដើមចម ដែលបណ្តាលអោយមានពលកម្មកុមារ ប៉ុន្តែមូលហេតុដែលចម្បងបំផុតមួយនោះគឺបណ្តាលមកពី ភាពក្រីក្រ។ ភាពក្រីក្រនៃគ្រួសារនីមួយៗ ជាហេតុនាំអោយមានតម្រូវការបន្ថែមលើប្រាក់ចំណូលគ្រួសារ។ កុមារដែលប្រឡូកនៅក្នុងពលកម្មកុមារ គឺមកពីក្រុមគ្រួសារដែលរងគ្រោះដោយសារភាពក្រីក្រ គ្មានអនាម័យ និងអាហារូបត្ថម្ភ។ មានការអោយដឹងទៀតថា ការប្រឡូកក្នុងពលកម្មកុមារ គឺជាការសម្រេចចិត្ត របស់ក្រុមគ្រួសារដើម្បីប្រយុទ្ធនឹងភាពក្រីក្រ។ ចំនួនប្រហែលជាពីរភាគបីនៃក្រុមគ្រួសារដែលអោយកុមារប្រឡូកនៅក្នុងប្រភេទខ្លះនៃពលកម្មកុមារ គឺដោយសារបញ្ហាលំបាកផ្នែកសេដ្ឋកិច្ចរបស់គ្រួសារ ហើយប្រហែលជា ៥០% នៃគ្រួសារទាំងនោះមានជំនឿថា កម្រិតជីវភាពរបស់ខ្លួនអាចនឹងជួបបញ្ហា ឬធ្លាក់ចុះ ប្រសិនបើកូនជាកុមាររបស់ពួកគេឈប់ធ្វើការ។[15]

ភាពក្រីក្រមានទំនាក់ទំនងយ៉ាងរឹងមាំ ដោយផ្ទាល់ និងទៅវិញទៅមកទៅនឹងការសិក្សារបស់កុមារ។ ជាបឋមកង្វះថវិការដើម្បីចាយវាយក្នុងការសិក្សា និងនៅសាលារៀន អាចជាកត្តាមួយនាំអោយកុមារចូលប្រឡូកក្នុងពលកម្មកុមារ ក្នុងគោលបំណងដើម្បីស្វែងរកប្រាក់សម្រាប់បន្តការសិក្សារបស់ខ្លួន។ កុមារដែលប្រឡូកក្នុងពលកម្មកុមារ អាចនឹងធ្វើការឈប់រៀននៅពេលអនាគត។ ពួកគេឈប់រៀនដោយស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្ត ដើម្បីរកប្រាក់សម្រាប់គ្រួសារ ឬដើម្បីជួយគ្រួសារ។ ដោយសារតែរំពឹងថា ការរួមចំណែករកប្រាក់ដោយកុមារ ដើម្បីផ្គត់ផ្គង់គ្រួសារបាន ឪពុកម្តាយមួយចំនួនបានបង្ខំអោយកូនរបស់ខ្លួនធ្វើការ ដើម្បីអាចរកប្រាក់សងបំណុល ឬដើម្បីមានប្រាក់គ្រប់គ្រាន់សម្រាប់ចំណាយលើការរស់នៅប្រចាំថ្ងៃ។

ភាពក្រីក្រ នៅតែជាបញ្ហាចោទចំពោះប្រទេសកំពុងអភិវឌ្ឍន៍។ ហេតុនេះហើយ ដើម្បីចិញ្ចឹមជីវិត និងបំពេញកង្វះខាតជីវភាពប្រចាំថ្ងៃខ្លួន កុមារជាច្រើនបាននឹងកំពុងប្រឡូកចូលក្នុងពលកម្មកុមារ។ ពលកម្មកុមារត្រូវបានគេរកឃើញនៅក្នុងវិស័យដែលផលិតផលទាក់ទងនឹងតម្រូវការរបស់មជ្ឈមណ្ឌលមានការរីកចម្រើន ដូចជាវិស័យឡូតដ្ឋ ការផលិតអំបិល ការកែច្នៃត្រី ការដាំដំណាំកៅស៊ូ ចម្ការដាំដំណាំនាំចេញ ការងារអូសរទេះ និងការនេសាទនៅជិតព្រំដែន។ កម្លាំងពលកម្មដែលស្ថិតនៅក្នុងវ័យកុមារ មិនមានជំនាញ ខ្វះការអប់រំ និងខ្វះទំនាក់ទំនងបណ្តាញការងារ ហើយចុងបញ្ចប់នឹងធ្វើការនៅក្នុងវិស័យដែលមិនគួរជាទីពេញចិត្តដូចជា ការដើររើសអេតចាយ ការលីសែងតាមផ្សារ ការដើរលក់ឥវ៉ាន់តាមផ្លូវ ឬការដើរសុំទាន។ កុមារធ្វើការដែលមិនទទួលបានព័ត៌មានត្រឹមត្រូវគ្រប់គ្រាន់ អស់សង្ឃឹមនឹងងាយស្រួលត្រូវបានគេបោកប្រាស់ ជាពិសេសកុមារី ដែលនៅទីបំផុតត្រូវបានជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ។

[15] Cambodia Child Labor Survey របស់អង្គការពលកម្មអន្តរជាតិ

ដូចនេះហើយ វាមានភាពចាំបាច់ណាស់ ក្នុងការកាត់បន្ថយភាពក្រីក្រ ដើម្បីអាចឈានទៅរកការលុបបំបាត់នូវរាល់ទម្រង់នៃពលកម្មកុមារបាន។

### ២.២.១.២.មូលហេតុបន្ទាប់បន្សំ

ក្រៅពីភាពក្រីក្រ ដែលជាមូលហេតុចម្បងនោះ ក៏មានមូលហេតុបន្ទាប់បន្សំផ្សេងៗផងដែរ ដែលមានជាអាទិ៍៖ អំពើហិង្សាក្នុងគ្រួសារ ការញៀនល្បែង ឬប្រើប្រាស់គ្រឿងស្រវឹង កង្វះខាតកម្មករ និងតម្លៃពលកម្មថោកចំពោះកុមារ។ ល ។

បរិយាកាសនៃគ្រួសារអាចជាកត្តាមួយដែលលើកទឹកចិត្តកុមារអោយធ្វើការ ឬរារាំងកុមារអោយទៅធ្វើការឆ្ងាយពីគ្រួសារផងដែរ។ គ្រួសារមួយចំនួនតែងមានអំពើហិង្សាជារឿយៗ។ កុមារជាកូនតែងត្រូវបានគ្រួសាររបស់ខ្លួនវាយដំ និងជេរស្តី ហេតុដូច្នេះហើយ គ្រួសាររបស់ពួកគេពុំមានលទ្ធភាពផ្តល់បរិយាកាសមានសុវត្ថិភាព និងការពារដល់កុមារទេ។ គ្រួសារខ្លះទៀត អាចញៀននឹងល្បែង ឬប្រើប្រាស់គ្រឿងស្រវឹង ដែលជាឬសគល់នាំអោយមានបញ្ហាក្នុងគ្រួសារ ហើយក៏ជាឬសគល់ ដែលនាំអោយកុមារសម្រេចចាកចេញពីគ្រួសារ ដើម្បីរួចផុតពីរឿងរ៉ាវទាំងអស់នោះផងដែរ។ ក្នុងករណីបែបនេះ កុមារអាចត្រូវបង្ខំអោយធ្វើការងារដោយស្ម័គ្រចិត្ត គ្រាន់តែដើម្បីចៀសផុតពីបរិយាកាសគ្រួសារដ៏អាប់អួរ ឬបង្ខំចិត្តទៅរកប្រាក់នៅខាងក្រៅសម្រាប់គ្រួសារ។

ហេតុផលមួយទៀតគឺ កង្វះខាតកម្មករ ដែលសិប្បកម្ម សហគ្រាសត្រូវការយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងសង្វាក់ផលិតកម្មរបស់ខ្លួន ស្របពេលដែលតម្រូវការទីផ្សារកំពុងហក់ឡើងយ៉ាងខ្ពស់នោះ។ កង្វះខាតកម្មករដែលគ្រប់អាយុ ទាមទារអោយមានកម្មករបន្ថែមដើម្បីធ្វើការងារ ជាហេតុនាំអោយមានកុមារក្រោមអាយុ ១៨ ឆ្នាំបានប្រឡូកចូលក្នុងពលកម្មកុមារ ។ ម្យ៉ាងវិញទៀត ពលកម្មកុមារមានតម្លៃទាប។ ពលកម្មកុមារដែលមានតម្លៃទាប នៅក្នុងទីផ្សារការងារ រួមចំណែកដល់ការកើនឡើងនៃចំនួនពលករ និងការជួញដូរកុមារនៅក្នុងផ្នែកផ្សេងៗនៃសេដ្ឋកិច្ច។ ហេតុផលទាំងនេះហើយ បង្ហាញអោយឃើញពីស្ថានភាពដែលម្ចាស់សិប្បកម្ម ឬម្ចាស់កន្លែងធ្វើកាងារនោះ ត្រូវស្វែងរកកម្មករដែលពុំចាំបាច់មានជំនាញ មានតម្លៃពលកម្មទាប ដែលជាកុមារ ងាយស្រួលក្នុងការគ្រប់គ្រង ស្តាប់បង្គាប់ និងពុំមានការការពារសមស្របបាន។

## ២.២.២.ប្រភពនៃពលកម្មកុមារ

### ២.២.២.១.ការបញ្ជាំខ្លួនដោះបំណុល

ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ប្រទេសកម្ពុជាមានការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ចយ៉ាងខ្លាំង និងជាបន្តបន្ទាប់ ហើយជាលទ្ធផលវិស័យសំណង់នៅកម្ពុជា កំពុងមានការកើនឡើងយ៉ាងគំហុក។ ទីក្រុងធំៗបំផុតដូចជានៅក្នុងរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ មានការពង្រីកជាបន្តបន្ទាប់ តាមរយៈការសាងសង់នូវអាគារ

ការិយាល័យ រោងចក្រ អាគារខុនដូរ សំណង់ផ្ទះល្វែង សណ្ឋាគារ និងផ្សារទំនើបជាដើម។[16] គម្រោងទាំងនោះត្រូវការចំនួនឥដ្ឋយ៉ាងច្រើន ហើយមានសិប្បកម្មផលិតឥដ្ឋក្នុងស្រុកជាច្រើន កំពុងត្រូវបានបង្កើតឡើង ដើម្បីផ្គត់ផ្គង់ឥដ្ឋដល់គម្រោងទាំងអស់នោះ។ សិប្បកម្មទាំងនោះ ពឹងផ្អែកលើកម្លាំងពលកម្មរបស់ទាសករសម័យថ្មី គឺសំដៅលើគ្រួសាររបស់មនុស្សពេញវ័យ និងកុមារជាច្រើនជំនាន់ ដែលត្រូវបញ្ចាំខ្លួនក្នុងសិប្បកម្ម ដើម្បីធ្វើការងារដោះបំណុល។

ការបញ្ចាំខ្លួនដោះបំណុល គឺជាស្ថានភាពមួយដែលកើតមានឡើងនៅពេលកម្លាំងពលកម្មរបស់មនុស្សម្នាក់ត្រូវបានប្រើប្រាស់ ដើម្បីធ្វើការទូទាត់សងបំណុល។ ជាទូទៅ កម្មករដែលធ្វើការងារ ដើម្បីដោះបំណុលគឺទទួលបានប្រាក់កម្រៃទាបយ៉ាងខ្លាំង ជាមួយគ្នានោះ ជារឿយៗនាំឲ្យពួកគាត់ជំពាក់បំណុលកាន់តែច្រើន ហើយគ្មានលទ្ធភាពសងបំណុលទាំងនោះវិញទេ។ ការបញ្ចាំខ្លួនដោះបំណុល ជាប្រព័ន្ធមួយដែលជនម្នាក់បញ្ចាំខ្លួនបម្រើគេ ឬស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនណាម្នាក់ទៀត ដែលជនរងគ្រោះមិនអាចសងបំណុលពិតដែលខ្លួនបានជំពាក់។ មានន័យថារូបភាពដែលជនល្មើសបានកេងប្រវ័ញ្ចកម្លាំងពលកម្ម ទៅលើជនរងគ្រោះដោយខុសច្បាប់ ដើម្បីឲ្យបំណុលរបស់ជនរងគ្រោះកាន់តែកើនឡើងៗ មិនអាចមានលទ្ធភាពសងត្រលប់មកវិញបានតាមរយៈការតម្លើងការប្រាក់ ឬតាមរយៈការគម្រាមកំហែងណាមួយ ក្នុងគោលបំណងរក្សាគ្រប់គ្រងជនរងគ្រោះឲ្យធ្វើការនៅកន្លែងខ្លួនជារៀងរហូត។ កត្តាដែលនាំអោយជនរងគ្រោះជំពាក់បំណុលកាន់តែច្រើនឡើងៗ ពីព្រោះដំបូងឡើយ ពួកគេជួបប្រទះទៅនឹងបញ្ហាមួយចំនួនដូចជា ការឈឺថ្កាត់ កង្វះខាតក្នុងការចំណាយផ្សេងៗ គ្មានលទ្ធភាពទិញគ្រាប់ពូជ ឬសត្វពាហនៈ ដើម្បីមកធ្វើស្រែជាដើម។ ហើយខ្លះទៀត ពួកគាត់ភាគច្រើនបានខ្ចីប្រាក់ពីធនាគារ ឬអ្នកចងការប្រាក់នៅតាមមូលដ្ឋាន។ នៅពេលពួកគាត់មិនមានលទ្ធភាពសងប្រាក់ទាំងអស់នោះវិញ ពួកគាត់ត្រូវផ្ទេរបំណុលទាំងអស់នោះទៅឲ្យជនល្មើស ដើម្បីសងជំនួស ហើយសន្យាថានឹងធ្វើការងារ ឬធ្វើអ្វីមួយដើម្បីដោះបំណុលទាំងអស់។

ការបញ្ចាំខ្លួនដោះបំណុល ជាប្រភពមួយនៃពលកម្មលើកុមារ និងជាមធ្យោបាយដែលត្រូវបានប្រើប្រាស់ជាទូទៅដោយម្ចាស់សិប្បកម្ម ដើម្បីទទួលបាននូវកម្លាំងពលកម្មរយៈពេលយូរ មានតម្លៃទាប ចេះស្តាប់បង្គាប់។ កុមារត្រូវបានបង្ខំជាញឹកញាប់ ឲ្យជួយការងាររបស់ឪពុកម្តាយ នៅក្នុងសិប្បកម្មទាំងនោះ ដោយសារតែប្រាក់ឈ្នួលពលកម្មទាប ហើយប្រព័ន្ធនៃការផ្តល់ប្រាក់ឈ្នួលត្រូវគិតតាមចំនួនផលិតកម្ម។ លើសពីនេះទៅទៀត ក្រៅពីលក្ខខណ្ឌការងារមិនសមរម្យ កន្លែងស្នាក់នៅរបស់ពួកគេពុំមានអនាម័យ និងទីតូចចង្អៀតផងដែរ។ កុមារដែលស្ថិតនៅស្ថានភាពនៃការបញ្ចាំខ្លួនដោះបំណុល ត្រូវបានផុងខ្លួនជាកម្មករដែលបម្រើពលកម្មធ្ងន់ធ្ងរ ដោយពុំទទួលបានប្រាក់កម្រៃអ្វីឡើយ ។ ស្ថិតនៅក្នុងស្ថានភាពបែបនេះ ពួកគេបានត្រឹមតែមានកន្លែងស្នាក់នៅ និង

[16] បច្ចុប្បន្នភាពនៃកម្ពុជាផ្នែកវិស័យសំណង់ និងអចលនទ្រព្យ - របាយការណ៍ធនាគារពិភពលោក

ត្រូវក្រោកពីព្រឹកធ្វើការ សម្រាកតែពេលទទួលទានអាហារតែប៉ុណ្ណោះ។ កុមារទាំងនោះ ប្រឈមនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងត្រូវបានបង្ខំឲ្យធ្វើការងារដែលគ្រោះថ្នាក់ និងមិនសមរម្យ។ គ្រោះថ្នាក់តែងកើតឡើងជាញឹកញាប់ ហើយក្នុងករណីខ្លះ មានអ្នករងរបួសធ្ងន់ធ្ងររហូតដល់បាត់បង់អវៈយវៈ និងខ្លះរហូតដល់បាត់បង់អាយុជីវិតក៏មានផងដែរ។

ការបញ្ចាំខ្លួនដោះបំណុល ត្រូវបានច្បាប់អន្តរជាតិ ចាត់ទុកថាជាការអនុវត្តស្រដៀងគ្នាទៅនឹងទាសភាព ហើយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីទម្រង់ទាសភាពសម័យទំនើប ក៏យល់ថានេះ គឺជាទម្រង់មួយនៃទាសភាពសម័យថ្មីផងដែរ។[17]

### ២.២.២.២.ទំនាក់ទំនងរវាងម្ចាស់សិប្បកម្ម និងកម្មករជាកុមារ

ទោះបីជាពួកគាត់បានជួបប្រទះនូវការកេងប្រវ័ញ្ច និងស្ថានភាពជីវិតដ៏លំបាកក្តី ប៉ុន្តែមានកម្មករតិចណាស់ដែលសម្តែងនូវការមិនសប្បាយចិត្ត ឬក៏ទទូចទាមទារឲ្យម្ចាស់សិប្បកម្ម ផ្តល់នូវលក្ខខណ្ឌការងារ ឬសិទ្ធិការងារប្រសើរជាងមុន។ នោះហាក់ដូចជាមកពីពួកគាត់ចាត់ទុកថា ម្ចាស់សិប្បកម្ម ជាម្ចាស់ ជាចៅហ្វាយនាយរបស់ពួកគាត់ ជាជាង និយោជក ហើយចាត់ទុកខ្លួនឯងជាកូនចៅ ជាជាងបុគ្គលិក។ ហេតុដូច្នេះហើយ ទើបពួកគាត់មានការពឹងផ្អែក និងដឹងគុណចំពោះម្ចាស់សិប្បកម្ម។ ពលកម្មកុមារ មានច្រើននៅក្នុងសិប្បកម្មឡឥដ្ឋដែលកុមារទាំងអស់យល់ថា ពួកគេជាផ្នែកមួយនៃសិប្បកម្មឡឥដ្ឋ ដែលជាកន្លែងដែលពួកគេបានរស់នៅជាមួយម្តាយឪពុក តាំងតែពីចាប់កំណើតមកម្លេះ។ កុមារដែលធ្វើការនៅទីនោះ មានអាយុចាប់ពី ៩ ឆ្នាំ រហូតដល់ ១៥ ឆ្នាំ ។ ឪពុកម្តាយរបស់កុមារទាំងនោះ បានលើកឡើងថា កូនៗពួកគាត់បានជួយពួកគាត់ដើម្បីបង្កើនចំណូលសម្រាប់គ្រួសារ។ នេះគឺជាការជម្រុញ និងជាប្រភពដែលនាំអោយកុមារធ្វើការងារដែលស្ថិតនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ នេះក៏ជាកត្តាដែលជម្រុញអោយកុមារធ្វើបែបនោះ ដោយសារតែប្រាក់ឈ្នួលត្រូវទូទាត់ទៅតាមចំនួនផលិតផល អញ្ចឹងកាលណាគ្រួសារពួកគាត់ផលិតបានផលិតផល(ឥដ្ឋ)ច្រើន ពួកគាត់ក៏ទទួលបានចំណូលច្រើនដែរ។ កុមារភាគច្រើនមិនទទួលបានកម្រៃ ពីកម្លាំងពលកម្មរបស់ពួកគេឡើយដែលនេះជាការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ ដែលច្បាប់ហាមប្រាម។ កុមារជួយធ្វើការងារឪពុកម្តាយគេដើម្បីគ្រួសាររបស់ពួកគេមានប្រាក់ទិញម្ហូបអាហារ។ ឪពុកម្តាយរបស់កុមារទាំងនោះ ក៏បានដឹងពីគ្រោះថ្នាក់ការងារនៅក្នុងសិប្បកម្មនោះដែរ ប៉ុន្តែពួកគាត់គ្មានជម្រើស។

បើទោះបីជាពុំមានអ្វីមកបញ្ជាក់ថា កុមារមិនបានបំពេញកាងារទាំងអស់នៅក្នុងសិប្បកម្មឡឥដ្ឋក៏ដោយប៉ុន្តែវាច្បាស់ណាស់ថា កុមារទាំងនោះចូលរួមគ្រប់ដំណាក់កាលនៃការផលិតឥដ្ឋ។ កុមារទាំងនោះត្រូវប្រើពូថៅ

[17] មាត្រា ១ នៃអនុសញ្ញាបំពេញបន្ថែមស្តីពីការលុបបំបាត់ទាសភាព ការជួញដូរទាសភាព ស្ថាប័ន និងការអនុវត្តស្រដៀងទាសភាព ឆ្នាំ ១៩៥៦ របស់អង្គការសហប្រជាជាតិ

និងប៉ែល ដើម្បីជីកដីឥដ្ឋពីពំនូកដី ការលើកដីឥដ្ឋដាក់ចូលក្នុងម៉ាស៊ីនផលិតឥដ្ឋតូច ឬធំ ដឹកដីឥដ្ឋនឹងរទេះឈើ ឬត្រាក់ទ័រ ហាលឥដ្ឋក្រោមកម្ដៅថ្ងៃ ដឹកឥដ្ឋដែលហាលរួចយកទៅដាក់ក្នុងឡឥដ្ឋ ពុសអុសដើម្បីដុតក្នុងឡ បិតមាត់ឡជាមួយនឹងដីឥដ្ឋ និងជញ្ជូនឥដ្ឋចេញពីឡទៅរៀបដាក់លើរថយន្តជាដើម។

ការងារនៅក្នុងសិប្បកម្មឡឥដ្ឋ ពិតជាត្រូវប្រើកម្លាំងខ្លាំងណាស់ ជាពិសេសកុមារផ្ទាល់។ កុមារត្រូវក្រោកនៅម៉ោង ៣ ព្រឹកជារៀងរាល់ថ្ងៃ ដើម្បីជីកយកដី។ ពួកគាត់ធ្វើបែបនេះ ដើម្បីអាចឲ្យគាត់អាចបញ្ចប់ការងារដែលត្រូវប្រើកម្លាំងបែបនេះ មុនពេលថ្ងៃក្ដៅខ្លាំង។ កុមារដែលធ្វើការងារធ្ងន់បែបនេះ មានការលូតលាស់មិនល្អឡើយ ជាពិសេសការលូតលាស់សាច់ដុំខុសពីធម្មតា ជាពិសេសជុំវិញឆ្អឹងខ្នងរបស់ពួកគេ ដែលនេះអាចបណ្ដាលមកពីការធ្វើការងារដោយប្រើកម្លាំងខ្លាំងហួសហេតុ។

### ២.២.២.៣.ការជួញដូរកុមារ

កុមារកម្ពុជា ជាច្រើនត្រូវបានគេជួញដូរ ក្នុងគោលបំណងដើម្បីឲ្យធ្វើការងារក្នុងលក្ខណៈទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ កុមារខ្លះត្រូវបានគេបញ្ជូនទៅឲ្យធ្វើជាអ្នកសុំទាននៅទីក្រុងក្នុងស្រុក រីឯកុមារខ្លះទៀតត្រូវបានគេបញ្ជូនទៅបរទេសជិតខាងដូចជា ប្រទេសថៃ វៀតណាម ជាដើម។ ជាពិសេសនៅក្នុងប្រទេសថៃ ទាំងនៅទីក្រុងធំៗ និងនៅតាមព្រំដែន មានកុមារកម្ពុជា ៨0% ក្នុងចំណោមកុមារដែលកំពុងសុំទាននៅទីនោះ។[18] ដោយឡែកនៅក្នុងប្រទេសវៀតណាម កុមារកម្ពុជាត្រូវបានគេរកឃើញថា ពួកទាំងនោះគេត្រូវបានមនុស្សពេញវ័យបង្ខំអោយដើរលក់ផ្កា ឬដើរសុំទានជាដើម។ មានករណីជាក់ស្ដែង ជនរងគ្រោះមួយរូបត្រូវបានសម្ភាសន៍ដោយបានបញ្ជាក់ថា៖ "គាត់ត្រូវបានគេជួញដូរទៅប្រទេសវៀតណាម និងត្រូវបានគេបង្ខំអោយដើរសុំទាន និងលក់ផ្កាអស់រយៈពេល ៦ ខែ។ ជនល្មើសមានភាពលោភលន់ ចង់បានលុយច្រើន ម្លោះហើយទើបបង្ខំនាង និងមិនអោយហូបបាយគ្រប់គ្រាន់ ដើម្បីអោយគេឃើញថានាងគួរអោយអាណិត។ ជារៀងរាល់ថ្ងៃនាងត្រូវបានគេបង្ខំអោយទៅសុំទានតាំងពីម៉ោង ៥ ព្រឹក រហូតដល់កណ្ដាលយប់"។[19]

មានជនរងគ្រោះផ្សេងទៀត បានលើកឡើងប្រហាក់ប្រហែលនឹងជនរងគ្រោះខាងលើផងដែរ ប៉ុន្តែមានលក្ខណៈអមនុស្សធម៌ជាងនេះទៅទៀត។ កុមារខ្លះត្រូវបានគេបង្ខំអោយប្រើប្រាស់គ្រឿងញៀន និងជួញដូរគ្រឿងញៀនឆ្លងដែន។ ខ្លះទៀតត្រូវបានជនល្មើសកាត់សរសៃដៃ ឬជើង ដើម្បីអោយកុមារទាំងនោះក្លាយជាជនពិការដើម្បីមើលទៅកាន់តែគួរអោយអាណិត និងងាយរកប្រាក់បានច្រើនពីការសុំទាន។ ហើយអ្វីដែលអាក្រក់ជាងនេះ

---

[18] The Global Slavery Index, How many people are in modern slavery in Cambodia, ចូលមើលថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០២០, http://www.globalslaveryindex.org/country/cambodia/ ។

[19] Neth Naro, Human Trafficking in Cambodia: Reintegration of Cambodia illegal migrants from Vietnam and Thailand (Singapore, 2009) 18.

ទៅទៀតនោះ គេជឿថានៅពេលកុមារណាដែលធ្លាក់ខ្លួនឈឺ និងលែងមានផលប្រយោជន៍បន្តទៅទៀតនោះ កុមាររូបនោះអាចនឹងត្រូវបានគេវះកាត់យកសរីរាង្គណាមួយ ជាពិសេសគ្រឿងក្នុង ដើម្បីយកទៅជួញដូរនៅក្នុងទីផ្សារងងឹតផងដែរ ។ កុមារខ្លះទៀត បន្ទាប់ពីលែងមានផលប្រយោជន៍ ត្រូវបានគេយកមកបំបោះបង់ចោល នៅតាមព្រំដែន ហើយត្រូវបានអង្គការក្រៅរដ្ឋាភិបាល និងក្រសួងសង្គមកិច្ចជួយសង្គ្រោះបាន និងស្តារនីតិសម្បទារឡើងវិញ ហើយខ្លះទៀតក៏បាត់បង់ជីវិតក៏មាន។

ការជួញដូរ ជាប្រភពមួយដែលនាំអោយមានការកេងប្រវ័ញ្ចពលកម្មលើកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារតែម្តង។ ហើយវាមានផលវិបាកណាស់ក្នុងការទប់ស្កាត់ ដោយសារតែការជួញដូរមានលក្ខណៈជាបណ្តាញ ស្មុគស្មាញ និងធ្វើឡើងដោយសម្ងាត់ ជាហេតុនាំអោយមានផលវិបាកក្នុងបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសនេះ។

# ជំពូកទី៣
# ច្បាប់ពាក់ព័ន្ធ និង
# ទោសព្រហ្មទណ្ឌ
# ចំពោះពលកម្មកុមារ

# ជំពូកទី៣

# ច្បាប់ពាក់ព័ន្ធ និងទោសព្រហ្មទណ្ឌ ចំពោះពលកម្មកុមារ

## ផ្នែកទី១៖ ច្បាប់ជាតិ និងបទដ្ឋានគតិយុត្តអន្តរជាតិ

### ៣.១.១.ច្បាប់ជាតិ

#### ៣.១.១.១.រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺជាច្បាប់កំពូលសម្រាប់ប្រទេសកម្ពុជា ដែលប្រកាន់នូវរបបប្រជាធិបតេយ្យ ដោយចាប់ផ្តើមបង្កើតលើកដំបូងនៅក្នុងឆ្នាំ១៩៤៧។ បច្ចុប្បន្នកម្ពុជាកំពុងប្រើប្រាស់រដ្ឋធម្មនុញ្ញលើកទី៦ ដែលត្រូវបានអនុម័តដោយសភាធម្មនុញ្ញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយត្រូវបានអតីតព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ប្រកាសអោយប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដែលមានចំនួន ១៦ ជំពូក និង ១៥៨ មាត្រា។ រដ្ឋធម្មនុញ្ញនេះបានកើតឡើងសារជាថ្មីម្តងទៀត បន្ទាប់ពីសង្គ្រាមរ៉ាំរ៉ៃជាច្រើនទសវត្សរ៍ត្រូវបានបញ្ចប់ ក្រោមជំនួបកិច្ចចរចារស្វែងរកសន្តិភាពទីក្រុងប៉ារីស ២៣ តុលា ១៩៩១។ មកទល់នឹងពេលបច្ចុប្បន្ន រដ្ឋធម្មនុញ្ញនេះមានអាយុកាល ២៧ ឆ្នាំហើយ បើគិតត្រឹមឆ្នាំ ២០២០ នេះ។ រដ្ឋធម្មនុញ្ញនេះ បានធ្វើវិសោធនកម្ម ០៨ លើករួចមកហើយ។ លើកទី១ ធ្វើឡើងនៅខែកក្កដា ឆ្នាំ១៩៩៤, លើកទី២ នៅខែមីនា ឆ្នាំ១៩៩៩, លើកទី៣ នៅខែកក្កដា ឆ្នាំ២០០១, លើកទី៤ នៅខែមិថុនា ឆ្នាំ២០០៥, លើកទី៥ នៅខែមីនា ឆ្នាំ២០០៦, លើកទី៦ នៅខែកុម្ភៈ ឆ្នាំ២០០៨ និងលើកទី៧ ខែតុលា ឆ្នាំ២០១៤ គឺធ្វើវិសោធនកម្មមាត្រា៧៦ ដាក់បញ្ចូលច្បាប់ស្តីពីការបោះឆ្នោតទៅជាច្បាប់កំពូលរបស់ជាតិ និងលើកទី៨ នៅខែកុម្ភៈ ឆ្នាំ២០១៨ ដោយបានកែប្រែមាត្រា ៣៤ ថ្មី មាត្រា ៤២ មាត្រា ៥៣ និងមាត្រា ១១៨ ស្តីពីការកំណត់សមាសភាពសមាជិកគណៈរដ្ឋមន្ត្រី។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺជាច្បាប់កំពូលសម្រាប់ប្រទេសកម្ពុជា។ រាល់ច្បាប់ និងសេចក្តីសម្រេចទាំងឡាយរបស់ស្ថាប័ននានារបស់រដ្ឋ ត្រូវស្របទៅនឹងរដ្ឋធម្មនុញ្ញ ជាដាច់ខាត។ ចំណុចសំខាន់ៗបំផុតមួយចំនួនដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញមានដូចជា៖ កម្ពុជាត្រូវគោរពដាច់ខាត នូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ របបប្រជាធិបតេយ្យ សេរី ពហុបក្ស ហើយរដ្ឋធម្មនុញ្ញបានចែងអំពីគោលការណ៍នៃការបែងចែកអំណាចដាច់ដោយឡែកពីគ្នា គឺអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។ លើសពីនេះក៏មានចែងអំពីគោលការណ៍នីតិរដ្ឋ និងអនុម័តសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋផងដែរ។

នៅក្នុងជំពូកទី ៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ កម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង

កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ។[20] កម្ពុជាក៏ធានាថា ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន។ ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ។[21] លើសពីនេះទៅទៀត រដ្ឋរ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារ ជីវិត កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនឱ្យធ្វើឡើយ។ អ្នកដែដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសទៅតាមច្បាប់។ ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ...។[22] រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារ ក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។[23]

ជារួមមក នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា បានទទួលស្គាល់សិទ្ធិកុមារ ជាពិសេសសិទ្ធរស់រានមានជីវិត សិទ្ធិទទួលការអប់រំ សិទ្ធិទទួលបានការគាំពារក្នុងស្ថានភាពសង្គ្រាម ការការពារប្រឆាំងនឹងពលកម្មកុមារ និងអាជីវកម្មលើកុមារ។ ពលកម្មកុមារ គឺជាអំពើផ្ទុយពីបញ្ញត្តិច្បាប់ ដែលបានធ្វើអោយប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់កុមារ ប្រឆាំងការងារទាំងឡាយដែលធ្វើអោយប៉ះពាល់ដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ គប្បីមានចំណាត់ការលើបុគ្គលដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចពលកម្មលើកុមារ។

### ៣.១.១.២.ក្រមព្រហ្មទណ្ឌ

ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័តនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គនៃរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងត្រូវបានព្រះមហាក្សត្រចុះព្រះហស្តលេខា នាថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ក៏ប៉ុន្តែក្រមនេះនៅមិនទាន់អាចយកទៅអនុវត្តបាននោះឡើយទេ ដោយហេតុថា នៅមាត្រាចុងក្រោយបានចែងថា "លើកលែងតែបទប្បញ្ញត្តិទូទៅ បទប្បញ្ញត្តិដទៃទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ ឆ្នាំ

[20] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ

[21] មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញ

[22] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ

[23] មាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញ

ក្រោយការចូលជាធរមាននៃក្រមនេះ"។[24] ក្រោយពីបានចុះផ្សាយនៅក្នុងរាជកិច្ច ក្រមព្រហ្មទណ្ឌថ្មីត្រូវបានចូលជាធរមាននៅភ្នំពេញ នៅថ្ងៃទី១១.ធ្នូ.២០០៩ និងនៅតាមបណ្ដាខេត្ត-ក្រុងផ្សេងទៀត នៅថ្ងៃទី២១.ធ្នូ.២០០៩ ពោលគឺ ១០ថ្ងៃក្រោយពីចូលជាធរមាននៅភ្នំពេញ។ មួយឆ្នាំក្រោយពីចូលជាធរមាន ទើបក្រមថ្មីនេះចាប់ផ្ដើមអនុវត្តបានគឺនៅក្នុងខែធ្នូ.២០១០។ ក្រមព្រហ្មទណ្ឌ បែងចែកជា ៦ គន្ថី និងមានចំនួន ៦៧២ មាត្រា។

ក្រមព្រហ្មទណ្ឌដែលស្គាល់ថាជាច្បាប់សារធាតុនេះគឺជាច្បាប់ដែលបានបញ្ញត្តិកំណត់ទុកជាមុននូវអំពើនៃបទល្មើស ឈ្មោះបទល្មើស និងទណ្ឌកម្មដែលត្រូវផ្ដន្ទាទោសក្នុងបទល្មើសនីមួយៗ មានន័យថាក្នុងក្រមនេះគេកំណត់ឈ្មោះបទល្មើសរួចជាស្រេច ឧទាហរណ៍៖ បទឃាតកម្ម ដូចនេះច្បាប់បានចែងទៀតថាអំពើអ្វីទៅជាបទឃាតកម្មហើយបើជនណាប្រព្រឹត្តបទល្មើសឃាតកម្មនេះត្រូវផ្ដន្ទាទោសដូចម្ដេច?

ជាការពិតណាស់ នៅក្នុងក្រមព្រហ្មទណ្ឌបានកំណត់ទុកជាមុននូវបទល្មើសជាច្រើន ដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ ហើយឈ្មោះនៃបទល្មើស និងទណ្ឌកម្មដែលត្រូវផ្ដន្ទាទោស ព្រមទាំងស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ដោយមូលហេតុនៃអាយុរបស់បុគ្គល ត្រូវបានកំណត់យ៉ាងច្បាស់ទៅតាមបទល្មើសនីមួយៗនោះ។ ក្នុងគន្ថីទី២ នៃក្រមព្រហ្មទណ្ឌ ស្ទើតែគ្រប់មាត្រាច្បាប់ដែលបញ្ញត្តិសុទ្ធតែអាចយកអនុវត្តន៍ ដើម្បីផ្ដន្ទាទោសលើជនល្មើស អាស្រ័យទៅតាមបទល្មើសដែលបានប្រព្រឹត្ត ហើយថាតើជនល្មើសត្រូវទទួលទោសព្រហ្មទណ្ឌពីបទអ្វី និងទទួលទណ្ឌកម្មយ៉ាងដូចម្ដេច គឺវាជាសមត្ថកិច្ចរបស់ស្ថាប័នតុលាការ។

### ៣.១.១.៣.ច្បាប់ស្ដីពីការជួញដូរ[25]

ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានរៀបចំឡើងស្របទៅតាមគោលការណ៍ ដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងផ្អែកលើគោលការណ៍មួយចំនួននៃក្រមព្រហ្មទណ្ឌ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធ ព្រមទាំងសិក្សាស្រាវជ្រាវចេញពីច្បាប់ប្រទេសមួយចំនួនទៀតផង ហើយក៏ផ្អែកលើពិធីសារ កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិនានា ទាក់ទងនឹងស្ត្រី និងកុមារដែលប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នរួចហើយ។

ផ្ដើមចេញពីការយកចិត្តទុកដាក់ និងស្មារតីទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងបន្ថែមទៀតនូវការការពារសិទ្ធិ សេរីភាព និងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ក្រសួងពាក់ព័ន្ធដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានសិក្សាស្រាវជ្រាវលើបទបញ្ញត្តិជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្សនេះ ដើម្បីធ្វើកំណែទម្រង់ច្បាប់ឲ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

[24] មាត្រា ៦៧២ នៃក្រមព្រហ្មទណ្ឌ

[25] ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ច្បាប់នេះអនុវត្តន៍តាមពិធីសារបន្ថែម ដើម្បីទប់ស្កាត់ បង្ក្រាប និងផ្ដន្ទាទោសចំពោះការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ឆ្នាំ២០០០ របស់អង្គការសហប្រជាជាតិ

ដោយសារតែច្បាប់ស្តីពី **ការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស** ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩៩៦ នៅមានចន្លោះខ្វះខាតជាច្រើន ហើយបញ្ញត្តិខ្លះពុំទាន់បានចែងច្បាស់លាស់នៅឡើយ ជាហេតុនាំអោយការអនុវត្តពុំសូវមានប្រសិទ្ធិភាព និងមិនទាន់ទប់ស្កាត់បានទាំងស្រុងនូវបទល្មើសជួញដូរមនុស្ស ដែលជាឧក្រិដ្ឋកម្មឆ្លងដែន និងមានការចាត់តាំង ហេតុនេះទើបកម្ពុជាបានរៀបចំច្បាប់ថ្មីនេះស្តីពី **ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**។ ច្បាប់នេះមានលក្ខណៈលម្អិត និងច្បាស់លាស់ជាងច្បាប់ឆ្នាំ ១៩៩៦ ដែលនឹងអាចឲ្យសមត្ថកិច្ចអនុវត្តន៍ច្បាប់មានភាពទូលំទូលាយក្នុងការអនុវត្តបង្ក្រាបជនល្មើសដែលទាក់ទងរាល់គ្រប់សកម្មភាព នៃអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មលើមនុស្ស។

ច្បាប់នេះ បានដាក់ពិគ្រោះយោបល់ ក្នុងក្រុមការងារ ដែលមានសមាសភាពសុទ្ធតែ ចៅក្រម ព្រះរាជអាជ្ញា ជំនាញការជាតិ និងអន្តរជាតិ និងបានពិនិត្យផ្ទៀងផ្ទាត់ ជាមួយនឹងពិធីសារអង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលកម្ពុជាបានផ្តល់សច្ចាប័ននោះ។ មិនតែប៉ុណ្ណោះក៏បានដាក់ឲ្យពិភាក្សា និងផ្តល់មតិយោបល់ក្នុងអង្គសិក្ខាសាលា ដែលមានការចូលរួមពីតំណាងស្ថាប័នរដ្ឋ ស្ថាប័នអង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងតំណាងគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភាផងដែរ។[26]

ច្បាប់នេះត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ៣ មានចំនួន ៩ ជំពូក និងចំនួន ៥២ មាត្រា។ គោលបំណងនៃច្បាប់នេះ គឺបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីការពារសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងបង្កើននូវសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ និងរក្សាការពារ លើកកម្ពស់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អរបស់ជាតិ និងមានគោលបំណងអនុវត្តន៍ឲ្យបានសមស្របផងដែរ តាមពិធីសារអង្គការសហប្រជាជាតិស្តីពី ការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋសង្គ្រាមឆ្លងដែន ឬឧបករណ៍ ឬកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀត ទាក់ទងនឹងការជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ឬចុះហត្ថលេខា។[27]

ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទនេះ បានកំណត់ពីបទល្មើសជាច្រើន ដោយមានមាត្រាចំនួន ៣០ ក្នុងច្បាប់នេះចែងច្បាស់ពីបទល្មើសព្រហ្មទណ្ឌដែលជនល្មើសត្រូវប្រឈមមុខ និងទទួលខុសត្រូវតាមផ្លូវច្បាប់។

[26] ចំណាប់អារម្មណ៍របស់ ឯកឧត្តម អង្គ វង្ស វឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨

[27] មាត្រា ១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

#### ៣.១.១.៤.ច្បាប់ស្តីពីការងារ

ច្បាប់ស្តីពីការងារ របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាអនុម័ត កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ ដែលមាន ១៩ ជំពូក និង ៣៩៦ មាត្រា។ ច្បាប់ស្តីពីការងារ របស់ព្រះរាជាណាចក្រកម្ពុជា មានចែងនូវបទបញ្ញត្តិស្តីអំពីពលកម្មកុមារផងដែរ ក្នុងគោលបំណងការពារកុមារ ពីការកេងប្រវ័ញ្ច និងការការពារពីការងារប្រកបដោយគ្រោះថ្នាក់ ដូចជាការងារនៅលើទូកនេសាទ ការងារនៅ តាមសិប្បកម្មឡឥដ្ឋ ឬនៅតាមសិប្បកម្ម សហគ្រាសផ្សេងៗទៀត។ ច្បាប់ស្តីពីការងារ បានចែងថា៖ អាយុអប្ប បរមា ដែលអាចធ្វើការងារក្នុងស្ថានភាពគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាព គឺអាយុ ១៨(ដប់ប្រាំបី)ឆ្នាំ។[28] នេះមានន័យន័យថា កុមារដែលមានអាយុក្រោម ១៨ ឆ្នាំ មិនត្រូវអនុញ្ញាតអោយធ្វើការដែលប្រកបដោយគ្រោះ ថ្នាក់ទាំងនោះឡើយ។ ដូចនេះ ចំពោះការងារដែលប្រកបដោយគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាពចំពោះ មនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ គឺជាបទល្មើស។ នេះមិនទាន់គិតអំពីថិរវេលានៃការងារ ម៉ោងធ្វើការ ម៉ោងសម្រាក សិទ្ធិ និងផលប្រយោជន៍ផ្សេងៗដែលត្រូវទទួលបាន។ ប្រសិនបើកុមារដែលត្រូវបានគេកេងប្រវ័ញ្ច កម្លាំងពលកម្មនោះ មានន័យថាជនល្មើស បានប្រព្រឹត្តផ្ទុយពីបញ្ញាត្តិច្បាប់ទាំងស្រុងតែម្តង។

ជាការពិតណាស់ ចំពោះប្រទេសកម្ពុជា មិនអនុញ្ញាតឲ្យមានពលកម្មលើកុមារឡើយ។ នៅក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៨២ របស់អង្គការពលកម្ម អន្តរជាតិ ដែលមានការហាមប្រាម ធ្វើការហាមឃាត់ និងលុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារជា បន្ទាន់។[29] អនុសញ្ញានេះបានចាត់ទុកការងារទាំងឡាយ ដែលប្រកបដោយគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិ ភាពរបស់កុមារ ជាទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

### ៣.១.២)បទដ្ឋានគតិយុត្តអន្តរជាតិ

#### ៣.១.២.១.សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ មហាសន្និតបាតអង្គការសហប្រជាជាតិ បានប្រកាសជាសាធារណៈថាសេចក្តី ប្រកាសជាសកលនេះ គឺជា "ឧត្តមគតិរួមដែលប្រជាពលរដ្ឋគ្រប់ៗប្រទេស និងប្រជាជាតិទាំងអស់ត្រូវធ្វើឲ្យបាន សម្រេច" សេចក្តីប្រកាសជាសកលនេះចែងអំពីទស្សនៈរួមមួយ ស្តីអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ទាំងឡាយ ដែលរដ្ឋជាសមាជិកបានប្តេជ្ញាចិត្តអនុវត្តន៍បញ្ញត្តិនៃធម្មនុញ្ញសហប្រជាជាតិឲ្យបានសម្រេច។

[28] មាត្រា ១៧៧ នៃច្បាប់ស្តីពីការងារ

[29] អនុសញ្ញាលេខ ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ១៩៩៩ របស់អង្គការពលកម្មអន្តរជាតិ

សេចក្តីប្រកាសជាសកលនេះ ទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិសេរីភាព និងសិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបានរបស់មនុស្សជាតិទាំងអស់ ដោយគ្មានការបែងចែក។ រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ សេចក្តីប្រកាសនេះបានទទួលកម្លាំងខាងសីលធម៌មួយដែលមិនអាចវាស់វែងបាន។ សេចក្តីប្រកាសនេះភ្ជាប់កាតព្វកិច្ចខាងផ្លូវច្បាប់នៅក្នុងប្រទេសកម្ពុជា ដោយមានបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ផងដែរ។[30]

ការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ គឺជាការរំលោភបំពានលើសិទ្ធិមនុស្ស ជាពិសេសសិទ្ធិរបស់កុមារផ្ទាល់ ដូចមានបញ្ញត្តិនៅក្នុងសេចក្តីថ្លែងការជាសកលស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានបកប្រែបញ្ចូលក្នុងឯកសារច្បាប់ និងសេចក្តីប្រកាសជាសកល ដែលរួមមានសន្ធិសញ្ញាអន្តរជាតិ និងអនុសញ្ញាអន្តរជាតិផ្សេងៗ។

### ៣.១.២.២.អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ

អនុសញ្ញាស្តីពីសិទ្ធិកុមារ គឺជាសន្ធិសញ្ញាអន្តរជាតិ ដែលមានចែងពីបទដ្ឋានអប្បបរមាជាសកល និងពីគោលការណ៍សីលធម៌សម្រាប់ការប្រព្រឹត្តលើកុមារនៅក្នុងសង្គម។ អនុសញ្ញានេះ គឺជាសេចក្តីថ្លែងលម្អិតមួយពីសិទ្ធិទាំងឡាយ ដែលកុមារគ្រប់ទិសទីត្រូវទទួលបាន ហើយរួមបញ្ចូលសិទ្ធិពលរដ្ឋ នយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ដែលពាក់ព័ន្ធនឹងកុមារ។

នៅក្នុងអតីតកាល កុមារត្រូវបានគេចាត់ទុកថាគ្រាន់តែជាអ្នករងអំពើ ឬកម្មវត្ថុដែលគេប្រព្រឹត្តលើតែប៉ុណ្ណោះ។ ប៉ុន្តែឥលូវនេះ អនុសញ្ញាអន្តរជាតិស្តីពីកុមារ ទទួលស្គាល់កុមារថាជាមនុស្សដែលមានសិទ្ធិរបស់គេផ្ទាល់ គឺជាសិទ្ធិកុមារទទួលបានអាស្រ័យដោយគេកើតជាមនុស្ស។ កុមារអាចទាមទារសិទ្ធិរបស់ខ្លួនពីអ្នកមានភារកិច្ចនានា ដូចជាឳពុកម្តាយ និងរដ្ឋ ជាពិសេសមន្ត្រីនគរបាល និងតុលាការដែលមានភារកិច្ចគោរព ការពារ និងបំពេញតាមសិទ្ធិរបស់កុមារ។

អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៦ ហើយព្រះរាជាណាចក្រកម្ពុជា បានចូលជារដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩២ ដោយប្តេជ្ញាបំពេញតាមសិទ្ធិនានារបស់កុមារទាំងអស់នៅកម្ពុជា និងការពារជាដាច់ខាតនូវការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ។

ហេតុដូច្នេះ ការកេងប្រវ័ញ្ចគ្រប់ទម្រង់លើកុមារ រួមទាំងការកេងប្រវ័ញ្ចពលកម្មលើកុមារផងនោះ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិរបស់កុមារ ក៏ដូចជាអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារនេះ។

[30] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ

### ៣.១.២.៣.អនុសញ្ញាស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

អនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៩ នៅទីក្រុងហ្សឺណែវ។ ហើយត្រូវបានរដ្ឋសភាអនុម័តយល់ព្រមលើអនុសញ្ញានេះ កាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ នាសម័យប្រជុំសភាលើកទី៣ នីតិកាលទី ៣។

អនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនេះ មានគោលបំណងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារប្រកបដោយប្រសិទ្ធភាពតម្រូវអោយមានសកម្មភាពបន្ទាន់ និងទូលំទូលាយ ដែលនឹងយកចិត្តទុកដាក់នូវសារៈសំខាន់នៃការអប់រំជាមូលដ្ឋានដោយឥតគិតថ្លៃ និងសេចក្តីត្រូវការ ដើម្បីដកយកកុមារពាក់ព័ន្ធចេញពីកន្លែងធ្វើការងារ និងដើម្បីផ្តល់អោយពួកគេនូវការស្តារនីតិសម្បទារ និងការធ្វើសមាហរណកម្មនៅក្នុងសង្គម។

## ផ្នែកទី២៖ ទោសព្រហ្មទណ្ឌ និងទណ្ឌភាព និងដំណោះស្រាយ ចំពោះពលកម្មកុមារ

### ៣.២.១.ទោសព្រហ្មទណ្ឌ ចំពោះពលកម្មកុមារ

ទោសព្រហ្មទណ្ឌ គឺសំដៅដល់ទណ្ឌកម្ម ដែលត្រូវប្រកាសដោយតុលាការ សម្រាប់អនុវត្តន៍ចំពោះបុគ្គលដែលប្រព្រឹត្តបទល្មើស (ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត) ដែលជាតួអង្គដ៏សំខាន់ក្នុងការប្រព្រឹត្តបទល្មើស។ ទោសព្រហ្មទណ្ឌត្រូវបានតុលាការយកទៅអនុវត្តន៍ចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលដែលជាប្រធាននៃបទល្មើស ឲ្យស្របតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថាបុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌ តែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ។

ដូចគ្នានេះដែរ ករណីដែលរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានប្រព្រឹត្តអំពើណាមួយដែលជាការកេងប្រវ័ញ្ចពលកម្មលើកុមារ ហើយច្បាប់បានកំណត់ថាវាជាបទល្មើស បុគ្គលនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដែលបានចែង។ លក្ខណៈពិសេសនៃទោសព្រហ្មទណ្ឌ គឺសម្រាប់អនុវត្តចំពោះរូបវន្តបុគ្គល និងនីតិបុគ្គល ដែលមានទោសពន្ធនាគារ ទោសពិន័យ និងទោសបន្ថែមមួយចំនួន ព្រមទាំងទោសជំនួសដែលមានចែងកំណត់នៅក្នុងក្រមព្រហ្មទណ្ឌជាធរមាន។

រូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តី កាលណាបើបានប្រព្រឹត្តបទល្មើស ដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចពលកម្មកុមារ នឹងត្រូវទទួលទោសតាមផ្លូវច្បាប់ អាស្រ័យទៅលើអំពើល្មើសដែលខ្លួនបានប្រព្រឹត្ត និងព្យសនកម្មដែលកុមារបានរងគ្រោះ ហើយច្បាប់ក៏មានចែងថាជាបទល្មើស។ ខាងក្រោមនេះ គឺជាទោសព្រហ្មទណ្ឌ ចំពោះពលកម្មកុមារ ដែលអនុវត្តចំពោះរូបវន្តបុគ្គល និងនីតិបុគ្គល។

### ៣.២.១.១)ទោសអនុវត្តន៍ចំពោះរូបវន្តបុគ្គល

រូបវន្តបុគ្គល គឺជាបុគ្គលម្នាក់ៗ ដែលមានជីវិតពិត ផ្ទុយអំពី នីតិបុគ្គល ។[31] ម្យ៉ាងទៀតរូបវន្តបុគ្គល គឺជាមនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល។[32] ប្រភេទនៃទោសដែលអនុវត្តចំពោះរូបវន្តបុគ្គល រួមមាន៖ មូលទោស ទោសបន្ថែម និងទោសជំនួស។ មូលទោស គឺជាទោសដាក់ពន្ធនាគារ និងទោសពិន័យ ។[33] ទោសពិន័យជាប្រាក់ ត្រូវគិតជាប្រាក់រៀល។ មូលទោសនេះ ជាទោសមូលដ្ឋាន ដើម្បីប្រកាសទោសចំពោះជនជាប់ចោទ ដែលប្រព្រឹត្តបទល្មើស។ ម្យ៉ាងទៀត មូលទោស សំដៅទៅដល់ទោសចម្បងជាងគេ ដែតុលាការអាចប្រកាសទោសតែឯង ដើម្បីផ្តន្ទាទោសចំពោះបទល្មើសណាមួយ។ ឯទោសបន្ថែម គឺជាអនុទោស ឬទោសបន្ទាប់បន្សំ ដែលត្រូវបន្ថែមពីលើមូលទោស។[34] ទោសបន្ថែមនេះ គឺត្រូវបានបង្កើតឡើង ក្នុងគោលបំណងឲ្យការដាក់ទណ្ឌកម្ម មានកម្រិតសមស្របនឹងអំពើល្មើសដែលបានប្រព្រឹត្ត។ ចំណែកឯទោសជំនួសវិញ គឺជាទោសប្រកាសជំនួសមូលទោស និងសម្រាប់អនុវត្តជំនួសមូលទោស។ ក្នុងន័យនេះ ចំពោះរូបវន្តបុគ្គលដែលបានប្រព្រឹត្តបទល្មើស ជាពិសេសបទល្មើសពាក់ព័ន្ធទៅនឹងពលកម្មលើកុមារ រូបវន្តបុគ្គលនោះ ត្រូវទទួលទោសទណ្ឌទៅតាមផ្លូវច្បាប់ អាស្រ័យលើអំពើដែលប្រព្រឹត្ត។

❖ **ក្រមព្រហ្មទណ្ឌ**

ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានដើរតួយ៉ាងសំខាន់ ជុំវិញបទល្មើសទាំងឡាយនៃការកេងប្រវ័ញ្ចមនុស្ស ជាពិសេសកុមារ ដែលមានកំណត់នៅក្នុងស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ដោយមូលហេតុនៃអាយុរបស់បុគ្គល នៃមាត្រាភាគច្រើនដែលមាននៅក្នុងក្រមព្រហ្មទណ្ឌ។ មានបទល្មើសមួយចំនួនដែលមានចែងដូចគ្នា ទាំងក្នុងក្រមព្រហ្មទណ្ឌ និងទាំងក្នុងច្បាប់ពិសេស ដែលការពារពីការកេងប្រវ័ញ្ចពលកម្មកុមារ។ បើទោះបីជាឈ្មោះនៃបទល្មើស ត្រូវបានបញ្ញត្តិខុសគ្នាពីច្បាប់ពិសេសក៏ដោយ ប៉ុន្តែបទបញ្ញត្តិទាំងនោះនៅតែអាចយកមកប្រើប្រាស់ ក្នុងការផ្តន្ទាទោសជនល្មើសបានដដែល។

ខាងក្រោមនេះ ជាមាត្រាពាក់ព័ន្ធមួយចំនួន ដែលអាចយកមកផ្តន្ទាទោស ជនល្មើសដែលបានកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ឬប្រើទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដោយពឹងផ្អែកលើធាតុផ្សំនៃបទល្មើស រួមទាំងព្យសនកម្មដែលកុមារជាអនីតិជនរងគ្រោះ ដែលមានដូចតទៅ៖

យើងបានដឹងរួចមកហើយថា ជនរងគ្រោះនៃទម្រង់ពលកម្មធ្ងន់ធ្ងរ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលភាគច្រើនលើសលុប គឺជាកុមារ ដែលមានអាយុក្រោម ១៨ ឆ្នាំ។ កុមារទាំងនោះ ត្រូវបានដកយក

[31] សន្ទានុក្រមពាក្យច្បាប់ នៃក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀង ១៩៩

[32] សន្ទានុក្រមពាក្យច្បាប់ នៃក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧ លេខរៀង ១២៧

[33] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ

[34] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌ

ក្នុងគោលបំណង ដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្ម។ នៅក្នុងក្រមព្រហ្មទណ្ឌ មិនបានបញ្ញត្តិថា ការដកយកជនរងគ្រោះនៅក្នុងគោលបំណងអ្វីមួយ ឬក្នុងគោលបំណងសម្រាប់កេងប្រវ័ញ្ចកម្លាំងពលកម្មឡើយ ប៉ុន្តែអោយតែជនល្មើសធ្វើការដកយកជនរងគ្រោះជាកុមារចេញដោយខុសច្បាប់ គឺជាលក្ខខណ្ឌគ្រប់គ្រាន់ សម្រាប់ចោទប្រកាន់ដាក់បន្ទុក។ នៅក្នុងមាត្រា ៣២៧ **បទដកយកអនីតិជន** បានចែងថា៖ «អំពើដកយកអនីតិជន ដោយផ្ទុយច្បាប់ ពីបុគ្គលដែលថែរក្សាស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១(មួយ) ខែ ទៅ ១(មួយ) ឆ្នាំ និងពិន័យជាប្រាក់ ពី ១០០,០០០(មួយសែន)រៀល ទៅ ២,០០០,០០០ (ពីរលាន)រៀល។

បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី ២,០០០,០០០(ពីរលាន)រៀល ទៅ ៦,០០០,០០០ (ប្រាំមួយលាន)រៀល ប្រសិនបើអនីតិជនត្រូវបានរក្សាទុកនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។»

ពាក្យថាផ្ទុយច្បាប់ពីបុគ្គលដែលថែរក្សាស្របច្បាប់ មានន័យថា ជនល្មើសដកយកអនីតិជន ចេញដោយមិនមានសមត្ថកិច្ចស្របច្បាប់ ឬច្បាប់មិនបានអនុញ្ញាត ឲ្យទទួលយកអនីតិជននោះ ពីអ្នកថែរក្សាស្របច្បាប់ ដូចជា ឪពុកម្តាយ អាណាព្យាបាល ឬពីកន្លែងថែរក្សាកុមារកំព្រាជាដើម។

ចំពោះក្រមព្រហ្មទណ្ឌក៏មានចែងផងដែរអំពី លក្ខខណ្ឌការងារប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ជាក់ស្តែង **បទដាក់ឲ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស** បានកំណត់ថា៖

អំពើដែលដាក់បុគ្គលណាម្នាក់ ដោយរំលោភលើភាពទន់ខ្សោយ ឬលើស្ថានភាពនៃអនិស្សរភាពរបស់បុគ្គលនោះ ឲ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យប្រាក់ពី ១០០,០០០(មួយសែន)រៀល ទៅ ២,០០០,០០០ (ពីរលាន)រៀល។[35] ក្នុងន័យនេះ ចំពោះកុមារដែលត្រូវបាននិយោជក ឬម្ចាស់សិប្បកម្ម បានកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ ដែលជាលក្ខខណ្ឌការងារមួយ ដែលបានបង្កអោយប៉ះពាល់ដល់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់កុមារ នោះនិយោជក ឬម្ចាស់សិប្បកម្មនោះ ត្រូវមានទោស និងត្រូវទទួលទណ្ឌកម្មដែលបានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌជាដាច់ខាត។

ដើម្បីថែរក្សាជនរងគ្រោះ កុំឲ្យមានការរត់គេច ឬបានលាក់បាំងពីមន្ត្រីមានសមត្ថកិច្ច នោះជនល្មើសបានប្រើវិធីឃុំឃាំងជនរងគ្រោះនៅកន្លែងងងឹត ស្ងាត់ ដែលជនរងគ្រោះជាកុមារមិនអាចរើបំរាស់បាន។ ការឃុំឃាំងជនរងគ្រោះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ដូចដែលមានចែងក្នុងមាត្រា ២៥៣ ពី បទចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ នៃក្រមព្រហ្មទណ្ឌ។

[35] មាត្រា ២៧៤ នៃក្រមព្រហ្មទណ្ឌ

«បុគ្គលដែលចាប់ ដែលឃុំឃាំង ឬដែលបង្ខាំង បុគ្គលផ្សេងទៀត ដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក្រៅករណីដែលច្បាប់អនុញ្ញាត ត្រូវផ្តន្ទាទោស៖

១- ដាក់ពន្ធនាគារ ពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ បើការចាប់ ការឃុំឃាំង ឬដែលបង្ខាំងខ្លួន មានរយៈពេលតិចជាង ៤៨ (សែសិបប្រាំបី) ម៉ោង។

២- ដាក់ពន្ធនាគារ ពី ៣(បី)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ បើការចាប់ ការឃុំឃាំង ឬដែលបង្ខាំងខ្លួន មានរយៈពេលតិចជាង ៤៨ (សែសិបប្រាំបី) ម៉ោង ដល់តិចជាង ១ (មួយ) ខែ។

៣- ដាក់ពន្ធនាគារ ពី ៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ បើការចាប់ ការឃុំឃាំង ឬដែលបង្ខាំងខ្លួន មានរយៈពេលស្មើ ឬលើសពី ១ (មួយ) ខែ។»

លើសពីនេះទៅទៀត ការកេងប្រវ័ញ្ចពលកម្ម ដូចជាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដោយបង្ខំអោយបម្រើសេវាកម្ម ដើរសុំទាន ដើរលក់ផ្កា ជាពេស្យាចារ ដោយប្រើទារុណកម្ម ឬប្រើអំពើឃោរឃៅ ជនល្មើសអាចត្រូវជាប់ជាប់ពី **បទទារុណកម្ម និងអំពើឃោរឃៅ** និង **ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** ដូចមានចែងក្នុងមាត្រា ២១០ «ទារុណកម្ម និងអំពើឃោរឃៅ ដែលប្រព្រឹត្តលើបុគ្គលណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ» និងមាត្រា ២១១ «បទឧក្រិដ្ឋដែលមានចែងក្នុងមាត្រា ២១០ កថាខណ្ឌទី១ (ទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់)ឆ្នាំ ទៅ ២០ (ម្ភៃ)ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើបុគ្គល ដែលទន់ខ្សោយពិសេស ដោយសារមូលហេតុអាយុនៃបុគ្គលនោះ ។ ត្រង់ចំនុចនេះ កាលណាបើជនល្មើសបាន ប្រព្រឹត្តអំពើខាងលើ នោះជនល្មើសត្រូវទទួលខុសត្រូវចំពោះក្រមព្រហ្មទណ្ឌ។»

ជាមួយគ្នានេះ ការកេងប្រវ័ញ្ចពលកម្មលើកុមារ អាចស្ថិតនៅក្រោមរូបភាពកេងប្រវ័ញ្ចកម្លាំងផ្លូវភេទ ឬសញ្ជារកម្មផងដែរ ដែលក្រមព្រហ្មទណ្ឌក៏មានកំណត់ថាជាបទល្មើស។ សញ្ជារកម្ម ជាបទល្មើសធ្វើអោយប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សហួសហេតុ ដោយធ្វើការដឹកនាំឲ្យមានជនរងគ្រោះ ទៅបម្រើសេវាកម្មផ្លូវភេទទៅកាន់អតិថិជន ហើយរង់ចាំទទួលប្រាក់កម្រៃពីអតិថិជន តាមរយៈការបើកជាទីកន្លែងកំសាន្តសប្បាយៗដូចជា៖ ខារ៉ាអូខេ ក្លឹប រង្គសាល ឬកន្លែងម៉ាស្សា កោសជប់ជាដើម ដោយបង្កប់នូវសកម្មភាពសញ្ជារកម្ម ។ នៅក្នុងមាត្រា ២៨៥ បទសញ្ជារកម្ម នៃក្រមព្រហ្មទណ្ឌ បានផ្តល់និយមន័យ និងការផ្តន្ទាទោសយ៉ាងច្បាស់ដែលមានខ្លឹមសារថា៖

សញ្ជារកម្ម គឺជាអំពើ៖

១- ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុ ពីអំពើពេស្យាចាររបស់អ្នកដ៏ទៃ។

២- ជួយឬការពារអំពើពេស្យាចាររបស់អ្នកដ៏ទៃ ឬរៀបចំតាមគ្រប់មធ្យោបាយនូវសកម្មភាពពេស្យាចារ។

៣- ជ្រើសរើស ពង្រត់ ឬអូសទាញបុគ្គលណាមួយឲ្យធ្វើអំពើពេស្យាចារ។

៤- ការគាបសង្កត់ លើបុគ្គលណាមួយ ដើម្បីឲ្យបុគ្គលនោះធ្វើពេស្យាចារ។

៥- សញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤,០០០,០០០(បួនលាន)រៀល ទៅ១០,០០០,០០០(ដប់លាន)រៀល។

អំពើអូសទាញផលប្រយោជន៍ពេស្យាចារ ពីជនដ៏ទៃបាន ភាគច្រើនមិនមែនកើតចេញពីការស្ម័គ្រចិត្តពីជនរងគ្រោះនោះទេ ភាគច្រើននៃពួកគេក្លាយខ្លួនជាពេស្យាចារ និងបម្រើការក្នុងគ្រឹះស្ថានពេស្យាចារ តាមរយៈការបង្ខិតបង្ខំ និងឈានទៅដល់ការប្រើទារុណកម្ម និងអំពើឃោឃៅផ្សេងៗទៀតទៅលើជនរងគ្រោះ ដើម្បីអោយពួកគេព្រមទទួលបម្រើសេវាកម្មផ្លូវភេទ។

នៅក្នុងក្រមព្រហ្មទណ្ឌ ការធ្វើទារុណកម្ម ឬអំពើឃោឃៅទៅលើជនរងគ្រោះ ក្នុងបទល្មើសសញ្ចារកម្ម គឺជាស្ថានទម្ងន់ទោស ត្រូវអនុវត្តន៍លើជនល្មើស ជាសញ្ចារិក សញ្ចារិកា ឬជាមេពេស្យា ដែលជាធម្មតា នៅក្នុងមាត្រា ២៨៥ ផ្តន្ទាទោសត្រឹមតែ ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យពី ៤ លានរៀល ទៅ ១០ លានរៀលប៉ុណ្ណោះ។ រីឯស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើឃោឃៅ ឬទារុណកម្មវិញ ត្រូវអនុវត្តធ្ងន់ធ្ងរ ដែលមានចែងក្នុងមាត្រា ២៩០ ស្ថានទម្ងន់ទោស ដោយសារការធ្វើទារុណកម្ម ឬអំពើឃោឃៅ ៖

សញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់)ឆ្នាំ ទៅ ២០(ម្ភៃ) ឆ្នាំ កាលបើសញ្ចារិក សញ្ចារិកា ឬជនមេពេស្យា បានប្រើប្រាស់ទារុណកម្ម ឬអំពើឃោឃៅចំពោះបុគ្គលដែលធ្វើពេស្យាចារ។

ដោយឡែក ក្នុងករណីជនរងគ្រោះជាអនីតិជន ក៏ជាស្ថានទម្ងន់ទោសនៃបទល្មើសសញ្ចារកម្មដែរ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧(ប្រាំពីរ) ឆ្នាំ ទៅ ១៥(ដប់ប្រាំ) ឆ្នាំ។[36]

### ❖ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ បានចែងយ៉ាងច្បាស់អំពីការផ្តន្ទាទោសចំពោះការប្រើប្រាស់ពលកម្មលើកុមារ។ ច្បាប់នេះក៏មានចែងអំពីបទល្មើស "ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច"។[37] "ការជ្រើសរើសដោយមិនស្របច្បាប់" មានន័យថា ការបញ្ចុះបញ្ចូល ការជួល ឬការឲ្យបុគ្គលណាមួយបម្រើការងារ ក្រោមទម្រង់នៃការកេងប្រវ័ញ្ច តាមមធ្យោបាយបោកបញ្ឆោត បំពានអំណាចការបង្ខាំងខ្លួន ការប្រើប្រាស់កម្លាំង ការគម្រាមកំហែង ឬមធ្យោបាយបង្ខិតបង្ខំជាដើម។ "ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត" ត្រូវបាននៅក្នុងច្បាប់នេះ[38] រួមមានទាំងការបញ្ចាំខ្លួនដោះបំណុលផងដែរ។ ការផ្តន្ទាទោស ចំពោះ

[36] មាត្រា ២៨៩ នៃក្រមព្រហ្មទណ្ឌ

[37] មាត្រា ១២ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

[38] មាត្រា ១០ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច គឺត្រូវជាប់ពន្ធនាគារចាប់ពី ៧(ប្រាំពីរ)ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ ឬចាប់ពី ១៥(ដប់ប្រាំ)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ ប្រសិនបើជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ ។ ការពឹងផ្អែកលើម្ចាស់សិប្បកម្មរបស់កម្មករកុមារដែលធ្វើការ ដើម្បីដោះបំណុល និងការមិនមានអំណាចក្នុងការតវ៉ា គួបផ្សំជាមួយនឹងការគម្រាមកំហែងលើកុមារផ្ទាល់ថា ពួកគេអាចត្រូវចាប់ខ្លួន ប្រសិនបើពួកគេប៉ុនប៉ងចាកចេញពីកន្លែងការងារ ដោយគ្មានការអនុញ្ញាត ដោយមិនទាន់ទូទាត់សងប្រាក់បំណុលទាំងអស់នេះ ហាក់ដូចជា ធ្វើការដោយបញ្ចាំខ្លួនដោះបំណុល ដែលនេះស្ថិតនៅក្រោមវិសាលភាពនៃ "ការជ្រើសរើសដោយមិនស្របច្បាប់"។

ជាមួយគ្នានេះ ក៏មានមាត្រាផ្សេងទៀតនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសមាត្រាទាក់ទងនឹងការនាំចេញដោយមិនស្របច្បាប់ ដែលមានន័យថា "ការនាំយកមនុស្សម្នាក់ពីកន្លែងដែលគេរស់នៅ ទៅកាន់កន្លែងដ៏ទៃទៀត ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬរបស់តតិយជនតាមមធ្យោបាយបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានអំណាច ឬលួងលោម"។ នៅពេលការនាំចេញដោយមិនស្របច្បាប់ត្រូវបានធ្វើឡើង ក្នុងគោលបំណងកេងប្រវ័ញ្ច រួមទាំងការបញ្ចាំខ្លួនដោះបំណុល ជនល្មើសនឹងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ ចាប់ពី ៧(ប្រាំពីរ)ឆ្នាំ ទៅ ១៥(ដប់ប្រាំ)ឆ្នាំ ឬចាប់ពី ១៥(ដប់ប្រាំ)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ ប្រសិនបើជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ។ ច្បាប់ស្តីពីការជួញដូរ មិនមានចែងលក្ខខណ្ឌដែលតម្រូវឲ្យធ្វើការឆ្លងដែន[39] ឬកំណត់ចម្ងាយអប្បបរមាជាក់លាក់ណាមួយ ដើម្បីចាត់ជាការនាំយកចេញដោយមិនស្របច្បាប់នោះទេ ដូច្នេះមានន័យថា ការនាំយកមនុស្សម្នាក់ចេញពីភូមិកំណើត ទៅកាន់កន្លែងធ្វើការផ្សេងៗ វាគ្រប់គ្រាន់ក្នុងការចាត់ទុកថា ជាការនាំយកចេញដោយមិនស្របច្បាប់ ហើយនេះជាបទល្មើស។ ជាមួយគ្នានេះ ការផ្តល់ប្រាក់កម្ចី និងការផ្តល់កន្លែងស្នាក់នៅ អាចត្រូវបានចាត់ទុកថាជា ការលួងលោម។ ដូចនេះម្ចាស់ទីតាំង ឬម្ចាស់សិប្បកម្មដែលកុមារកំពុងបម្រើការងារ មិនអាចប្រកែកបានទេដោយសម្អាងថា កុមារទាំងនោះមកធ្វើការដោយខ្លួនឯង ហើយក៏មិនអាចប្រើប្រាស់ហេតុផលទាំងនេះ ដើម្បីយកមកការពារខ្លួនផងដែរ។[40]

ច្បាប់ស្តីពីការជួញដូរ ក៏មានចែងពីការផ្តន្ទាទោសចំពោះអំពើជួញដូរមនុស្សផងដែរ ដែលរាប់បញ្ចូលជាពិសេសស្ត្រី និងកុមារ។ អំពើជួញដូរមនុស្សមានន័យថាការផ្ទេរនូវការគ្រប់គ្រងលើបុគ្គលណាម្នាក់ដោយដោះដូរជាមួយនឹងវត្ថុមានតម្លៃអ្វីមួយ[41] ហើយអំពើនេះអាចត្រូវបានផ្តន្ទាទោសពន្ធនាគារចាប់ពី ២(ពីរ)ឆ្នាំ ដល់ ៥(ប្រាំ)ឆ្នាំ។[42] ប្រសិនបើគោលបំណងនៃការធ្វើអាជីវកម្មនោះ ដើម្បីកេងប្រវ័ញ្ច (ទាំងការកេងប្រវ័ញ្ចពលកម្ម និងផ្លូវភេទ)

[39] ប្រសិនបើអំពើរួមផ្សំណាមួយនៃបទល្មើសជួញដូរប្រព្រឹត្តឡើងក្នុងប្រទេសកម្ពុជា នេះគ្រប់គ្រាន់ក្នុងការអនុវត្តមាត្រា ២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

[40] មាត្រា ៨ និងមាត្រា ១០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

[41] មាត្រា ១៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

[42] មាត្រា ១៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

នោះការផ្តន្ទាទោសពន្ធនាគារចាប់ពី ៧(ប្រាំពីរ)ឆ្នាំ ទៅ ១៥(ដប់ប្រាំ)ឆ្នាំ ឬចាប់ពី ១៥(ដប់ប្រាំ)ឆ្នាំ ទៅ ២០(ម្ភៃ) ឆ្នាំ ប្រសិនបើជនរងគ្រោះមានអាយុក្រោម ១៨ ឆ្នាំ។[43]

### ៣.២.១.២) ទោសអនុវត្តន៍ចំពោះនីតិបុគ្គល

នីតិបុគ្គល គឺជាក្រុមមនុស្ស ឬមូលនិធិ ដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។[44] នីតិបុគ្គល សំដៅអង្គភាព ឬស្ថាប័ន ដែលបង្កើតឡើងដោយច្បាប់ (ក្រុមហ៊ុន រោងចក្រ សិប្បកម្ម សហគ្រាស សមាគមន៍ អង្គការ...) នីតិបុគ្គល បណ្តុំដោយរូបវន្តបុគ្គល។

នីតិបុគ្គល មាននីតិបុគ្គលនៃនីតិសាធារណៈ និងនីតិបុគ្គលនៃនីតិឯកជន។

ជាទូទៅ ទោសអនុវត្តន៍សម្រាប់នីតិបុគ្គលដែលត្រូវរង គឺមានមូលទោស ក្នុងប្រភេទជាទោសពិន័យ ទោសបន្ថែមទាំង ១៤ ចំនុច ដែលបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ ធ្វើឡើងតាមរយៈការប្រកាសទោស។[45]

ដោយសារតែនីតិបុគ្គល មិនមែនជាមនុស្ស ដូច្នេះគេត្រូវសម្របទណ្ឌកម្មដើម្បីអាចអនុវត្តន៍ទៅបាន។ ឧទាហរណ៍ ទោសពន្ធនាគារ គេមិនអាចចាប់នីតិបុគ្គល ដែលជាក្រុមហ៊ុន/សហគ្រាស ដាក់ពន្ធនាគារបានទេ។ ដូចនេះ ដើម្បីអនុវត្តន៍ទោសបាន សម្រាប់នីតិបុគ្គល មានតែទោសពិន័យជាប្រាក់ រួមនឹងទោសបន្ថែមប៉ុណ្ណោះ។

ចំពោះបែបបទ ដែលមានចែងទាក់ទងជាមួយទោសខាងលើ គឺមានចែងចាប់ពីមាត្រា ១៦៧ ដល់មាត្រា ១៨២ នៃក្រមព្រហ្មទណ្ឌ ដែលយើងសង្កេតឃើញថា ទោសពិន័យក្នុងឋានៈជាមូលទោសនេះ យើងប្រើប្រាស់ដូចគ្នា ជាមួយនឹងទោសពិន័យសម្រាប់រូបវន្តបុគ្គលដែរ។

ចំពោះទោសបន្ថែម ដែលត្រូវអនុវត្តចំពោះនីតិបុគ្គល គឺមានចែងដាក់លាក់ក្នុងមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌ។ នៅក្នុងមាត្រា ១៦៨ នេះ បានកំណត់ចំនួន ១៤ ចំនុច ។ ទោសបន្ថែមទាំង ១៤ ចំនុច ដែលត្រូវអនុវត្តន៍ចំពោះនីតិបុគ្គល មានដូចតទៅ៖[46]

១- ការរំលាយចោល។

២- ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យ តាមដានរបស់តុលាការ។

៣- ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពណាមួយ ឬច្រើន។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

៥- ការហាមឃាត់ ចំពោះការអំពាវនាវសាធារណៈដល់ការសន្សំសំចៃ។

[43] មាត្រា ១៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

[44] មាត្រា ៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងសទ្ទានុក្រមពាក្យច្បាប់ នៃក្រមព្រហ្មទណ្ឌ ទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០១១ លេខរៀងទី ៥៦

[45] មាត្រា ១៦៧ នៃក្រមព្រហ្មទណ្ឌ

[46] មាត្រា ១៦៨ ស្តីពី ទោសបន្ថែមអនុវត្តន៍ចំពោះនីតិបុគ្គល នៃក្រមព្រហ្មទណ្ឌ

៦- ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបាន ដែលកំណត់ដោយធនាគារ។

៧- ការហាមឃាត់ចំពោះការប្រើប័ណ្ណទូទាត់។

៨- ការបិទគ្រឹះស្ថាន ដែលប្រើសម្រាប់រៀបចំ ឬប្រព្រឹត្តបទល្មើស។

៩- ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហរដល់សាធារណៈជន ឬដែលបានប្រើប្រាស់ដោយសាធារណៈជន។

១០- ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។

១១- ការរឹបអូសវត្ថុ ឬមូលនីធិដែលជាកម្មវត្ថុនៃបទល្មើស។

១២- ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

១៣- ការរឹបអូសឧបភោគភណ្ឌសម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។

១៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយ ទូរគមនាគមន៍សោតទស្សន៍។

ចំពោះករណី បទល្មើសដែលពាក់ព័ន្ធនឹងពលកម្មកុមារ ការអនុវត្តទោសព្រហ្មទណ្ឌ លើនីតិបុគ្គលគឺប្រើតែចំនួន ២ ទៅ ៣ ចំនុចប៉ុណ្ណោះ ដោយហេតុតែបទល្មើសនេះ ច្រើនកើតឡើងនៅក្នុងនីតិបុគ្គលឯកជន លើកលែងតែមានការសម្រេចច្រើនជាងនេះ ទៅតាមសេចក្តីសម្រេចរបស់តុលាការ។ ចំនុចទាំងនោះ មានដូចតទៅ៖

**ចំនុចទី១.** យោងតាមក្រមព្រហ្មទណ្ឌ ទាក់ទងនឹងការរំលាយចោលនេះបានកំណត់ថា៖ សេចក្តីសម្រេចដែលបង្គាប់ឲ្យរំលាយនីតិបុគ្គល នាំឲ្យមានការបញ្ជូននីតិបុគ្គលនេះទៅតុលាការ មានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី។[47] មួយវិញទៀត ដោយយោងតាមប្រសាសន៍ ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានលើកឡើង និងពន្យល់ថា៖

*"ការរំលាយចោលហ្នឹង គឺសំដៅការសម្រេចប្រកាស បើនិយាយពីរូបវន្តបុគ្គល សម្រាប់មនុស្សវិញ គឺហាក់ដូចជា ទោសប្រហារជីវិតអញ្ចឹងដែរ បានន័យថា រំលាយអត្ថិភាពនៃនីតិបុគ្គលតាមច្បាប់។ ហ្នឹង! ទោសហ្នឹង គឺជាទោសដែលធ្ងន់ធ្ងរជាងគេបំផុត សម្រាប់នីតិបុគ្គល ព្រោះក្រៅពីនិន័យជាប្រាក់ហើយ គេអាចរំលាយក្រុមហ៊ុនហ្នឹងចោល រំលាយសមាគមន៍ហ្នឹងចោល រំលាយអង្គការហ្នឹងចោល។ អញ្ចឹងទោសហ្នឹងគឺសំខាន់ណាស់។"*

**ចំនុចទី៨.** យោងតាមក្រមព្រហ្មទណ្ឌ ចំពោះការបិទគ្រឹះស្ថាន ។ ទោសបិទគ្រឹះស្ថាន នាំឲ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះ នូវសកម្មភាពដែលបទល្មើស បានកើតឡើងនៅក្នុងឱកាសដែលធ្វើ

[47] មាត្រា ១៧០ នៃក្រមព្រហ្មទណ្ឌ

សកម្មភាពនេះ។ ទោសនេះអាចចូលជាស្ថាពរ ឬជាបណ្ដោះអាសន្នសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។[48]

ក្នុងន័យនេះ ចំពោះគ្រឹះស្ថាន សិប្បកម្ម សហគ្រាសដែលបានប្រព្រឹត្តបទល្មើសពលកម្មកុមារ នឹងត្រូវប្រឈមមុខនឹងទណ្ឌកម្ម ដែលជាទោសបន្ថែមនេះផងដែរ។ ជាមួយគ្នានេះដែរ មន្ត្រីជាន់ខ្ពស់នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានព្រមានផងដែរថា៖

*"បើមានករណីណាមួយប្រើប្រាស់ពលកម្មកុមារ ក្រសួងនឹងធ្វើការដាក់កំហិត បើសិនជាកម្រិតធ្ងន់ធ្ងរ ក្រសួងនឹងធ្វើការពិន័យយកតែម្ដង បើករណីគ្រោះថ្នាក់អាចបាត់បង់សារពាង្គកាយ ឬឈានដល់ការបាត់បង់អាយុជីវិតណាមួយ ក្រសួងនឹងធ្វើកិច្ចសហការជាមួយអាជ្ញាធរដែលពាក់ព័ន្ធអនុវត្តក្រមព្រហ្មទណ្ឌភ្លាម ក្នុងការបិទសិប្បកម្ម សហគ្រាសទាំងនោះ។"*

នេះជាការបញ្ជាក់របស់លោក **វ៉េង ហៀង** អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ និងជាប្រធាននាយកដ្ឋានកុមារ នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្នុងឱកាសដែលលោកដឹកនាំក្រុមអធិការរបស់ក្រសួងការងារ ចុះទៅដល់កន្លែងសិប្បកម្មផលិតឥដ្ឋដោយផ្ទាល់ ស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ៦អា សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វា នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩។

**ចំនុចទី១០.** ការរឹបអូស និងសិទ្ធិតតិយជន ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ បានកំណត់ថា៖[49]

ការរឹបអូស អាចធ្វើទៅលើវត្ថុដូចខាងក្រោម៖

១- ឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។

២- វត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣- ផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។

៤- ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើតឡើង។

ក៏ប៉ុន្តែ ការរឹបអូសមិនអាចត្រូវបានប្រកាសបានទេ ប្រសិនបើការរឹបអូសនោះ បានប៉ះពាល់ដល់សិទ្ធិរបស់តតិយជន។

ជារួមមក ប្រការនេះត្រូវបានគេយកមកអនុវត្តន៍ផងដែរ ចំពោះសិប្បកម្ម សហគ្រាស ឬនៅទីកន្លែងណាដែលមានបទល្មើសពលកម្មលើកុមារ។

---

48 មាត្រា ១៧៦ នៃក្រមព្រហ្មទណ្ឌ

49 មាត្រា ១៧៩ នៃក្រមព្រហ្មទណ្ឌ

បើទោះបីជាមានច្បាប់ជាច្រើន ដែលរួមមានទាំងក្រមព្រហ្មទណ្ឌ និងច្បាប់ពិសេសផ្សេងៗ បានបញ្ញត្តិនូវទោសទណ្ឌចំពោះបទល្មើសទាំងឡាយ ដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចពលកម្មលើកុមារក៏ដោយក្តី ប៉ុន្តែជារឿយៗ ជនដែលបានប្រព្រឹត្តបទល្មើស តែងរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលនេះគឺជា និទណ្ឌភាពដែលតម្រូវអោយមានដំណោះស្រាយសមស្រប ដើម្បីការលុបបំបាត់វប្បធម៌និទណ្ឌភាពនេះ។

### ៣.២.២. និទណ្ឌភាព និងដំណោះស្រាយ

#### ៣.២.៣.១) និទណ្ឌភាព

និទណ្ឌភាព មានន័យថា ការមិនត្រូវផ្តន្ទាទោស ឬគ្មានផលវិបាកណាមួយ ។ តាមរយៈការរៀបរាប់ខាងលើ មានបញ្ញាត្តិច្បាប់ជាច្រើន ស្តីពីការហាមឃាត់ និងការផ្តន្ទាទោសចំពោះការប្រើប្រាស់កម្លាំងពលកម្មកុមារ ឬការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ។ បទបញ្ញាត្តិទាំងនោះមានទាំងនៅក្នុងក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការងារ ច្បាប់អន្តរជាតិ ច្បាប់បន្ថែម និងសូម្បីតែរដ្ឋធម្មនុញ្ញក៏មានដែរ។ ប៉ុន្តែជនដែលបានប្រព្រឹត្តបទល្មើស ក៏ដូចជាសិប្បកម្ម សហគ្រាសដែលបានធ្វើអោយមានបទល្មើស ហាក់ដូចជាពុំមានចំណាត់ការណាមួយឡើយ និងនៅតែបន្តដំណើរការជាធម្មតា។ ជាក់ស្តែងកាលពីពេលថ្មីៗនេះ នាអំឡុងខែមីនា ឆ្នាំ២០១៩ ក្មេងស្រី អាយុ១០ឆ្នាំម្នាក់ ត្រូវបានរងរបួសដាច់ដៃស្តាំម្ខាងនៅក្នុងសិប្បកម្មផលិតឥដ្ឋ។[50] ទោះបីជានាងជាអនីតិជន ប៉ុន្តែនាងបានជួយឪពុកម្តាយដាក់ដីចូលក្នុងម៉ាស៊ីនកាត់ឥដ្ឋ ដែលទទួលបានប្រាក់កម្រៃតាមចំនួនផលិតកម្ម។ ជាទម្លាប់នៃសិប្បកម្មផលិតឥដ្ឋដែលមានកម្មករជំពាក់បំណុលម្ចាស់សិប្បកម្មផលិតឥដ្ឋ ប្រាក់កម្រៃបែបនេះ អាចផ្តល់ជាមធ្យោបាយលើកទឹកចិត្តដល់គ្រួសារដើម្បីបង្កើនចំនួនផលិតកម្ម ដោយឱ្យសមាជិកគ្រួសារចូលរួមជួយធ្វើការ។ ភ្លាមៗ បន្ទាប់ពីហេតុការណ៍នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសម្រេចផាកពិន័យម្ចាស់សិប្បកម្ម និងបិទដំណើរការរបស់សិប្បកម្ម។ ប៉ុន្តែគេសង្កេតឃើញថាសិប្បកម្មផលិតឥដ្ឋមួយនេះ គឺនៅដំណើរការជាធម្មតានៅឡើយ។

យោងទៅតាមរបាយការណ៍របស់អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូរ) បានលើកឡើងថា នៅពេលដែលមានកិច្ចពិភាក្សាជាមួយចៅសង្កាត់ ឬមេឃុំ និងមន្ត្រីនគរបាលនៅក្នុងតំបន់ដែលមានសិប្បកម្មផលិតឥដ្ឋបានបង្ហាញថា ទាំងអាជ្ញាធររដ្ឋបាល និងអាជ្ញាធរអនុវត្តន៍ច្បាប់ បានដឹងច្បាស់អំពីការអនុវត្តន៍ និងការកេងប្រវ័ញ្ចពលកម្មលើកុមារ ដែលកើតមានឡើងនៅក្នុងសិប្បកម្មផលិតឥដ្ឋ។ ប៉ុន្តែអាជ្ញាធរទាំងពីរផ្នែក ជារឿយៗតែងតែព្រងើយកន្តើយចំពោះការអនុវត្តច្បាប់ ចំពោះម្ចាស់សិប្បកម្មផលិតឥដ្ឋ ហើយកន្លងមកនៅកម្ពុជាមិនធ្លាប់បានឮ ឬបានដឹងពីការផ្តន្ទាទោស ឬសូម្បីតែការពិន័យជាប្រាក់ចំពោះម្ចាស់សិប្បកម្មដែលមិនបានគោរព និងអនុវត្តន៍ច្បាប់ទាំងអម្បាលមាណឡើយ។ សូម្បីតែករណីដែលមានកុមាររងគ្រោះបាន

---

[50] សេចក្តីថ្លែងការណ៍របស់អង្គការលីកាដូ នៅថ្ងៃទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ឆ្នាំ២០១៩

រងរបួសធ្ងន់ធ្ងរ ម្ចាស់សិប្បកម្មនៅតែទទួលបាននិទណ្ឌភាពដដែល។ ឪពុកម្តាយរបស់កុមារដែលជាជនរងគ្រោះបានព្យាយាមប្តឹងទៅមន្ត្រីនគរបាល ប៉ុន្តែមន្ត្រីនគរបាល បានបដិសេធបញ្ជូនសំណុំរឿងទាំងនោះទៅកាន់តុលាការ។ ក្នុងសំណុំរឿងមួយដែលពាក់ព័ន្ធនឹងកុមារអាយុ ១៤ ឆ្នាំម្នាក់ មន្ត្រីនគរបាលបានប្រាប់ឪពុកម្តាយនោះថា គ្រោះថ្នាក់នេះកើតឡើងដោយសារកំហុសរបស់ឪពុកម្តាយរបស់កុមារ ដែលឲ្យកូនធ្វើការ ហេតុនេះវាគ្មានប្រយោជន៍អ្វីទេដែលត្រូវប្តឹងទៅតុលាការនោះ ពីព្រោះពួកគាត់នឹងចាញ់ក្តី។ ចំណែកឯម្ចាស់សិប្បកម្មក៏បានអះអាងដែរថា នេះមិនមែនជាកំហុសរបស់ម្ចាស់សិប្បកម្មឡើយ ដោយយកលេសថា គាត់មិនបានអោយកុមារទាំងនោះធ្វើការទេ។ បន្ទាប់ពីកូនគាត់រងគ្រោះ ក្រុមគ្រួសារមិនបានទទួលសំណងអ្វីឡើយពីម្ចាស់សិប្បកម្ម ប៉ុន្តែជាការដោះដូរ និងបញ្ចប់រឿង ម្ចាស់សិប្បកម្មបានលុបចោលបំណុលដែលឪពុកម្តាយកុមាររងគ្រោះជំពាក់ ចំនួនពាក់កណ្តាល មានន័យថា បើគ្រួសារកុមារនោះជំពាក់ ៥០០០ដុល្លារ និងនៅសល់តែ ២៥០០ដុល្លាតែប៉ុណ្ណោះ។[51]

ចំពោះករណីពាក់ព័ន្ធមួយទៀត កុមាររងគ្រោះម្នាក់អាយុ ៧ ឆ្នាំ ត្រូវបានមន្ត្រីនគរបាលបដិសេធមិនទទួលពាក្យបណ្តឹងពីគ្រួសារកុមារនោះ។ មន្ត្រីនគរបាលនោះ បានលើកឡើងថា កំហុសនោះជាកំហុសរបស់ឪពុកម្តាយរបស់កុមារផ្ទាល់ ដែលបណ្តោយអោយកុមារនោះទៅលេងក្នុងបរិវេណដែលមានគ្រោះថ្នាក់ មិនមែនកុមារនោះធ្វើការនៅទីនោះទេ ហេតុដូច្នេះ វាមិនមែនជាការទទួលខុសត្រូវរបស់ម្ចាស់សិប្បកម្មឡើយ។ នៅពេលដែលមានអង្គការសង្គមស៊ីវិល ផ្តល់យោបល់អោយគ្រួសារកុមាររងគ្រោះ ដាក់ពាក្យបណ្តឹងទៅតុលាការ ពួកគាត់បែរជាស្ទាក់ស្ទើរ និងមិនហ៊ានប្តឹងឡើយ ពីព្រោះម្ចាស់សិប្បកម្មអាចនឹងបំពានលើពួកគាត់ជាកម្មករ តាមរយៈការព្យួរប្រាក់ពលកម្ម ដោយសារតែកន្លងមក រឿងនេះតែងកើតឡើងជាញឹកញាប់។

ជារួមមក ម្ចាស់សិប្បកម្មតែងតែទទួលបាននូវនិទណ្ឌភាព ដែលមិនអាចចាប់ម្ចាស់សិប្បកម្ម ដើម្បីទទួលទោសទណ្ឌបានឡើយ។ ហើយគេសង្កេតឃើញថា មកទល់នឹងពេលនេះ សិប្បកម្មផលិតឥដ្ឋទាំងឡាយនៅតែដំណើរ និងប្រព្រឹត្តទៅយ៉ាងរលូនធម្មតាដដែល។

តើត្រូវមានវិធានការ និងដំណោះស្រាយយ៉ាងដូចម្តេចខ្លះចំពោះបញ្ហាអវិជ្ជមាននេះ?

### ៣.២.៣.២) ដំណោះស្រាយ

ដើម្បីលុបបំបាត់ពលកម្មកុមារ កន្លងមករាជរដ្ឋាភិបាល តាមរយៈក្រសួងការងារ ក៏ដូចជាអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធបានចូលរួមយ៉ាងច្រើន ក្នុងនោះមានទាំងការបង្កលក្ខណៈងាយស្រួល និងជួយឧបត្ថម្ភដល់កុមារឲ្យបានចូលរៀន និងជួយជាប្រាក់ដល់ក្រុមគ្រួសារកុមារទាំងនោះជាដើម។

[51] របាយការណ៍អង្គការលីកាដូ ចេញផ្សាយខែធ្នូ ឆ្នាំ២០១៦

ក្រៅពីនោះ រាជរដ្ឋាភិបាលក៏មានចាត់វិធានការនានាក្នុងការកាត់បន្ថយ និងលុបបំបាត់ពលកម្មកុមារនៅក្នុងប្រទេសកម្ពុជាផងដែរ ដែលមានជាអាទិ៍៖

❖ **គោលនយោបាយជាតិក្នុងការលុបបំបាត់ពលកម្មកុមារ**

រាជរដ្ឋាភិបាលបានបង្កើត និងអនុវត្តន៍នូវក្របខ័ណ្ឌគោលនយោបាយថ្នាក់ជាតិ ដែលកំណត់ពលកម្មកុមារ ជាសូចនាករសំខាន់សម្រាប់សេដ្ឋកិច្ច ការលុបបំបាត់ភាពក្រីក្រ និងការលើកកម្ពស់សិទ្ធិកុមារ។ យុទ្ធ-សាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតសំខាន់លើការកំណើនការងារ សមធម៌ និងប្រសិទ្ធិភាព ហើយបានចាត់ទុកកុមារ គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ និងមូលធននៅក្នុងប្រទេស។ លើសពីនេះទៅទៀត ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ បានកំណត់យ៉ាងច្បាស់អំពីការលើកម្ពស់សុវត្ថិភាពនៅកន្លែងការងារ សម្រាប់កុមារអាយុចាប់ពី ១៥ ឆ្នាំ ដល់ ១៨ ឆ្នាំ និងក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ ទាំងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ និងទាំងគោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់កម្ពុជា សុទ្ធតែបានផ្តល់ការងារបង្កើនការផ្គត់ផ្គង់ពលកម្មជំនាញ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ ការធានានូវលក្ខខណ្ឌការងារសមរម្យ និងការអនុវត្តច្បាប់ការងារ និងលក្ខខណ្ឌអន្តរជាតិ និងផ្តល់នូវការចូលរួមចំណែក និងពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយកុមារបម្រើការងារ។ លើសពីនេះទៅទៀត សំណាញ់សន្តិសុខសង្គម ត្រូវបានផ្តល់ឲ្យជនរងគ្រោះពីការជួញដូរ ដែលជាអនីតិជន កុមារជាប់ទោស ជនរស់នៅតាមចិញ្ចើមផ្លូវ ក្មេងកំព្រា និងកុមារងាយរងគ្រោះដ៏ទៃទៀត។

ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅក្នុងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨។ ផែនការនេះត្រូវបានអនុវត្តន៍ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុពីកម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ (ILO IPEC) អង្គការក្រៅរដ្ឋាភិបាលជាតិ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិក្នុងប្រទេស។

❖ **គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព**

គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ត្រូវបានអនុម័ត និងដាក់ចូលជាធរមានកាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០។ ភូមិ ឃុំ/សង្កាត់នីមួយៗ ត្រូវធានាឲ្យបាននូវសុវត្ថិភាពនៅក្នុងតំបន់របស់ខ្លួន មានន័យថានឹងមិនមានអំពើចោរកម្ម សកម្មភាពលួច ឆក់ប្លន់គ្រប់ប្រភេទ គ្មានការផលិត ចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្មានអំពើពេស្យាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ គ្មានក្មេងទំនើង គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

គោលនយោបាយនេះ បំពេញបន្ថែមលើគោលនយោបាយថ្នាក់ជាតិ ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ដែលផ្តោតសំខាន់លើការជួញដូរ ការកេងប្រវ័ញ្ចពលកម្មកុមារ។

ជាមួយគ្នានេះ ច្បាប់ស្តីពីការងារ ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៧ នាពេលបច្ចុប្បន្ន កំពុងត្រូវបានស្ថិតនៅក្នុងដំណើរការត្រួតពិនិត្យមើលឡើងវិញ និងត្រូវរួមបញ្ចូលនូវភាសា និងលក្ខខណ្ឌចាំបាច់ខ្លះស្តីពីការលុបបំបាត់ពលកម្មកុមារ ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដែលកុមារបម្រើតាមផ្ទះ ស្របពេលដែលអង្គការពលកម្មអន្តរជាតិ បានអនុម័តលើអនុសញ្ញាស្តីពី ការងារសមរម្យ សម្រាប់អ្នកបម្រើការងារតាមផ្ទះ។[52]

ក្រៅពីនេះ រដ្ឋាភិបាលក៏ចេញសេចក្តីណែនាំ ៥ ចំណុច ស្តីពីការហាមកុមារ ក្មេងៗចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម នៃសិប្បកម្មផលិតឥដ្ឋ។ សេចក្តីណែនាំនេះ ត្រូវបានបញ្ជូនទៅកាន់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាល រាជធានីខេត្តទាំងអស់ ដើម្បីចុះធ្វើការណែនាំដល់ម្ចាស់ ឬនាយកសិប្បកម្មផលិតឥដ្ឋនៅមូលដ្ឋានរបស់ខ្លួនឲ្យអនុវត្ត។ វិធានការ ៥ ចំណុច ដើម្បីបញ្ចៀសនូវឧបទ្ទវហេតុ ដែលអាចកើតមានជាយថាហេតុចំពោះក្មេង នៅក្នុងសិប្បកម្មផលិតឥដ្ឋ ដែលរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទើបតែដាក់ចេញរួមមាន៖[53]

១-រៀបចំដាក់ស្លាកសញ្ញាធំៗ និងងាយមើលឃើញដូចជា៖ ហាមកុមារចូលទៅក្នុងបរិវេណខ្សែចង្វាក់ផលិតកម្ម។ ជនណាដែលនាំកុមារ ចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម អាចនឹងប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ។ ការប្រើប្រាស់ពលកម្មកុមារនៅសិប្បកម្មផលិតឥដ្ឋ គឺអាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ។

២-ហាមឃាត់ដាច់ខាតការប្រើប្រាស់ទាសភាពបំណុល ដើម្បីដាក់បន្ទុកសេរីភាពការងារកម្មករ។

៣-ត្រូវមានអ្នកឃ្លាំមើលជាប្រចាំ និងហាមក្មេងចូលក្នុងបរិវេណខ្សែសង្វាក់ ផលិតកម្ម ឬធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋ។

៤-ត្រូវរៀបចំកន្លែងស្នាក់នៅឲ្យឃ្លាត ឆ្ងាយពីខ្សែសង្វាក់ផលិតកម្ម និងត្រូវមានរបងការងារសុវត្ថិភាពដែលខណ្ឌចែកបរិវេណ ខ្សែសង្វាក់ផលិតកម្ម និងកន្លែងស្នាក់នៅ។

៥-ហាមឃាត់ដាច់ខាតរាល់ទម្រង់នៃការ កេងប្រវ័ញ្ចពលកម្មលើកុមារ និងការបង្ខំឲ្យកុមារធ្វើការ ដើម្បីដោះបំណុល។

[52] អនុសញ្ញាលេខ ១៨៩ ស្តីពីការងារសមរម្យសម្រាប់អ្នកបម្រើការងារតាមផ្ទះ

[53] សេចក្តីណែនាំចេញដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩

សេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងការងារ បានបញ្ជាក់ថា "ម្ចាស់ឬនាយកសិប្បកម្មផលិតឥដ្ឋទាំងឡាយណា ដែលខកខានក្នុងការអនុវត្តតាមសេចក្តីណែនាំនេះនឹងត្រូវទទួលរង នូវការផាកពិន័យ ឬអាចឈានដល់ការបិទអាជីវកម្ម ឬអាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ"។

អ្វីដែលបានរៀបរាប់ខាងលើ គឺជាយន្តការរបស់រាជរដ្ឋាភិបាល ដែលសហការ និងគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក្នុងគោលដៅដោះស្រាយបញ្ហាពលកម្មកុមារ ជាពិសេសគឺសំដៅដល់ការលុបបំបាត់ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបជារួមមក ការងារកុមារ និងពលកម្មកុមារ ភាពភាពខុសគ្នាយ៉ាងដាច់ស្រឡះ ។ ដែលការងារកុមារជាការងារដែលច្បាប់អនុញ្ញាត ហើយកុមារគ្រប់ៗរូបអាចធ្វើបាន។ ផ្ទុយមកវិញ ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ គឺត្រូវបានច្បាប់ហាមឃាត់ជាដាច់ខាត។ ក្នុងករណីដែល រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលបានទទួលកុមារ ឬបោកបញ្ឆោតកុមារ ក្នុងគោលបំណងកេងប្រវ័ញ្ចពលកម្មលើកុមារ ដែលបណ្តាលអោយប៉ះពាល់ដល់សិទ្ធិរបស់កុមារ និងច្បាប់ដែលបានបញ្ញត្តិនោះ ទោះក្នុងរូបភាពណាក៏ដោយ បុគ្គលនោះត្រូវប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ ដែលត្រូវទទួលទណ្ឌកម្ម ទៅតាមអំពើប្រព្រឹត្តបទល្មើសរបស់ខ្លួន។

ប៉ុន្តែសព្វថ្ងៃនេះ នៅក្នុងបរិបទសង្គមនៃប្រទេសកម្ពុជា ពលកម្មកុមារនៅតែជាបញ្ហា ដែលពិបាកក្នុងការដោះស្រាយ។ ពលកម្មកុមារមានលក្ខណៈមិនបើកចំហរ ដែលជាការពិបាកក្នុងការទប់ស្កាត់ និងបង្ក្រាប។ ហើយម្យ៉ាងទៀត ពលកម្មកុមារខ្លះ ជាពិសេសនៅតាមសិប្បកម្មផលិតឥដ្ឋជាដើម បើទោះបីជាមានការដឹងឮពីអាជ្ញាធរមូលដ្ឋាន និងមន្ត្រីនគរបាលដែលជាអ្នកអនុវត្តច្បាប់ក្តី ឬក៏ធ្លាប់មានការចុះអប់រំ ណែនាំ និងវិធានការផ្លូវច្បាប់ផ្សេងៗចំពោះម្ចាស់សិប្បកម្មទាំងនោះក្តី ក៏កុមារជាច្រើននៅតែបន្តមានវត្តមាន និងធ្វើការងារគ្រោះថ្នាក់ទាំងនោះដដែល។ នៅពេលសួរថា តើមកពីមូលហេតុអ្វី? គឺដោយសារតែកត្តាជីវភាព ជាមូលហេតុចម្បងដែលបង្ខំកុមារទាំងនោះមិនមានឱកាសបានចូលសាលារៀន ជំនួសវិញដោយឲ្យពួកគេត្រូវខិតខំធ្វើកិច្ចការជាច្រើន រួមទាំងការងារប្រកបដោយគ្រោះថ្នាក់ ដើម្បីរកចំណូលផ្គត់ផ្គង់គ្រួសារ។ ហើយជាទូទៅ ពួកគេជាកុមារតែងតែរងរបួស ពេលខ្លះរហូតដល់បាត់បង់សរីរាង្គណាមួយ ជាពិសេសគឺបានដាច់ដៃ ដោយសារតែម៉ាស៊ីនផលិតឥតហើយរហូតមានកុមារខ្លះបានបាត់បង់ជីវិតផងដែរ។

ពលកម្មកុមារ ជាការងារដែលដោះស្រាយមិនចេះចប់ ដោយសារគោលនយោបាយគាំពាររបស់រាជរដ្ឋាភិបាលមានតិចតួចនៅឡើយ បើទោះបីជាច្បាប់រដ្ឋធម្មនុញ្ញ មាត្រា ៤៨ បានទទួលស្គាល់សិទ្ធិកុមារ ដូចមានចែងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ និងប្រឆាំងអំពើអាជីវកម្មជួញដូរលើកុមារក្តី។ បន្ថែមលើនេះ ដោយមើលឃើញអំពីទុក្ខលំបាករបស់កុមារ ដែលកំពុងធ្វើកិច្ចការជាច្រើន ដូចជា ការលក់របស់កំប៉ិកកំប៉ុកនៅតាមផ្លូវ និងការសុំទានពីអ្នកដំណើរជាដើម ប្រមុខរដ្ឋាភិបាលកម្ពុជា ហាក់បង្ហាញអំពីការទទួលខុសត្រូវរបស់ខ្លួន ដោយមានការពិនិត្យមើល និងដោះស្រាយបញ្ហានេះ។ ប៉ុន្តែការទទួលខុសត្រូវរបស់រដ្ឋាភិបាលនេះ មិនបានឆ្លើយតបលើការកាត់បន្ថយ ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារនៅឡើយ ព្រោះវាគ្រាន់តែជាការអំពាវនាវ ហើយខ្វះការយន្តការអនុវត្តន៍ជាក់ស្តែង។ ការដោះស្រាយ ឬការលុបបំបាត់ពលកម្មកុមារ ហាក់ជារឿងមួយពិបាក

ដោយសារតែបញ្ហានេះទាមទារឲ្យមានការចូលរួមពីរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ប្រជាពលរដ្ឋ និងដៃគូអន្តរជាតិ។ ម្យ៉ាងវិញទៀត ការអនុវត្តច្បាប់របស់ប្រទេសកម្ពុជា និងច្បាប់អន្តរជាតិ ហាក់មិនស៊ីសង្វាក់គ្នានៅឡើយផង។

លើសពីនេះទៅទៀត មកទល់នឹងពេលនេះ នៅមិនទាន់ចំណាត់ការតាមផ្លូវតុលាការណាមួយ ដែលដាក់ទណ្ឌកម្មដល់ម្ចាស់សិប្បកម្ម រោងចក្រសហគ្រាស ក៏ដូចជាជនដែលប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងពលកម្មលើកុមារនៅឡើយផងដែរ។ នេះជាកត្តាមួយ ដែលនាំឲ្យការកេងប្រវ័ញ្ចពលកម្មលើកុមារ នៅតែបន្តកើតមានឡើងហូរហែរ។ ចម្ងល់មួយបានលើកឡើងថា ទន្ទឹមនឹងកម្ពុជាបានផ្តល់សច្ចាប័នលើលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ និងមានច្បាប់បញ្ញាត្តិជាច្រើន រួមទាំងច្បាប់កំពូលផង តើហេតុអ្វីបានជាការរំលោភបំពានលើកុមារ ជាពិសេសពលកម្មកុមារនៅតែបន្តកើនឡើង និងនៅតែមិនអាចលុបបំបាត់បាន?

ជារួមមក ដើម្បីកាត់បន្ថយពលកម្មកុមារ និងឈានទៅដល់ការលុបបំបាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវចាប់ផ្តើមចេញពីយើងទាំងអស់គ្នា តាមរយៈការអប់រំ ណែនាំអំពីពលកម្មកុមារ ការឃ្លាំមើល និងការផ្តល់ព័ត៌មានដល់មន្ត្រីនគរបាលអនុវត្តច្បាប់អំពីបទល្មើសនៃការកេងប្រវ័ញ្ចពលកម្មលើកុមារ ហើយតុលាការ គប្បីផ្តន្ទាទោសអោយបានធ្ងន់ធ្ងរចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើសនេះ ទៅតាមបញ្ញាត្តិច្បាប់ដែលមានចែងជាធរមាន។

# អនុសាសន៍

# អនុសាសន៍

ដើម្បីរួមចំណែកក្នុងការកាត់បន្ថយពលកម្មកុមារ និងឈានទៅរកការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ខ្ញុំបាទមានជាអនុសាសន៍មួយចំនួន គប្បីយកទៅពិចារណា និងអនុវត្តន៍មានដូចតទៅ៖

❖ **ចំពោះប្រជាពលរដ្ឋ ជាពិសេសឪពុកម្តាយ/អាណាព្យាបាលរបស់កុមារ**

- នៅពេលមានគេមកណែនាំអំពីការងារ ដែលទទួលបានប្រាក់កម្រៃខ្ពស់ ឬតម្រូវអោយចំណាកស្រុក ទាំងក្នុងប្រទេសក្តី ឬក្រៅប្រទេសក្តី គប្បីពិចារណាអោយបានល្អិតល្អន់ ដោយមានការជជែកស្នើសុំការផ្តល់យោបល់ពីសំណាក់បងប្អូន ឬអាជ្ញាធរអោយបានច្បាស់លាស់ មុននឹងសម្រេចចិត្តទៅធ្វើការ ឬបញ្ជូនកូនអោយទៅធ្វើការ
- ត្រូវស៊ើបឲ្យដឹង និងយល់ច្បាស់ឲ្យបានច្បាស់អំពីសាវតានៃកន្លែងដែលកូន ឬក្មួយ ឬកុមារទៅធ្វើការ ថាតើមានលក្ខខណ្ឌការងារសមស្រប ត្រឹមត្រូវ និងសុវត្ថិភាពដែរឬទេ?
- ឪពុក ម្តាយ មិនត្រូវបង្ខំកូនអោយទៅជួយធ្វើការងារ ដែលស្ថិតនៅក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឡើយ បើទោះបីជាស្ថិតនៅក្នុងស្ថានភាពទីទាលក្រ ឬការងារដែលកុមារធ្វើនោះ បានទទួលប្រាក់កម្រៃច្រើនយ៉ាងណាក៏ដោយ
- ប្រជាពលរដ្ឋ គប្បីចូលរួមសហការ និងផ្តល់ព័ត៌មានអោយបានឆាប់រហ័ស ទៅកាន់សមត្ថកិច្ច ឬអាជ្ញាធរមូលដ្ឋាន នៅពេលដែលប្រទះឃើញមានករណីពលកម្មកុមារ ក៏ដូចជាទម្រង់ពលកម្មធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

❖ **ចំពោះអាជ្ញាធរមូលដ្ឋាន និងមន្ត្រីនគរបាលអនុវត្តន៍ច្បាប់**

- អាជ្ញាធរមូលដ្ឋាន ជាពិសេសនគរបាល ត្រូវឃ្លាំមើល និងស៊ើបអង្កេតអោយបានគ្រប់ជ្រុងជ្រោយ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនអំពីបទល្មើសទាក់ទងនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាប ចាប់ជនដែលប្រព្រឹត្តបទល្មើស យកទៅផ្តន្ទាទោសតាមច្បាប់
- ពង្រឹងស្មារតី ដោយឆន្ទៈ និងទំនួលខុសត្រូវ ដោយមិនទទួលសំណូក សូកប៉ាន់ពីជនដែលប្រព្រឹត្តបទល្មើស ហើយបណ្តោយឲ្យជនប្រព្រឹត្តបទល្មើសរួចខ្លួន
- ត្រូវគោរព និងអនុវត្តន៍ច្បាប់ដែលមានស្រាប់ឲ្យបានខ្ជាប់ខ្ជួន ដោយម៉ឺងម៉ាត់ និងមិនយោគយល់ជាដាច់ខាត ចំពោះជនប្រព្រឹត្តបទល្មើស។

❖ **ចំពោះតុលាការ**

- គប្បីផ្តន្ទាទោសអោយបានធ្ងន់ធ្ងរបំផុត ទៅតាមច្បាប់ដែលមានចែង ដើម្បីអោយជនប្រព្រឹត្តបទល្មើសភ្ញាក់រលឹក និងជាគំរូសម្រាប់អ្នកក្រោយៗទៀត កុំអោយប្រព្រឹត្តតាម។

❖ **ចំពោះរាជរដ្ឋាភិបាល**

- គប្បីបង្កើតច្បាប់ពិសេស ដាច់ដោយឡែក ដែលបញ្ញត្តិអំពីការកេងប្រវ័ញ្ចពលកម្មកុមារ និងទោសទណ្ឌចំពោះជនដែលប្រព្រឹត្តបទល្មើស
- គប្បីមានវិធានការបន្ថែម ដែលធានាដល់ការអនុវត្តច្បាប់ជាតិ និងច្បាប់អន្តរជាតិ ឲ្យបានពេញលេញក្នុងការលុបបំបាត់ពលកម្មកុមារ
- គប្បីបង្កើតឲ្យមាន គណៈកម្មាធិការអចិន្ត្រៃយ៍មួយ ដើម្បីឃ្លាំមើល និងស៊ើបអង្កេតលើករណីពលកម្មកុមារ និងសហការណ៍ជាមួយសមត្ថកិច្ចជំនាញ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាប បទល្មើសទាក់ទងនឹងពលកម្មកុមារ
- គប្បីធ្វើកិច្ចសហប្រតិបត្តិការ ជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិអោយបានច្រើន ដើម្បីស្វែងរកដំណោះស្រាយបញ្ហាពលកម្មកុមារ
- គប្បីបញ្ចូលគោលនយោបាយលុបបំបាត់ពលកម្មកុមារ នៅក្នុងផែនការអភិវឌ្ឍន៍ជាតិ
- កំណែទម្រង់ ស៊ីជម្រៅ ក្នុងការកាត់បន្ថយភាពក្រីក្រ ដើម្បីឲ្យប្រជាពលរដ្ឋមានលទ្ធភាពបញ្ជូនកូនទៅសាលា ជៀសវាងបញ្ជូនកូនទៅរកប្រាក់មកផ្គត់ផ្គង់គ្រួសារ។

# ឯកសារយោង

# ឯកសារយោង៖


❖ **បទដ្ឋានគតិយុត្តជាតិ៖**

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
- ច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧
- ច្បាប់ស្ដីពីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨

❖ **បទដ្ឋានគតិយុត្តអន្តរជាតិ៖**

- សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨
- អនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារ ឆ្នាំ១៩៨៦
- ពិធីសារបន្ថែមនៃអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារ ឆ្នាំ២០០៩
- អនុសញ្ញាលេខ ១៣៨ ស្ដីពីការកំរិតអាយុអប្បបរមាសម្រាប់ចូលធ្វើការងារ ឆ្នាំ១៩៧៦
- អនុសញ្ញាលេខ ១៨២ ស្ដីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ១៩៩៩
- ពិធីសារបន្ថែមដើម្បីទប់ស្កាត់ បង្ក្រាប និងផ្ដន្ទាទោសចំពោះការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ឆ្នាំ២០០០

❖ **សៀវភៅ និងរបាយការណ៍៖**

- កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្ដីពីបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បោះពុម្ពលើកទី២ ឆ្នាំ២០១៣
- សៀវភៅ Human Trafficking in Cambodia: Reintegration of Cambodia illegal migrants from Vietnam and Thailand, Singapore, June 2009. https:/www.rsis.edu.sg/wp-content/upload/rsis-pubs/WP181.pdf
- របាយការណ៍៖ ការអភិវឌ្ឍលើទាសភាព "ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារក្នុងសិប្បកម្មឥដ្ឋនៅកម្ពុជា", លីកាដូ, ភ្នំពេញ ២០១៦ http://www.licadho-cambodia.org/reports/file/221kLICADHO_Built_On_Slavery_Report_KHM.pdf

- របាយការណ៍៖ The Global Slavery Index, How many people are in modern slavery in Cambodia?

  http://www.globalslaveryindex.org/country/cambodia/

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

❖ **ឧបសម្ព័ន្ធរូបភាព**

ឧបសម្ព័ន្ធទី១៖ កុមារដែលធ្វើការនៅក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

ឧបសម្ព័ន្ធទី២៖ កុមារពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលស្ថិតក្នុងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

ឧបសម្ព័ន្ធទី៣៖ ជនសង្ស័យដែលត្រូវបានបញ្ជូនទៅតុលាការ ពាក់ព័ន្ធនឹងករណីកេងប្រវ័ញ្ចពលកម្មលើអ្នកសុំទានជាកុមារផងដែរ ។

❖ **ឧបសម្ព័ន្ធគតិយុត្ត**

ឧបសម្ព័ន្ធទី១៖ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ។

ឧបសម្ព័ន្ធទី២៖ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម ។

ឧបសម្ព័ន្ធទី៣៖ អនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់លុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ។

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធទី១៖



កុមារា ដែលធ្វើការនៅសិប្បកម្មផលិតឥដ្ឋមួយកន្លែង



កុមារីរុញរទេះដឹកឥវ៉ាន់ឆ្លងដែន (ពេលទៅយកឥវ៉ាន់ពីទឹកដីថៃ)



កុមារីដែលលក់ផ្កាលើមហាវិថីសហព័ន្ធរុស្សី



ក្មេងប្រុសដែលមានអាយុពី ១៣ ដល់ ១៥ ឆ្នាំដែលធ្វើជាកម្មករសំណង់មួយកន្លែងនៅរាជធានីភ្នំពេញ



កុមារា ដែលធ្វើការនៅកន្លែងលាងសម្អាតយានយន្តមួយកន្លែងក្នុងរាជធានីភ្នំពេញ

## ឧបសម្ព័ន្ធទី២៖

អធិការដ្ឋាននគរបាលក្រុងច្បារមន

1h ·

កម្លាំងនគរបាលក្រុងច្បារមននិងនគរបាលរដ្ឋបាលប៉ុស្តិ៍ស្វាយក្រវ៉ាន់ ធ្វើការស្រាវជ្រាវ បង្ក្រាបមុខសញ្ញាជួញដូរ គ្រឿងញៀននៅថ្ងៃទី01-08-2020 វេលាម៉ោង១២-៤៧នាទី នៅក្នុងភូមិផ្សារចាស់សង្កាត់ស្វាយក្រវ៉ាន់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ឃាត់មុខសញ្ញាចំនួន០៣នាក់។

១/ឈ្មោះម៉ៅ-រ៉ាដែន ភេទប្រុសអាយុ១៦ឆ្នាំសព្វថ្ងៃនៅភូមិពាណិជ្ជកម្មសង្កាត់រការធំក្រុងច្បារមន ។

២/ឈ្មោះពេជ្យ ណាសៀនភេទប្រុសអាយុ១៧ឆ្នាំសព្វថ្ងៃនៅភូមិអូរ១សង្កាត់៤ក្រុងកំពង់សោម ខេត្តព្រះសីហនុ។

៣/ឈ្មោះរ៉េង-សំបូរហៅកុយ ភេទប្រុសអាយុ២០ឆ្នាំសព្វថ្ងៃនៅភូមិត្រស់សង្កាត់ស្វាយក្រវ៉ាន់ក្រុងច្បារមន។

ក្នុងកិច្ចប្រតិបត្តិការខាងលើកម្លាំងយើងបានដកហូតម្សៅក្រាមសថ្លាសង្ស័យថាគ្រឿងញៀនម៉ាទឹកកកចំនួន១៦កញ្ចប់ ១៥កញ្ចប់ធំនិង០១កញ្ចប់តូចនិងជញ្ជីងថ្លឹងគ្រឿងញៀនចំនួន១និងឧបករណ៍វេចខ្ចប់មួយចំនួន។ មុខសញ្ញានិងវត្ថុតាំងកសាងសំណុំរឿងបញ្ជូនទៅតុលាកាចាត់ការតាមនីតិវិធី៕



# ឧបសម្ព័ន្ធទី៣៖



សមត្ថកិច្ចសម្រេចបញ្ជូនមន្ត្រីជាប់កិច្ចសន្យា នៃមន្ទីរសង្គមកិច្ច រាជធានីភ្នំពេញ ចំនួន៣នាក់ ទៅតុលាការ
បន្ទាប់ពីសង្ស័យថាពួកគេជាប់ពាក់ព័ន្ធករណីកេងប្រវ័ញ្ចពលកម្មលើអ្នកសុំទាន ដែលរួមមានអ្នកសុំទានជាកុមារផងដែរ។